ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣
# ស្តីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ការវាយតម្លៃពាក់កណ្តាលអាណត្តិ

ជំនួយពីពលរដ្ឋអាមេរិក

# សារលិខិត

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
## និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!*

ស្ថានភាព និងបរិយាកាសសង្គមនៅក្នុងពិភពលោក បានប្រែប្រួលគួរឱ្យកត់សម្គាល់ និងជះឥទ្ធិពលយ៉ាងខ្លាំងមកលើកិច្ចប្រតិបត្តិការគ្រប់វិស័យ ខុសពីការគ្រោងទុក។ ទាំងគ្រោះធម្មជាតិផ្សេងៗបញ្ហាអសន្តិសុខក្នុងតំបន់ និងជំងឺរាតត្បាតដ៏កាចសាហាវកូវីដ-១៩ បានបន្តជះឥទ្ធិពលដល់សុខភាព សុវត្ថិភាព និងជីវិតមនុស្សរាប់លាននាក់។ រាជរដ្ឋាភិបាលកម្ពុជាខិតខំយកចិត្តទុកដាក់លើសុខុមាលភាព និងអាយុជីវិតប្រជាពលរដ្ឋ ឱ្យជៀសផុតពីជំងឺរាតត្បាត ការទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដែលខ្វះខាត ការរក្សាសន្តិសុខ និងស្ថេរភាពសង្គម។ ក្នុងស្ថានភាពបែបនេះ របៀបរបបការងារ ត្រូវបានផ្លាស់ប្តូរដោយកាត់បន្ថយការជួបជុំទ្រង់ទ្រាយធំដោយផ្ទាល់ ការកាត់បន្ថយសកម្មភាពបណ្តុះបណ្តាល អប់រំផ្សព្វផ្សាយនានា ហើយក្នុងពេលដែលប្រជាពលរដ្ឋកំពុងស្ថិតក្នុងស្ថានភាពភ័យបារម្ភ ជនល្មើសឆ្លៀតឆក់ឱកាស កេងប្រវ័ញ្ចជនងាយរងគ្រោះ ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយ អង្គការវីនរ៉ក់អន្តរជាតិ (Winrock International) ក្រោមជំនួយឧបត្ថម្ភរបស់ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ធ្វើការប៉ាន់ប្រមាណវាយតម្លៃ ពាក់កណ្តាលអាណត្តិ ការអនុវត្ត "ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស "ដើម្បីប៉ាន់ប្រមាណ អំពីលទ្ធផលការងារ ភាពប្រឈម ផលប៉ះពាល់ ឱកាស លទ្ធភាព ធនធាន គួបផ្សំនឹងចំណុចខ្លាំង ចំណុចខ្សោយដែលមាន សម្រាប់ធ្វើជាមូលដ្ឋានគ្រឹះ ក្នុងការរកគន្លឹះដោះស្រាយ និងកែសម្រួលរបៀបប្រតិបត្តិការ ដែលឆ្លើយតបទៅនឹងស្ថានការណ៍ថ្មី សម្រាប់ឆ្នាំ២០២២ និង២០២៣ ឱ្យកាន់តែមានប្រសិទ្ធភាព។

ខាងក្រោមនេះជាលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ "ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស" ដែលលោកស្រី រ៉ូប៊ីន មូនី អ្នកវាយតម្លៃឯករាជ្យ និងសហការី បានស្រាវជ្រាវ ប៉ាន់ប្រមាណ និងវាយតម្លៃ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងទទួលបានព័ត៌មាន និងទិន្នន័យជាក់លាក់ សម្រាប់ការងារបន្តរបស់យើងទាំងអស់គ្នា ។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះការខិតខំប្រឹងប្រែងរបស់គ្រប់ក្រសួង-ស្ថាប័ន អង្គភាពជំនាញ និងអង្គការដៃគូ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវ ឆន្ទៈមោះមុត ជម្នះគ្រប់ឧបសគ្គ ដើម្បីសុវត្ថិភាពពលរដ្ឋយើងពីអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្សគ្រប់រូបភាព ។

សូមគោរពជូនពរ សុខភាពល្អ និងជ័យជម្នះគ្រប់ភារកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹង ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២
ហត្ថលេខា

**ជូ ប៊ុនអេង**

# មាតិកា


**ពាក្យសរសេរកាត់**......1

**សារចនា**...... 3

**១. គោលបំណង**...... 4

**២. វិធីសាស្ត្រ**...... 4

២.១ សំណួរស្រាវជ្រាវ...... 4

២.២ វិធីសាស្ត្របច្ចេកទេស...... 5

២.៣ ការពិនិត្យលើទិន្នន័យដែលបានពីឯកសារពាក់ព័ន្ធ...... 5

២.៤ ការប្រមូលទិន្នន័យបឋម...... 5

**៣. របកគំហើញ**...... 7

៣.១ ការបង្កើត មុខងារ និងតួនាទីនៃយន្តការ...... 7

៣.២ ចំណុចខ្លាំង និងបញ្ហាប្រឈមនៃស្ថាប័នអនុវត្ត និងការសម្របសម្រួល......9

៣.២.១ ចំណុចខ្លាំងនៃយន្តការ...... 9

៣.២.២ បញ្ហាប្រឈមនៃយន្តការ......13

៣.៣ ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ......15

៣.៤ ការអនុវត្ត និងការសម្រេចតាមចំណុចដៅដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រ......18

៣.៤.១ យុទ្ធសាស្ត្រទី ១៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា...... 19

៣.៤.២ យុទ្ធសាស្ត្រទី ២៖ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ...... 26

៣.៤.៣ យុទ្ធសាស្ត្រទី ៣៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ...... 35

៣.៤.៤ យុទ្ធសាស្ត្រទី ៤៖ បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ...... 39

**៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍**...... 42

**៥ បណ្តុំឧបករណ៍ប្រមូលទិន្នន័យ**...... 50

# ពាក្យសរសេរកាត់

| | | |
|---|---|---|
| AAPTIP | Australia-Asia Program to Combat Trafficking in Persons | កម្មវិធីអូស្ត្រាលី-អាស៊ីប្រឆាំងអំពើជួញដូរមនុស្ស |
| CLMTV | Cambodia, Lao, Myanmar, Thai, and Vietnam | ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម |
| CoM | Council of Ministers | គណៈរដ្ឋមន្ត្រី |
| COMMIT | Coordinated Mekong Ministerial Initiative against Trafficking | គំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់ទន្លេមេគង្គ |
| CTIP | Counter Trafficking in Persons | ការប្រឆាំងអំពើជួញដូរមនុស្ស |
| CWCC | Cambodia Women's Crisis Center | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| DoSAVY | Department of Social Affairs Veterans and Youth Rehabilitation | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| EPS | Employment Permit System | ប្រព័ន្ធចេញលិខិតអនុញ្ញាតការងារ |
| GCM | Global Compact on Migration | កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ |
| I/LNGOs | International and local non-governmental Organizations | អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ |
| ILO | International Labor Organization | អង្គការអន្តរជាតិខាងការងារ |
| IOM | International Organization for Migration | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| IRIS | International Recruitment Integrity System | ប្រព័ន្ធអន្តរជាតិដើម្បីធានាសុចរិតភាពក្នុងការជ្រើសរើសពលករ |
| KII | Key informant Interviews | កិច្ចសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ |
| MoAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MoCR | Ministry of Cults and Religions | ក្រសួងធម្មការ និងសាសនា |
| MoEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoInf | Ministry of Information | ក្រសួងព័ត៌មាន |
| MoJ | Ministry of Justice | ក្រសួងយុត្តិធម៌ |
| MoFAIC | Ministry of Foreign Affairs and International Cooperation | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoIH | Ministry of Industry and Handicraft | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

| | | |
|---|---|---|
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoPT | Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MoPF | Ministry of Public Functions | ក្រសួងមុខងារសាធារណៈ |
| MoRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoU | Memorandum of Understanding | អនុស្សរណៈនៃការយោគយល់ |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| NCCT | National Committee for Counter Trafficking | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) |
| NSP | National Strategic Plan | ផែនការយុទ្ធសាស្ត្រជាតិ |
| PDoWA | Provincial Department of Women's Affairs | មន្ទីរកិច្ចការនារី |
| PCCT | Provincial Committee for Counter Trafficking | គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ.) |
| PPE | Personal Protective Equipment | ឧបករណ៍ការពារខ្លួន |
| TIP | Trafficking in Persons | អំពើជួញដូរមនុស្ស |
| TWGs | Thematic Working Groups | ក្រុមការងារជំនាញ |
| UN | United Nations | អង្គការសហប្រជាជាតិ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| UNPFA | United Nations Population Fund | មូលនិធិសហប្រជាជាតិដើម្បីប្រជាជន |

# សារចនា

ក្នុងទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការដាក់ចេញនូវក្របខណ្ឌផែនការយុទ្ធសាស្ត្រនានា ដោយចាប់ផ្ដើមជាមួយនឹងផែនការសកម្មភាពស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១១-២០១៣) មន្ទាប់មកគឺផែនការសកម្មភាពជាតិស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលកំពុងអនុវត្តមកដល់ពេលបច្ចុប្បន្ននេះ។

ក្នុងនាមជាស្ថាប័នផ្ដល់ការណែនាំតម្រង់ទិសក្នុងការអនុវត្តផែនការនីមួយៗ ចាប់តាំងពីត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) ទទួលខុសត្រូវសម្របសម្រួល និងរៀបចំរបាយការណ៍ស្ដីពីកិច្ចខិតខំប្រឹងប្រែងក្នុងការឆ្លើយតប និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងគ្រប់វិស័យទាំងអស់ ដោយមានការជួយគាំទ្រពី ក្រុមការងារជំនាញចំនួន ៦ (ក្រុមការងារជំនាញផ្នែក៖ បង្ការទប់ស្កាត់ ការពារជនរងគ្រោះ អនុវត្តច្បាប់ កិច្ចការយុត្តិធម៌ ទំនាក់ទំនងអន្តរជាតិ និងទេសន្តរប្រវេសន៍) ព្រមទាំងគណៈកម្មាធិការរាជធានី-ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.) ដែលជារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិនៃ គ.ជ.ប.ជ. ក៏ដូចជាការជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

ដោយមានការសម្របសម្រួលផ្ដល់ធាតុចូលពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន ២២ ជាសមាជិករបស់ គ.ជ.ប.ជ. លេខាធិការដ្ឋាន គ.ជ.ប.ជ. បានរៀបចំរបាយការណ៍ប្រចាំឆ្នាំដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំនីមួយៗ។ នៅពាក់កណ្ដាលអាណត្តិនៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ គ.ជ.ប.ជ. បានរៀបចំឱ្យមានការវាយតម្លៃលើវឌ្ឍនភាព និងបញ្ហាប្រឈម ដើម្បីកំណត់ពីយុទ្ធសាស្ត្រ ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនោះ។ ការវាយតម្លៃកាលពីពេលនោះ ធ្វើឡើងក្រោមការគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) តាមរយៈគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (CTIP) របស់អង្គការវីនរ៉ក់អន្តរជាតិ (Winrock International)។

ស្រដៀងគ្នានេះដែរ គ.ជ.ប.ជ. កំពុងធ្វើការវាយតម្លៃពាក់កណ្ដាលអាណត្តិលើផែនការយុទ្ធសាស្ត្រដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ហើយគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (CTIP) ក៏កំពុងផ្ដល់ការគាំទ្របច្ចេកទេសដល់កិច្ចខិតខំប្រឹងប្រែងនេះផងដែរ។ ការវាយតម្លៃពាក់កណ្ដាលអាណត្តិថ្មីនេះមានសារៈសំខាន់ណាស់ បើទោះបីកម្ពុជាបានរងផលប៉ះពាល់ដោយការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ក្នុងអំឡុងពេល ១៨ ខែកន្លងមកនេះក៏ដោយ។ ការវាយតម្លៃនេះក៏នឹងពិនិត្យមើលផងដែរលើផលប៉ះពាល់ដែលជំងឺកូវីដ១៩ មានមកលើសកម្មភាពដែលត្រូវបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

# ១. គោលបំណង

- វាយតម្លៃលើ*ការបង្កើត មុខងារ និងតួនាទី*របស់ គ.ជ.ប.ជ. ក្រុមការងារជំនាញ គ.រ/ខ.ប.ជ. និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ក៏ដូចជាជាមួយវិស័យឯកជននានា ក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- វាយតម្លៃលើ*ផលប៉ះពាល់នៃជំងឺកូវីដ១៩ លើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ*ក្នុងគ្រប់ វិស័យ និងគ្រប់កម្រិត (ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ)។
- វាយតម្លៃលើ*ការអនុវត្ត និងសមិទ្ធផលសម្រេចបាន ធៀបនឹងគោលដៅក្នុងផែនការ និងក្នុងយុទ្ធសាស្ត្ររួម ចំណុចខ្វះខាត និងបញ្ហាប្រឈម* ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងប្រទេស ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ និងស្ថាប័នវិស័យឯកជន។
- វាយតម្លៃលើ*សមិទ្ធផល និងចំណុចខ្វះខាត* ក្នុងការអនុវត្ត ព្រមទាំងចំណុចខ្លាំង និងចំណុចខ្សោយនៃស្ថាប័នអនុវត្ត ការសម្របសម្រួល និងប្រព័ន្ធពិនិត្យតាមដាននិងរាយការណ៍។
- ផ្តល់ *អនុសាសន៍ជាក់លាក់* សម្រាប់ពង្រឹងយន្តការ អនុវត្ត ពិនិត្យតាមដាននិងរាយការណ៍ប្រកបដោយប្រសិទ្ធភាព លើផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

# ២. វិធីសាស្ត្រ

## ២.១ សំណួរស្រាវជ្រាវ

**ដំណើរការប្រព្រឹត្តិទៅនៃយន្តការ (គ.ជ.ប.ជ)៖**

- តើ គ.ជ.ប.ជ. និង គ.រ/ខ.ប.ជ. មានមុខងារ តួនាទី និងការទទួលខុសត្រូវអ្វីខ្លះក្នុងការពិនិត្យតាមដាន និងរាយការណ៍ពីការអនុវត្ត (រាប់បញ្ចូលទាំងក្រុមការងារជំនាញបច្ចេកទេស និងទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ)?
- តើ គ.ជ.ប.ជ. និង គ.រ/ខ.ប.ជ. មានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ ក្នុងការសម្របសម្រួល ពិនិត្យតាមដាន និងរាយការណ៍ពីការអនុវត្ត?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឆ្លើយតបចំពោះចំណុចខ្សោយទាំងនេះ?

**សមិទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៖**

- តើយើងមានសូចនាករចម្បងៗអ្វីខ្លះ ដើម្បីវាស់វែងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ?
- តើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រេចបានកម្រិតណា ធៀបនឹងសូចនាករទាំងនេះ?
- តើជំងឺកូវីដ១៩ បង្កផលប៉ះពាល់អ្វីខ្លះមកលើកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចតាមសូចនាករទាំងនេះ?

- តើការងារណាខ្លះដែលត្រូវកែសម្រួលឡើងវិញតាមរយៈការកំណត់សូចនាករថ្មីដោយសារជំងឺកូវីដ១៩?
- អនុសាសន៍ និងឧបករណ៍ ដើម្បីពង្រឹងការរាយការណ៍អំពីសូចនាករគន្លឹះ

## ២.២ វិធីសាស្ត្របច្ចេកទេស

វិធីសាស្ត្របច្ចេកទេសសម្រាប់ធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិ មានលក្ខណៈជាប្រព័ន្ធ និងជាកិច្ចសហការ។ វិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យពាក់ព័ន្ធយកមកធ្វើការវិភាគ រួមមានការពិនិត្យមើលឯកសារ និងធនធានដែលមានស្រាប់ និងការប្រមូលធាតុចូលសម្រាប់វាយតម្លៃពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ។ វិធីសាស្ត្រប្រមូលសំណាកតាមបំណងស្រាវជ្រាវ ត្រូវបានប្រើប្រាស់ដើម្បីប្រមូលធាតុចូល ពីអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ រាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត។

## ២.៣ ការពិនិត្យលើទិន្នន័យដែលបានពីឯកសារពាក់ព័ន្ធ

ជំហានទី ១ គឺការពិនិត្យលើទិន្នន័យក្នុងឯកសារពាក់ព័ន្ធដែលមានស្រាប់។ ការពិនិត្យលើទិន្នន័យទាំងនេះរួមមាន របាយការណ៍សង្ខេបស្តីពីស្ថានភាពបច្ចុប្បន្ននៃការជួញដូរមនុស្សនៅកម្ពុជា (បញ្ហាបច្ចុប្បន្ន) ឯកសារ/របាយការណ៍ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃ គ.ជ.ប.ជ. និងដើម្បីចងក្រងឯកសារអំពីវឌ្ឍនភាព និងសមិទ្ធផល ធៀបនឹងគោលដៅដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្ររបស់ គ.ជ.ប.ជ. រួមនឹងជោគជ័យ និង/ឬ បញ្ហាប្រឈមចម្បងៗ ។

ឯកសារ/របាយការណ៍សំខាន់ៗដែលត្រូវបានយកមកពិនិត្យរួមមាន៖

- ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣)ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- របាយការណ៍របស់ គ.ជ.ប.ជ. និងក្រុមការងារជំនាញ
- គេហទំព័ររបស់ គ.ជ.ប.ជ.
- របាយការណ៍នៃកិច្ចប្រជុំវាយតម្លៃ ដែលត្រូវបានរៀបចំឡើងនៅក្នុងខែកក្កដា ឆ្នាំ២០២១ ដើម្បីពិភាក្សាពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣)ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## ២.៤ ការប្រមូលទិន្នន័យបឋម

ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KII) ត្រូវបានធ្វើឡើងជាមួយអ្នកពាក់ព័ន្ធនៅរាជធានីភ្នំពេញ ដូចជា គ.ជ.ប.ជ. និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ទីភ្នាក់ងារសហប្រជាជាតិ (UN) អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ លើសពីនេះក៏មានការសម្ភាសជាមួយ គ.ខ.ប.ជ. ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាម កំពង់ធំ ឧត្តរមានជ័យ ព្រៃវែង ស្វាយរៀង និងសៀមរាប។ ដោយសារតែមានការរឹតត្បិតលើការធ្វើដំណើរ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ការសម្ភាសទាំងនេះត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ Zoom ជំនួសឱ្យការទៅដល់ខេត្តដោយផ្ទាល់។ ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានធ្វើឡើង

ដោយប្រើប្រាស់ទម្រង់សម្ភាសស៊ីជម្រៅពាក់កណ្ដាលរចនាសម្ព័ន្ធ (semi-structured in-depth interview format)។ គោលណែនាំសម្រាប់ការសម្ភាសមានផ្ដល់ជូននៅក្នុងផ្នែក ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ។

*តារាងទី ១៖ កិច្ចសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗសម្រាប់វាយតតម្លៃពាក់កណ្ដាលអាណត្តិលើផែនការយុទ្ធសាស្ត្រជាតិ*

| អ្នកផ្ដល់ព័ត៌មានសំខាន់ៗ | ចំនួននៃការសម្ភាស | ប្រភេទនៃការសម្ភាស |
|---|---|---|
| ***រដ្ឋាភិបាល*** | | |
| គ.ជ.ប.ជ. | ១ | KII |
| ក្រសួងអប់រំ យុវជន និងកីឡា | ១ | KII |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ២ | KII |
| ក្រសួងមហាផ្ទៃ នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស | ១ | KII |
| ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ២ | KII |
| ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | ១ | KII |
| ក្រសួងកិច្ចការនារី | ១ | KII |
| ក្រសួងយុត្តិធម៌ | ១ | ផ្ដល់ការឆ្លើយតបជាលាយលក្ខអក្សរ |
| គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ.) បាត់ដំបង | ១ | KII |
| គ.ខ.ប.ជ. បន្ទាយមានជ័យ | ១ | KII |
| គ.ខ.ប.ជ. កំពង់ចាម | ១ | KII |
| គ.ខ.ប.ជ. កំពង់ធំ | ១ | KII |
| គ.ខ.ប.ជ. ឧត្តរមានជ័យ | ១ | KII |
| គ.ខ.ប.ជ. ព្រៃវែង | ១ | KII |
| គ.ខ.ប.ជ. ស្វាយរៀង | ១ | KII |
| គ.ខ.ប.ជ. សៀមរាប | ១ | KII |
| ***អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ*** | | |
| Adhoc | ១ | KII |
| Cambodia ACTs | ១ | KII |
| Damnok Toek | ២ | KII |
| Chab Dai | ១ | KII |
| Hagar | ១ | KII |
| A21 | ១ | KII |
| APLE | ១ | KII |

| | | |
|---|---|---|
| Caritas | ១ | KII |
| Friends International | ១ | KII |
| Hope for Justice | ១ | KII |
| International Justice Mission | ១ | KII |
| Legal Services for Children and Women | ១ | KII |
| Ratanak International | ១ | KII |
| Samaritan's Purse | ១ | KII |
| World Hope International | ១ | KII |
| *ទីភ្នាក់ងារអង្គការសហប្រជាជាតិ* | | |
| មូលនិធិសហប្រជាជាតិ ដើម្បីប្រជាជន (UNFPA) | ១ | KII |
| អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) | ១ | KII |
| អង្គការអន្តរជាតិខាងការងារ (ILO) | ១ | KII |

# ៣. របកគំហើញ

## ៣.១ ការបង្កើត មុខងារ និងតួនាទីនៃយន្តការ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ហៅកាត់ថា គ.ជ.ប.ជ.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត ០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤។ គ.ជ.ប.ជ. គឺជាយន្តការជាតិដែលមានភារកិច្ចដឹកនាំ សម្របសម្រួល ជំរុញ ប្រមូលព័ត៌មាន ចងក្រងទិន្នន័យ និងផ្តួចផ្តើមកសាងច្បាប់ គោលនយោបាយ ផែនការ និងជំរុញឱ្យមានការចូលរួមអនុវត្តពីសំណាក់ភាគីពាក់ព័ន្ធ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

យន្តការនេះ ក្នុងពេលបច្ចុប្បន្ន មានក្រសួងចំនួន ២២ និងអង្គភាពជំនាញចំនួន ៥ ជាសមាជិកដោយមានក្រុមការងារអន្តរក្រសួងចំនួន ៦ ទទួលខុសត្រូវលើការអនុវត្តការងារក្នុងក្រុមជំនាញ។ រចនាសម្ព័ន្ធនៃ គ.ជ.ប.ជ. ត្រូវបានបង្កើតឡើង និងបញ្ជាក់តាមរយៈការដាក់ចេញនូវសេចក្តីសម្រេចជាបន្តបន្ទាប់។ ការងាររបស់ គ.ជ.ប.ជ. ត្រូវបានអនុវត្ត ផ្អែកតាមផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ក្រសួងជាសមាជិក៖** ១) ក្រសួងមហាផ្ទៃ ២) ក្រសួងអប់រំ យុវជន និងកីឡា ៣) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៤) ក្រសួងយុត្តិធម៌ ៥) ក្រសួងកិច្ចការនារី ៦) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៧) ក្រសួងសុខាភិបាល ៨) ក្រសួងទេសចរណ៍ ៩) ទីស្តីការគណៈរដ្ឋមន្ត្រី ១០) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១១) ក្រសួងការពារជាតិ ១២) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១៣) ក្រសួងផែនការ ១៤) ក្រសួងព័ត៌មាន ១៥) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១៦) ក្រសួងអភិវឌ្ឍន៍

ជនបទ ១៧) ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១៨) ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ១៩) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ២០) ក្រសួងធម្មការ និងសាសនា ២១) ក្រសួងមុខងារសាធារណៈ និង ២២) ក្រសួងសាធារណៈការ និងដឹកជញ្ជូន។

**អង្គភាពជំនាញជាសមាជិក៖** អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ នាយកដ្ឋានកិច្ចការព្រំដែននៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។

**ក្រុមការងារជំនាញ៖** ក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នចំនួន ៦ក្រុម ត្រូវបានរៀបចំបង្កើតឡើងដោយសេចក្តីសម្រេចរបស់ គ.ជ.ប.ជ. លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ៖

១) ក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

២) ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣) ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការនគរបាលជាតិ

៤) ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

៥) ក្រុមការងារទំនាក់ទំនងអន្តរជាតិ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី

៦) ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ.៖** គ.ជ.ប.ជ. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ បង្កើតដោយអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍នៃ គណៈកម្មាធិការជាតិ ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលបច្ចុប្បន្នគឺលោកជំទាវ ជូ ប៊ុនអេង។ អគ្គលេខាធិការដ្ឋានមានភារកិច្ចសំខាន់ក្នុងការសម្របសម្រួល ដឹកនាំ ជំរុញកិច្ចសហប្រតិបត្តិការរវាងអន្តរក្រសួង-ស្ថាប័ន រួមទាំងដៃគូសហការនានា ទាំងក្នុង និងក្រៅប្រទេស ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិរបស់ គ.ជ.ប.ជ.៖** គ.ជ.ប.ជ. មានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិ នៅតាមបណ្តារាជធានី-ខេត្ត ដោយមានគណៈកម្មាធិការរាជធានី-ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.) តាមសេចក្តីសម្រេចលេខ ០០១/១៤ សសរ ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៤។ គណៈកម្មាធិការរាជធានី-ខេត្តដឹកនាំដោយអភិបាលរាជធានី អភិបាលខេត្ត មានសមាជិកជាប្រធានគ្រប់មន្ទីរ-ស្ថាប័នក្រោមឱវាទ និងអភិបាលគ្រប់ក្រុង ស្រុក ខណ្ឌក្រោមចំណុះ។ គ.រ.ប.ជ./គ.ខ.ប.ជ. មានលេខាធិការដ្ឋាន

ដឹកនាំដោយអភិបាលរងមួយរូប និងក្រុមការងារអន្តរមន្ទីរ-ស្ថាប័ន ចំនួន ៦ ដូចគ្នានឹងថ្នាក់ជាតិដែរ។ លើសពីនេះទៅទៀត បណ្តាញការងារគណៈកម្មាធិការ ក៏មាននៅតាមបណ្តាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផងដែរ។

ក្រសួង ស្ថាប័ន អង្គភាពជាសមាជិក គ.ជ.ប.ជ. នៅថ្នាក់ជាតិ ក៏ដូចជាមន្ទីរអង្គភាព ជាសមាជិក គ.រ.ប.ជ. និងគ.ខ.ប.ជ. អនុវត្តផែនការ សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទៅតាមយុទ្ធសាស្រ្តដែលបានកំណត់។

គ.ជ.ប.ជ. មានភារៈកិច្ចប្រមូលផ្តុំកិច្ចសហការ គំនិតផ្តួចផ្តើម និងចំណេះជំនាញ ពីគ្រប់ដៃគូពាក់ព័ន្ធ ទាំងកម្រិតជាតិ និង អន្តរជាតិ ដើម្បីបង្កើតបានជាកម្លាំងចលករួមមួយ ដែលមានធនធាន និងមធ្យោបាយរួមគ្នាក្នុងការធ្វើឱ្យសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ ប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយជោគជ័យ។

> *"គ.ជ.ប.ជ. មានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់អនុវត្តការងាររបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ"*
> អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ

## ៣.២ ចំណុចខ្លាំង និងបញ្ហាប្រឈមនៃស្ថាប័នអនុវត្ត និងការសម្របសម្រួល

ផ្នែកនេះវាយតម្លៃលើចំណុចខ្លាំង និងបញ្ហាប្រឈមនៃយន្តការអនុវត្ត (គ.ជ.ប.ជ. ក្រុមការងារជំនាញ គ.រ/ខ.ប.ជ.)។ របកគំហើញទាំងនេះត្រូវបានសង្ខេបចេញពីព័ត៌មានដែលទទួលបានពីការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) របាយការណ៍ និងការសង្កេតរបស់ទីប្រឹក្សា។ នៅត្រង់ចំណុចដែលទិន្នន័យទទួលបានមកពីប្រភពផ្សេងក្រៅពី KIIs នឹងមានការបញ្ជាក់ជូន។

### ៣.២.១ ចំណុចខ្លាំងនៃយន្តការ

នៅក្នុងផ្នែកនេះចំណុចខ្លាំងនៃ គ.ជ.ប.ជ. គ.រ/ខ.ប.ជ. និងក្រុមការងារត្រូវបានបង្ហាញជូនទៅតាមការលើកឡើងរបស់អ្នកផ្តល់ព័ត៌មានសំខាន់ៗនៅក្នុងការសិក្សានេះ។

#### *៣.២.១.១ ស្ថានភាពជារួម*

**រចនាសម្ព័ន្ធ៖** រចនាសម្ព័ន្ធដូចបានបង្ហាញនៅក្នុងផ្នែកមុននេះ គ.ជ.ប.ជ. គ.រ/ខ.ប.ជ. ក្រុមការងារជំនាញ មានរចនាសម្ព័ន្ធច្បាស់លាស់ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យ និងសេចក្តីសម្រេចនានា។ មកដល់បច្ចុប្បន្ននេះ រចនាសម្ព័ន្ធនេះត្រូវបានដាក់ឱ្យអនុវត្តជាង ៧ឆ្នាំហើយ។ អ្នកតបសម្ភាសន៍បានរាយការណ៍ថា រចនាសម្ព័ន្ធនេះមានភាពគ្រប់គ្រាន់ និងផ្តល់នូវក្របខណ្ឌរឹងមាំសម្រាប់អនុវត្តសកម្មភាពបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការជួញដូរមនុស្ស។

**ការប្តេជ្ញាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** អ្វីដែលសំខាន់គឺ អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ គ.ជ.ប.ជ. បានលើកឡើងថា គ.រ/ខ.ប.ជ. និងក្រុមការងារជំនាញ មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស។

### *៣.២.១.២ គ.ជ.ប.ជ.*

**ការសម្របសម្រួល៖** គ.ជ.ប.ជ. បំពេញតួនាទីសម្របសម្រួលរវាងក្រសួង-ស្ថាប័ន ក្រុមការងារជំនាញ គ.រ/ខ.ប.ជ. និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ។ ការសម្របសម្រួលនេះ ធ្វើឡើងតាមរចនាសម្ព័ន្ធជាផ្លូវការដូចជា កិច្ចប្រជុំទៀងទាត់ ការធ្វើរបាយការណ៍ និងតាមរយៈយន្តការក្រៅផ្លូវការដូចជាតាមរយៈកម្មវិធីផ្ញើសារ ដូចជា តេឡេក្រាម (Telegram) ជាដើម។

*"គ.ជ.ប.ជ. តែងតែមានពេលជានិច្ច នៅពេលដែលយើងត្រូវការសុំយោបល់ ពេលជួបប្រទះនឹងបញ្ហានានា"*

គ.ខ.ប.ជ.

គ.ជ.ប.ជ. ត្រូវបានទទួលស្គាល់ជាបន្តបន្ទាប់ថាបានសម្រេចជោគជ័យក្នុងការបំពេញតួនាទីសម្របសម្រួលរបស់ខ្លួន ជាមួយក្រុមការងារជំនាញ គ.រ/ខ.ប.ជ. អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ក៏ដូចជា ជាមួយនឹងអ្នកដឹកនាំសាសនានិងសហគមន៍នានា។ ប៉ុន្តែមានការលើកឡើងថា គ.ជ.ប.ជ. ទទួលបានជោគជ័យជាងគេ ក្នុងការសម្របសម្រួលជាមួយនឹង គ.រ/ខ.ប.ជ. និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ។ តំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិមួយចំនួនរាយការណ៍ថា ពួកគេបានចុះអនុស្សរណៈ (MoUs) ជាមួយ គ.ជ.ប.ជ.។ អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិរាយការណ៍ថា ការធ្វើការងារជាមួយ គ.ជ.ប.ជ. ដោយផ្ទាល់តាមរយៈការចុះអនុស្សរណៈ ជួយសម្រួលដល់កិច្ចសហការឱ្យកាន់តែមានប្រសិទ្ធភាពជាងការធ្វើការងារជាមួយនឹងក្រុមការងារជំនាញ ឬធ្វើការងារដាច់ដោយឡែកតែឯង។

*"គ.ជ.ប.ជ. បំពេញតួនាទីសំខាន់ក្នុងការសម្របសម្រួលរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប្រសិនបើពុំមានតួនាទីបែបនេះនោះទេ យើងប្រាកដជាជួបប្រទះនឹងបញ្ហាប្រឈមកាន់តែច្រើន ព្រោះថាក្រសួង-ស្ថាប័ននីមួយៗសុទ្ធតែមានផែនការការងាររៀងៗខ្លួន"*

ក្រសួង

**ទំនាក់ទំនង៖** អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ និងក្រុមការងារជំនាញ និង គ.រ/ខ.ប.ជ ទទួលស្គាល់ថា គ.ជ.ប.ជ. ទំនាក់ទំនងការងារបានល្អ។ គ.ជ.ប.ជ. ត្រូវបានមើលឃើញថា តែងមានពេលវេលាដើម្បីផ្តល់ការគាំទ្របច្ចេកទេស ដល់ គ.រ/ខ.ប.ជ. និងបានឆ្លើយតបចំពោះអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ និងក្រុមការងារជំនាញ។ ការបើកចំហក្នុងការទំនាក់ទំនងការងារ ក៏ត្រូវបានបង្ហាញតាមរយៈឆន្ទៈរបស់ គ.ជ.ប.ជ. ក្នុងការទទួលយកយោបល់ និងជាតុចូលពីស្ថាប័នដទៃទៀត និងជួយឆ្លើយតបចំពោះបញ្ហាប្រឈមនានាផងដែរ។

**ផែនការយុទ្ធសាស្ត្រ៖** ចំណុចខ្លាំងមួយនៃ គ.ជ.ប.ជ. គឺមានផែនការយុទ្ធសាស្ត្រជាតិ។ ផែនការយុទ្ធសាស្ត្រជាតិត្រូវបានលើកឡើងថាជាឧបករណ៍ដ៏ល្អ ដើម្បីផ្តល់ការណែនាំស្តីពីការបង្ការទប់ស្កាត់ និងការឆ្លើយតបចំពោះករណីជួញដូរមនុស្ស។

*"គ.ខ.ប.ជ.ធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីឆ្លើយតបចំពោះករណីជួញដូរមនុស្ស តាមរយៈការសម្របសម្រួលជាមួយអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីផ្តល់សេវា មិនថាបិតនៅក្នុងម៉ោង ឬក្រៅម៉ោងធ្វើការឡើយ"*

អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ

### *៣.២.១.៣ គ.រ/ខ.ប.ជ.*

**ការសម្របសម្រួល៖** គ.រ/ខ.ប.ជ. ត្រូវបានទទួលស្គាល់ថា បានបំពេញតួនាទីសម្របសម្រួលជាមួយ មន្ទីរជំនាញពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដែលជាអ្នកផ្តល់សេវា និងមន្ត្រីអនុវត្តច្បាប់នៅកម្រិតរាជធានី-ខេត្ត។

មានការលើកឡើងថា កន្លងមកមានការរៀបចំកិច្ចប្រជុំជាទៀងទាត់ នៅក្នុងរាជធានី-ខេត្តភាគច្រើន ដែល គ.ខ.ប.ជ. ត្រូវបានសម្ភាស។ គ.រ/ខ.ប.ជ. បានទទួលការសរសើរជាបន្តបន្ទាប់ថា អាចសម្របសម្រួលបានយ៉ាងល្អជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដែលជាអ្នកផ្តល់សេវា និងក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់សេវានានា និងឆ្លើយតបចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

**ផែនការសកម្មភាព៖** នៅក្នុងខេត្តមួយចំនួនដែល គ.ខ.ប.ជ. អនុវត្តសកម្មភាពយ៉ាងសកម្ម ជាពិសេសនៅតំបន់ជាប់ព្រំដែន ឬតំបន់ដែលមានហានិភ័យខ្ពស់ដែលអាចមានអំពើជួញដូរមនុស្ស គ.ខ.ប.ជ. មានផែនការសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិ។ ខេត្តលេចធ្លោមួយដែលអង្គការជាតិ និងអន្តរជាតិលើកឡើងថាសកម្មជាងគេ គឺខេត្តសៀមរាប។

*"គ.ខ.ប.ជ. នៅកៀកនឹងសហគមន៍ ហើយអាចផ្តល់ការគាំទ្រយ៉ាងល្អ ដូច្នេះជនរងគ្រោះមិនចាំបាច់រងចាំជំនួយនោះឡើយ"*

គ.ខ.ប.ជ.

ឧទាហរណ៍ នៅក្នុងខេត្តសៀមរាប មានការលើកឡើងពីការអនុវត្តល្អមួយ នោះគឺ គ.ខ.ប.ជ. បានរៀបចំផែនការសកម្មភាពខ្លួនផ្អែកតាមផែនការសកម្មភាពជាតិ។ ដំណើរការនេះបានជួយឱ្យខេត្តសៀមរាបកំណត់ពីសកម្មភាពអាទិភាពដែលត្រូវអនុវត្ត និងកំណត់ពីសកម្មភាពសមស្រប ដែលត្រូវរាយការណ៍។

**ការផ្សព្វផ្សាយព័ត៌មាន៖** គ.រ/ខ.ប.ជ. បានរាយការណ៍ថា ខ្លួនបាន សហការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធរមូលដ្ឋាន នៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីផ្សព្វផ្សាយព័ត៌មាន អំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ នេះគឺជាសកម្មភាពជាអាទិភាពមួយ សម្រាប់ គ.ខ.ប.ជ.។

គ.ខ.ប.ជ. មួយចំនួនបានចែករំលែករបាយការណ៍ស្តីពីការផ្សព្វផ្សាយ ព័ត៌មានជាទៀតទាត់តាមរយៈ កិច្ចប្រជុំនៅថ្នាក់ខេត្ត ថ្នាក់ស្រុក ឬថ្នាក់ឃុំ ឬនៅចំកាលបរិច្ឆេទមួយចំនួនដូចជាទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្ងៃទី១២ ខែធ្នូ ជាដើម។

*"ក្រុមការងារជំនាញមានសមាជិក ដែលមានចំណេះដឹងឯកទេសពាក់ព័ន្ធនឹងអាទិភាពការងាររបស់ក្រុមការងារជំនាញនីមួយៗ"*

ក្រុមការងារជំនាញ

**ការឆ្លើយតបចំពោះករណីជួញដូរមនុស្សទាន់ពេលវេលា៖** គ.ខ.ប.ជ. ត្រូវបានរាយការណ៍ថា បានឆ្លើយតបទាន់ពេលវេលាចំពោះករណីជួញដូរមនុស្ស។ គ.ខ.ប.ជ. សហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីអនុវត្តច្បាប់ និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដែលជាអ្នកផ្តល់សេវាក្នុងការឆ្លើយតបចំពោះករណីនានា។ ក្រុមតេឡេក្រាមត្រូវបានបង្កើតឡើងជាមធ្យោបាយសម្រាប់ទំនាក់ទំនងឱ្យបានឆាប់រហ័ស រវាងអ្នកផ្តល់សេវា និង គ.ខ.ប.ជ.។

### *៣.២.១.៤ ក្រុមការងារជំនាញ*

**កិច្ចសហការ៖** ក្រុមការងារជំនាញមួយចំនួនបានលើកឡើងថាបានធ្វើការយ៉ាងជិតស្និតជាមួយ គ.ជ.ប.ជ. ព្រមទាំងក្រុមការងារជំនាញផ្សេងទៀត។ ឧទាហរណ៍ ក្រុមការងារជំនាញអនុវត្តច្បាប់ និងក្រុមការងារការពារជនរងគ្រោះបានរាយការណ៍ថា បានសហការគ្នាបានយ៉ាងល្អ ដើម្បីជួយដល់ជនរងគ្រោះនៅក្នុងប្រព័ន្ធច្បាប់។ កិច្ចសហការនេះត្រូវបានអ្នកឆ្លើយតបរៀបរាប់ថាមានសារៈសំខាន់ ដើម្បីធានាឱ្យជនរងគ្រោះ ឬអ្នករស់រានពីអំពើជួញដូរមនុស្ស ទទួលបានសេវាគាំទ្រដែលពួកគេត្រូវការ ដើម្បីបានធូរស្បើយពីវិបត្តិផ្សេងៗ និងទទួលបានការគាំទ្រ សម្រាប់ដំណើរការផ្លូវច្បាប់។ ពុំមានអ្នកមកពីក្រុមការងារការពារជនរងគ្រោះ ឬក្រុមការងារអនុវត្តច្បាប់ ដែលអាចផ្តល់ការគាំទ្រដែលជនរងគ្រោះត្រូវការបានឡើយ ប្រសិនបើមិនមានការសហការគ្នាល្អរវាងក្រុមទាំងពីរនេះ។

*"គ.ជ.ប.ជ. និង គ.ខ.ប.ជ. ពុំមានធនធានគ្រប់គ្រាន់សម្រាប់ធ្វើការងារឡើយ។ ពុំមានថវិកាជាតិគ្រប់គ្រាន់នោះឡើយ"*

អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ

**ទំនាក់ទំនងជាមួយសមាជិកក្រុមការងារជំនាញ៖** មានការលើកឡើងថាក្រុមការងារជំនាញ គឺជាកន្លែងដ៏ល្អសម្រាប់ចែករំលែកព័ត៌មានអំពីហានិភ័យនៃករណីជួញដូរមនុស្ស ព្រមទាំងសកម្មភាព និងអាទិភាពនានា។

**ជំនាញសម្រាប់អាទិភាពរបស់ក្រុមការងារជំនាញ៖** ដោយសារតែក្រុមការងារជំនាញដឹកនាំដោយក្រសួងស្ថាប័នពាក់ព័ន្ធ ជាទូទៅក្រុមការងារជំនាញទាំងនេះត្រូវបានរាយការណ៍ថា មានចំណេះដឹងឯកទេសពាក់ព័ន្ធនឹង អាទិភាពការងាររបស់ក្រុមការងារជំនាញនីមួយៗ។

## ៣.២.២ បញ្ហាប្រឈមនៃយន្តការ

### *៣.២.២.១ ស្ថានភាពជារួម*

> *"យើងធ្វើអ្វីដែលយើងអាចធ្វើបាន ជាមួយថវិកាដែលយើងមាន"*
>
> គ.ខ.ប.ជ.

**ផែនការការងារមិនគ្រប់គ្រាន់៖** មានការកត់សម្គាល់ឃើញថា ចំនួន និងគុណភាពនៃផែនការការងារមានភាពល្អប្រសើរជាងមុនចាប់តាំងពីការវាយតម្លៃពាក់កណ្តាលអាណត្តិចុងក្រោយ លើផែនការសកម្មភាពជាតិកន្លងមក។ ទោះជាយ៉ាងណាក៏ដោយ ជារួម ចំណុចនេះនៅតែជាចំណុចដែលត្រូវបន្តធ្វើការកែលម្អបន្ថែម។

អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួន មកពីក្រុមការងារជំនាញ គ.ខ.ប.ជ. និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ពុំបានដឹងពេញលេញពីយុទ្ធសាស្រ្តចង្អោមសកម្មភាព ឬសូចនាករនៅក្នុងផែនការសកម្មភាពជាតិនេះនៅឡើយ។ នេះទំនងជាបណ្តាលមកពី ការផ្សព្វផ្សាយ និងតម្រង់ទិសអំពីផែនការនេះ នៅមានកម្រិត ជាពិសេសដោយសារផលប៉ះពាល់នៃជំងឺកូវីដ១៩។

**ធនធានមិនគ្រប់គ្រាន់៖** ទាំង គ.ជ.ប.ជ. ទាំង គ.ខ.ប.ជ. សុទ្ធតែត្រូវបានរាយការណ៍ថាពុំមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ដើម្បីធ្វើការងារឱ្យមានប្រសិទ្ធភាពទៅតាមអ្វីដែលគេអាចធ្វើបាននោះឡើយ។

ធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ មានទំនាក់ទំនងជាមួយនឹងកង្វះថវិកាថ្នាក់ជាតិ ។ អ្នកឆ្លើយតបមួយចំនួនបានលើកឡើងថា បើទោះជាថវិកាមិនគ្រប់គ្រាន់មុនពេលមានជំងឺកូវីដ១៩ ក៏ដោយ ធនធានហិរញ្ញវត្ថុរឹតតែត្រូវបានកាត់បន្ថយបន្ថែមទៀត ព្រោះតែការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះជំងឺកូវីដ១៩ ទទួលបានអាទិភាពខ្ពស់ជាង។

> *"យើងត្រូវការកិច្ចសហប្រតិបត្តិការរឹងមាំរវាងក្រុមការងារជំនាញ ដើម្បីឱ្យមានអភិក្រមរួមតែមួយ -- ដើម្បីបញ្ចៀសកុំឱ្យក្រុមការងារនីមួយៗ ធ្វើការដាច់ដោយឡែកពីគ្នា"*
>
> ក្រុមការងារជំនាញផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិ

អ្នកតបសម្ភាសក៏បានការលើកឡើងពីធនធានមនុស្សដែលនៅមានកំណត់ផងដែរ។ កត្តាថវិកាដាក់កំហិតលើលទ្ធភាពជួលបុគ្គលិកឱ្យបានគ្រប់គ្រាន់ ហើយលើសពីនេះទៀត ការផ្លាស់ប្តូរបុគ្គលិកចេញចូល ក៏មានកម្រិតខ្ពស់នៅតាមវិស័យមួយចំនួនផងដែរ។

**សមត្ថភាពមិនគ្រប់គ្រាន់៖** គ.ជ.ប.ជ. គ.ខ.ប.ជ. និងក្រុមការងារជំនាញ បានទទួលការវាយតម្លៃខ្ពស់ចំពោះការបំពេញការងាររបស់ពួកគេ។ ប៉ុន្តែក្នុងពេលជាមួយគ្នាមានការកត់សម្គាល់ថា បុគ្គលិក ឬសមាជិកជាច្រើនរបស់ គ.ជ.ប.ជ. គ.ខ.ប.ជ. និងក្រុមការងារជំនាញ នឹងអាចទទួលបាន

ប្រយោជន៍ពីការបន្តបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីឱ្យពួកគេអាចមានសមត្ថភាពបំពេញតួនាទីរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។ ការអភិវឌ្ឍសមត្ថភាព ចាំបាច់ត្រូវផ្តោតលើជំនាញបច្ចេកទេស និងមុខងាររដ្ឋបាលផងដែរ។ ឧទាហរណ៍ មន្ត្រីដែលទទួលខុសត្រូវលើការរាយការណ៍ពីករណីជួញដូរមនុស្ស ពុំបានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្លូវការ អំពីរបៀបធ្វើរបាយការណ៍ស្តីពីសកម្មភាពពាក់ព័ន្ធនានានោះឡើយ។ លើសពីនេះ ក៏ពុំមានឯកសារគោលការណ៍ការណែនាំជាក់លាក់ អំពីរបៀបរៀបចំរបាយការណ៍នោះដែរ។

> "យើងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារអនុវត្តច្បាប់ ដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះ និងអ្នកដែលរួចរស់ពីអំពើជួញដូរមនុស្សក្នុងដំណើរការច្បាប់" (ប្រសិនបើពុំមានកិច្ចសហប្រតិបត្តិការឱ្យបានល្អរវាងក្រុមការងារទាំងនេះនោះទេ នោះការផ្តន្ទាទោសជនល្មើសនឹងរឹតតែពិបាក)
>
> ក្រុមការងារជំនាញការពារជនរងគ្រោះ

**តម្រូវការចាំបាច់ក្នុងការបង្កើនចំណេះដឹង៖** បន្ថែមលើចំណេះដឹងបច្ចេកទេស ដើម្បីបំពេញតួនាទីរបស់ខ្លួន ក៏នៅមានភាពខ្វះចន្លោះក្នុងការយល់ដឹងអំពីទម្រង់ ឬហានិភ័យថ្មីៗនៃអំពើជួញដូរមនុស្សនានា ដូចជា បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ការពពោះជំនួស និងបទល្មើសផ្សេងៗទៀតជាដើម។

**តួនាទីត្រួតត្រាវាង គ.ជ.ប.ជ. ក្រុមការងារជំនាញ និងក្រសួងស្ថាប័ននានា៖** មានការលើកឡើងពីការធ្វើការត្រួតត្រាវាង គ.ជ.ប.ជ. ក្រុមការងារជំនាញ និងក្រសួងស្ថាប័នជំនាញ ក្នុងសកម្មភាពសំខាន់ៗពាក់ព័ន្ធនឹងការងារប្រឆាំងអំពើជួញដូរមនុស្ស។ សកម្មភាពទាំងនេះត្រូវបានលើកឡើងថា ចាំបាច់ត្រូវមានការបញ្ជាក់ឡើងវិញឱ្យបានច្បាស់លាស់។

អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួនសង្កេតឃើញថា ពុំមានការកំណត់បញ្ជាក់ឱ្យបានច្បាស់លាស់ ថាតើនរណាជាអ្នកចុះហត្ថលេខាលើអនុស្សរណៈ (MOUs) នោះឡើយ។ ក្នុងករណីមួយចំនួន អនុស្សរណៈត្រូវបានចុះហត្ថលេខាដោយ គ.ជ.ប.ជ. ហើយក្នុងករណីមួយចំនួនផ្សេងទៀត ត្រូវបានចុះហត្ថលេខាដោយក្រសួងស្ថាប័នជំនាញផ្សេងៗទៀតទៅវិញ។ ក្រោយពេលចុះអនុស្សរណៈរួច ក៏មានភាពខ្វះចន្លោះក្នុងការរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តអនុស្សរណៈនេះផងដែរ។

> "បុគ្គលិកមួយចំនួនពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធ្វើការងាររបស់ពួកគេនោះឡើយ"
>
> អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ

ឧទាហរណ៍ផ្សេងទៀតរួមមានតួនាទីឆ្លើយតប ឬគ្រប់គ្រងបញ្ហាមួយចំនួន ដូចជាបញ្ហាទេសន្តរប្រវេសន៍ជាដើម។

តួនាទីរបស់ក្រុមការងារជំនាញ និងតួនាទីរបស់ក្រសួង-ស្ថាប័ន ពុំត្រូវបានបែងចែកឱ្យដាច់ពីគ្នានោះឡើយ ដែលនាំឱ្យមានការភាន់ច្រឡំ។

**ចំណុចខ្វះខាតពាក់ព័ន្ធនឹងការសម្របសម្រួលរវាងក្រុមការងារជំនាញ៖** ខណៈពេលដែលមានការលើកឡើងនូវឧទាហរណ៍ជាច្រើន បង្ហាញពីការសម្របសម្រួលយ៉ាងល្អ និងការសហការគ្នារវាងក្រុមការងារជំនាញ ដើម្បីសម្រេចគោលដៅរួម ក៏មានការលើកឡើងផងដែរថា នៅក្នុងករណីមួយចំនួន ក្រុមនីមួយៗធ្វើការដាច់ដោយឡែកពីគ្នា។

សមាជិកសំខាន់ៗមួយចំនួនរបស់ក្រុមការងារទទួលស្គាល់ថាមានឧបសគ្គមួយចំនួន ក្នុងការធ្វើការរួមគ្នាជាមួយក្រុមការងារដទៃទៀត ព្រោះតែពេលវេលា និងកិច្ចការអាទិភាពដែលក្រសួងស្ថាប័នរបស់ពួកគេបានចាត់ឱ្យបំពេញ។

ផែនការយុទ្ធសាស្ត្រនេះ ផ្តល់ការណែនាំឱ្យក្រុមការងារជំនាញធ្វើការរួមគ្នា ប៉ុន្តែនៅក្នុងករណីមួយចំនួន អាទិភាពរបស់ក្រសួងស្ថាប័ន ធ្វើឱ្យការសម្របសម្រួលពុំអាចប្រព្រឹត្តទៅបានរលូនគ្រប់គ្រាន់ជាមួយក្រុមការងារជំនាញផ្សេងទៀតឡើយ។

**ការសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ៖** អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិរាយការណ៍ថាការសម្របសម្រួលជាមួយ គ.ជ.ប.ជ. និងគ.ខ.ប.ជ. គឺជាចំណុចខ្លាំងមួយ។ ទោះជាយ៉ាងណាក៏ដោយមានការលើកឡើងថា ពួកគេមិនសូវមានឱកាសផ្តល់ជាតុចូលនៅកម្រិតក្រុមការងារជំនាញឡើយ។ អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ មិនមែនសុទ្ធតែអាចចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារជំនាញនោះទេ ដូច្នេះកិច្ចសហប្រតិបត្តិការនៅមានភាពខ្វះចន្លោះ។

> *"ចាប់តាំងពីការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ចាប់ផ្តើមកើតមានឡើង យើងត្រូវធ្វើការងារទ្វេដង ដើម្បីទប់ស្កាត់ករណីជួញដូរមនុស្សផង និងឆ្លើយតបចំពោះហានិភ័យនៃជំងឺកូវីដ១៩ ផង"*
> លេខាធិការដ្ឋាន គ.ជ.ប.ជ.

## ៣.៣ ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

ការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ គឺជាវិបត្តិមួយក្នុងចំណោមវិបត្តិធំៗជាងគេ ដែលបណ្តាលឱ្យមានអស្ថេរភាពក្នុងសកលលោក បង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។ វិបត្តិនេះរឹតតែបង្កផលប៉ះពាល់ធ្ងន់ធ្ងរកាន់តែខ្លាំងដល់សមាជិកនៃក្រុមសង្គម ដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះជាងគេ ធ្វើឱ្យពួកគេរឹតតែប្រឈមនឹងហានិភ័យនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច។ ដូចគ្នានឹងប្រទេសដទៃទៀតនៅក្នុងពិភពលោកដែរ កម្ពុជាកំពុងស្ថិតនៅក្នុងសមរភូមិទប់ទល់នឹងការរាតត្បាតជាសកលនេះ គិតមកដល់ដើមឆ្នាំ២០២១ កម្ពុជាមានករណីកូវីដ១៩ តិចតួចប៉ុណ្ណោះ ប៉ុន្តែរងផលប៉ះពាល់ជាចម្បង ដោយសារការបិទព្រំដែន សម្ពាធសេដ្ឋកិច្ច ដោយសារការបាត់បង់ចំណូលក្នុងវិស័យទេសចរណ៍ ការបិទរោងចក្រ និងរំហូរចូលយ៉ាងគំហុកនៃពលករ

*"កាលពីមុន យើងជួបគ្នាផ្ទាល់ ដើម្បីពិភាក្សា និងចែករំលែកព័ត៌មាន។ ឥឡូវនេះយ៉ាងអាចធ្វើបានតែតាមអនឡាញប៉ុណ្ណោះ។ កម្រិតនៃការយកចិត្តទុកដាក់មិនដូចគ្នានោះឡើយ"*
ក្រុមការងារជំនាញ

ទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍។ ក្នុងត្រីមាសទី១ ឆ្នាំ២០២១ នៅកម្ពុជាមានការកើនឡើងយ៉ាងគំហុកនៃករណីកូវីដ១៩ ដោយសារការឆ្លងក្នុងសហគមន៍[1] ដែលធ្វើឱ្យបញ្ហាសេដ្ឋកិច្ចរឹតតែធ្ងន់ធ្ងរ និងដាក់សម្ពាធមកលើមន្ត្រីរដ្ឋាភិបាល ដែលត្រូវឆ្លើយតបចំពោះវិបត្តិនេះ។

មានការលើកឡើងថា ដោយសារការរាតត្បាតជាសកល នៃជំងឺកូវីដ១៩ ហានិភ័យនៃការជួញដូរមនុស្សមានការផ្លាស់ប្តូរ។ ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានចាត់ទុកថាងាយរងគ្រោះខ្លាំង ព្រោះតែហានិភ័យថ្មីៗនៃអំពើជួញដូរមនុស្ស។

ជារឿយៗ ពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ពុំមានលទ្ធភាពបន្តទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេឱ្យគាប់ប្រសើរឡើយ បន្ទាប់ពីពួកគេវិលត្រឡប់មកវិញ ព្រោះពួកគេពុំមានការងារធ្វើ ឬមានការងារធ្វើមិនគ្រប់គ្រាន់ ដែលធ្វើឱ្យពួកគេរកចំណូលបានតិចជាងមុន និងកាន់តែងាយរងគ្រោះជាងមុន ដោយអំពើជួញដូរមនុស្ស។ អ្នកផ្តល់ព័ត៌មានសំខាន់ៗលើកឡើងថា ការបិទព្រំដែនដោយសារជំងឺកូវីដ១៩ មិនបានបញ្ឈប់ពលករទេសន្តរប្រវេសន៍មិនឱ្យឆ្លងដែនក្រៅផ្លូវការ (ខុសច្បាប់) ទៅប្រទេសជិតខាង ដើម្បីស្វែងរកការងារធ្វើនោះឡើយ ដែលការណ៍នេះធ្វើឱ្យពួកគេរឹតតែងាយរងការរំលោភបំពានពីសំណាក់មេខ្យល់។

គ.ខ.ប.ជ. និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ត្រូវបានស្នើឱ្យផ្តល់សេវានៅតាមបណ្តោយព្រំដែនដូចជាចាំទទួលពលករទេសន្តរប្រវេសន៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ ផ្តល់សេវាពិនិត្យសុខភាពជាមូលដ្ឋាន ផ្តល់ស្បៀង និងការគាំទ្រដល់ពលករទេសន្តរប្រវេសន៍ ដើម្បីពួកគេអាចវិលត្រឡប់ទៅកាន់សហគមន៍របស់ពួកគេវិញ។

លើសពីនេះក៏នៅមានហានិភ័យដោយអំពើជួញដូរមនុស្ស ពាក់ព័ន្ធនឹងការពពោះជំនួសផងដែរ បើទោះបីមានការលើកឡើងមួយចំនួនថា ការរៀបអាពាហ៍ពិពាហ៍បែបបោកបញ្ឆោត ត្រូវបានប្រើប្រាស់ជាវនាំងដើម្បីគេចវេះពីច្បាប់ និងបញ្ញត្តិផ្សេងៗ ពាក់ព័ន្ធនឹងការពពោះជំនួសក៏ដោយ។ ការណ៍នេះកើតឡើង គួបផ្សំនឹងការបន្តកើតមាននូវហានិភ័យនៃអំពើជួញដូរមនុស្ស ដូចជា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម បង្ខំឱ្យធ្វើជាអ្នកសុំទាន (មនុស្សពេញវ័យ និងកុមារ) ការមិនបំពេញតាមការសន្យាក្នុងការផ្តល់ការងារឱ្យធ្វើបន្ទាប់ពីពលករបានធ្វើទេសន្តរប្រវេសន៍រួច និងការជួញដូរឱ្យទៅធ្វើការលើទូកនេសាទជាដើម។ ការរំលោភបំពានតាមប្រព័ន្ធ

[1] ពី ៥០០ ករណី នៃកូវីដ១៩ នៅពេលចាប់ផ្តល់មានការរាតត្បាតជាសកល មកទល់នឹងខែមីនា ឆ្នាំ២០២១ (១៤ ខែ)។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ចំនួនករណីកើតឡើងជិត ១២០.000 ក្នុងរយៈពេល ៦ខែ ចាប់តាំងពីខែមីនា ឆ្នាំ ២០២១ មក។

អនឡាញក៏ក្លាយជាបញ្ហាធំទៅៗផងដែរ។[2] ហានិភ័យទាំងនេះរឹតតែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត ដោយសារជំងឺកូវីដ១៩ ព្រោះអាជ្ញាធរពាក់ព័ន្ធចាត់ទុកបញ្ហាសុខភាព និងសុវត្ថិភាពជាអាទិភាព ហើយក្នុងពេលទន្ទឹមគ្នានេះសម្ពាធសេដ្ឋកិច្ចមកលើក្រុមគ្រួសារក៏រឹតតែមានការកើនឡើង។

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងការងាររបស់ គ.ជ.ប.ជ. គ.ខ.ប.ជ. និងក្រុមការងារជំនាញសុទ្ធតែរងផលប៉ះពាល់។ មានការរាយការណ៍ថា សកម្មភាពដែលបានគ្រោងទុក ពុំត្រូវបានអនុវត្តឱ្យបានពេញលេញនៅគ្រប់កម្រិតទាំងអស់នោះទេ។ កម្មវិធីជាច្រើនត្រូវបានពន្យាពេល ឬមានការកំណត់ចំនួនអ្នកចូលរួម ឬផ្លាស់ប្តូររបៀបរៀបចំ។

យន្តការចម្បងសម្រាប់រៀបចំកិច្ចប្រជុំរបស់ គ.ជ.ប.ជ. គ.ខ.ប.ជ. និងក្រុមការងារជំនាញនៅពេលនេះ គឺប្រើប្រាស់ថ្នាលបច្ចេកវិទ្យាអនឡាញ ដូចជា Zoom, Teams ឬតាមរយៈកម្មវិធីដទៃទៀត។ ថ្នាលបច្ចេកវិទ្យាទាំងនេះមានភាពល្អប្រសើរសម្រាប់ គ.ជ.ប.ជ. និង គ.ខ.ប.ជ.។ ខណៈពេលដែលមានការលើកឡើងថា ឧបករណ៍ទាំងនេះមានសារៈសំខាន់ ដើម្បីបន្តទំនាក់ទំនងរវាងគ្នា ក៏មានការលើកឡើងជាទៀងទាត់ផងដែរថា ការទំនាក់ទំនងតាមប្រព័ន្ធអនឡាញមិនមានប្រសិទ្ធភាពដូចការពិភាក្សា និងចែករំលែកព័ត៌មានតាមរយៈការជួបគ្នាដោយផ្ទាល់នោះឡើយ។

ប៉ុន្តែ គ.ខ.ប.ជ. ពិតជាបានលើកឡើងថា អ្នកចូលរួមមួយចំនួននៅបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំ Zoom ដូចជាបង្ហាញពីការអនុវត្តសកម្មភាព ដែលត្រូវបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រជាតិនេះជាដើម។ សកម្មភាពសំខាន់ៗភាគច្រើន ជាសកម្មភាពការពារខ្លួនពីជំងឺកូវីដ១៩។ បើទោះបីជាយ៉ាងណាក៏ដោយ គ.ខ.ប.ជ. មួយចំនួនពិតជាបានបញ្ជ្រាបសារគន្លឹះអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមកម្មវិធីតូចៗដែលរៀបចំសម្រាប់ចែកស្បៀង ឧបករណ៍ការពារខ្លួន និងព្រឹត្តិការណ៍អប់រំផ្សព្វផ្សាយតាមសហគមន៍ដទៃទៀត។ គ.ខ.ប.ជ. ខ្លះទៀតទទួលស្គាល់ថា ការចុះអប់រំផ្សព្វផ្សាយតាមសហគមន៍អំពីករណីជួញដូរមនុស្ស និងថវិកាដែលមានសម្រាប់ការងារនេះ ត្រូវបានកាត់បន្ថយព្រោះតែមានការផ្តល់អាទិភាពដល់ជំងឺកូវីដ១៩។

វឌ្ឍនភាពជុំវិញសកម្មភាពនានា ដូចជាកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសដទៃទៀត ក៏ត្រូវរាំងស្ទះផងដែរ ដោយសារតែមានការផ្តោតការយកចិត្តទុកដាក់លើការបង្ការ និងឆ្លើយតបចំពោះជំងឺកូវីដ១៩ នៅកម្ពុជា និងក្នុងប្រទេសដទៃទៀត នៅក្នុងតំបន់។

សកម្មភាពបង្ការទប់ស្កាត់នៅមានកម្រិត ឬត្រូវបានប្តូរទៅប្រើប្រាស់វេទិកាផ្សេងៗ ដូចជា វិទ្យុ ទូរទស្សន៍ ហ្វេសប៊ុក ឬបណ្តាញទំនាក់ទំនងសង្គមដទៃទៀត។ កិច្ចប្រជុំសហគមន៍ ដែលផ្តោតលើសកម្មភាពបង្ការទប់ស្កាត់ ជាមួយប្រជាពលរដ្ឋក្នុងចំនួនច្រើនដែលធ្លាប់តែអាចធ្វើបានមុនពេលមានការរាតត្បាតជាសកល

[2] កំណត់សម្គាល់ដកស្រង់ចេញពីសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនការយុទ្ធសាស្ត្រជាតិ ដែលរៀបចំដោយ គ.ជ.ប.ជ. កាលពីខែកក្កដា ឆ្នាំ២០២១។

នៃជំងឺកូវីដ១៩ មិនអាចរៀបចំបានដូចមុនទៀតឡើយ។ ជារឿយៗមន្ត្រីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ តែងធ្វើការពីផ្ទះ និងមិនអាចចុះទៅដល់សហគមន៍ដោយផ្ទាល់នោះទេ។

ការឆ្លើយតបចំពោះជនរងគ្រោះក៏រងផលប៉ះពាល់ផងដែរ។ ការធ្វើសមាហរណកម្មទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័ននានា អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ និងអាជ្ញាធរមូលដ្ឋាន។ ការរឹតត្បិតលើការធ្វើដំណើរ ការប្តូរអាទិភាពនៃពេលវេលារបស់បុគ្គលិក ឱ្យឆ្លើយតបចំពោះជំងឺកូវីដ១៩ សុទ្ធតែ បណ្តាលឱ្យការជួយជនរងគ្រោះមានសភាពយឺតយ៉ាវជាងមុន។ ការចុះទៅសហគមន៍ដើម្បីធ្វើការងារផ្ទាល់ជាមួយជនរងគ្រោះ ក៏មិនអាចធ្វើបានជានិច្ចនោះដែរ។

អ្វីដែលសំខាន់នោះ គឺការយកចិត្តទុកដាក់លើការបង្ការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើជួញដូរមនុស្សនៅតែជាអាទិភាព។ អាជ្ញាធរពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ និងតួអង្គសំខាន់ៗដទៃទៀតនៅគ្រប់កម្រិតទាំងអស់បានរិះរកវិធីកែសម្រួលរបៀបធ្វើការរបស់ខ្លួន បើទោះជាពួកគេភាគច្រើនសារភាពថា កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនមានប្រសិទ្ធភាពដូចមុនក៏ដោយ។ ការរៀបចំរបាយការណ៍នៅតែបន្តធ្វើ ហើយកិច្ចប្រជុំបានប្តូរទៅជាកិច្ចប្រជុំតាមប្រព័ន្ធអនឡាញវិញ។ ការពិភាក្សាផ្សេងទៀតក៏កើតមានផងដែរ ដូចជា របៀបគ្រប់គ្រងកិច្ចប្រជុំ និងការទំនាក់ទំនងការងារនាពេលអនាគត ដោយសារតែការបន្តជួបនឹងបញ្ហាប្រឈមផ្សេងៗ ដែលបណ្តាលមកពីការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ។ ចំណុចសំខាន់គឺត្រូវសម្របខ្លួន ដូចជា តាមរយៈការរៀបចំកិច្ចប្រជុំក្រុមតូច ឬការចុះជួបប្រជាពលរដ្ឋតាមផ្ទះ ដោយមានការជួយគាំទ្រពីអាជ្ញាធរភូមិ ដើម្បីអាចផ្សព្វផ្សាយសារអប់រំផ្ទាល់ជូនប្រជាពលរដ្ឋបាន។

## ៣.៤ ការអនុវត្ត និងការសម្រេចតាមចំណុចដៅដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រ

ក្នុងផ្នែកនេះ មានការរាយការណ៍ជូនពីការអនុវត្ត និងការសម្រេចគោលដៅតាមយុទ្ធសាស្ត្រនីមួយៗ។ ទីមួយគឺជាតារាងយុទ្ធសាស្ត្រ រួមនឹងចង្កោមសកម្មភាពកម្រិតខ្ពស់ ព្រមទាំងសូចនាករដែលយកចេញពីផែនការយុទ្ធសាស្ត្រនេះ។ ក្រុមការងារវាយតម្លៃបានពិនិត្យលើរបាយការណ៍របស់ គ.ជ.ប.ជ. និងបានសាកសួរទៅកាន់អ្នកផ្តល់ព័ត៌មានសំខាន់ៗអំពីវឌ្ឍនភាពដែលសម្រេចបានដើម្បីព្យាយាមស្វែងយល់ពីវឌ្ឍនភាពនានា។

ជាទូទៅទិន្នន័យដែលមាន គឺជាទិន្នន័យដែលមានលក្ខណៈទូទៅ និងផ្សារភ្ជាប់ដាក់លាក់ជាមួយនឹងសូចនាករនីមួយៗ។ ឧទាហរណ៍ របាយការណ៍ទាំងនេះពុំបានបញ្ចូលកាលបរិច្ឆេទសកម្មភាព ឬព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីអាចរាយការណ៍ឱ្យបានច្បាស់លាស់ធៀបនឹងសូចនាករទាំងនោះឡើយ។ នៅពេលដែលទិន្នន័យទទួលបានពីរបាយការណ៍ណាមួយ (ក្រៅពីការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ) នឹងមានការលើកឡើងពីប្រភពឯកសារនោះ។

### ៣.៤.១ យុទ្ធសាស្ត្រទី ១៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

| ចង្កោមសកម្មភាព | សូចនាករ |
|---|---|
| ១.១ រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិប្រចាំឆ្នាំ និងពង្រឹងយន្តការ | • ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពត្រូវបានបង្កើតឡើង<br>• រចនាសម្ព័ន្ធ និងយន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានពង្រឹង និងកែលម្អ |
| ១.២ ពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាពអង្គភាព ស្ថាប័ន និងអង្គការដៃគូអនុវត្ត | របៀបរបបការងារត្រូវបានពង្រឹង៖<br>• កិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ<br>• របាយការណ៍កិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំត្រូវបានផលិត<br>• មន្ត្រីលេខាធិការដ្ឋាន គ.រ.ប.ជ. គ.ខ.ប.ជ. ទទួលបានការបណ្តុះបណ្តាល<br>• មន្ត្រីនគរបាលយុត្តិធម៌ទទួលបានការបណ្តុះបណ្តាលជំនាញ ក្បួន នីតិវិធីប្រតិបត្តិ |
| ១.៣ ការប្រមូលចងក្រង និងកសាងប្រព័ន្ធទិន្នន័យ ដើម្បីជាមូលដ្ឋាននៃការវិភាគលើកទិសដៅ អនុវត្តផ្សព្វផ្សាយ និងផ្លាស់ប្តូរជាមួយប្រទេសពាក់ព័ន្ធ | • យន្តការក្នុងការប្រមូលចងក្រង គ្រប់គ្រង និងផ្លាស់ប្តូរទិន្នន័យត្រូវបានបង្កើត និងដំណើរការជាប្រព័ន្ធ<br>• កិច្ចសហការរវាងអាជ្ញាធរ និងសមត្ថកិច្ច នៃបណ្តាប្រទេសពាក់ព័ន្ធ និងអន្តរជាតិ ត្រូវបានពង្រឹង និងបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការ<br>• របាយការណ៍បង្ក្រាបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំត្រូវបានផលិត<br>• របាយការណ៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សប្រចាំខែ ត្រីមាស និងឆ្នាំត្រូវបានផលិត |
| ១.៤ កសាងបទដ្ឋានគតិយុត្ត និងអនុស្សរណៈ កិច្ចព្រមព្រៀង និងស្តង់ដារនីតិវិធីប្រតិបត្តិនានាជាមួយបណ្តាប្រទេសពាក់ព័ន្ធ | • បង្កើត និងជំរុញឱ្យមានកិច្ចព្រមព្រៀង អនុវត្តសកម្មភាពបង្ការទប់ស្កាត់ អនុវត្តច្បាប់ និងជួយជនរងគ្រោះជាមួយប្រទេសពាក់ព័ន្ធ |
| ១.៥ ពង្រឹងកិច្ចសហប្រតិបត្តិការ និងសមត្ថភាពជំនាញ ជាមួយប្រទេសពាក់ព័ន្ធ និងជាអន្តរជាតិ ដើម្បីបង្ការទប់ស្កាត់ បង្ក្រាបអំពើជួញដូរមនុស្សឆ្លងដែន ផ្តល់អន្តរាគមន៍ជួយជនរងគ្រោះ និងជំរុញការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី | • អនុស្សរណៈកិច្ចព្រមព្រៀងត្រូវបានអនុវត្ត<br>• បញ្ហាប្រឈមក្នុងការអនុវត្តត្រូវបានរកឃើញ និងដោះស្រាយ<br>• កិច្ចប្រជុំទ្វេភាគី ពហុភាគី ត្រូវបានរៀបចំទៀងទាត់ |

| | |
|---|---|
| **១.៦ ធ្វើវិសោធនកម្ម ឬ/និងរៀបចំសេចក្ដីព្រាងច្បាប់ និងគោលនយោបាយជាតិ ឆ្លើយតបទៅនឹងបញ្ហាថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស** | • ឯកសារបទដ្ឋានគតិយុត្តត្រូវបានកែលម្អ សម្រាប់ជាជំនួយដល់ការអនុវត្ត<br>• ច្បាប់ និងគោលនយោបាយថ្មីៗ ត្រូវបានបង្កើតឡើង សម្រាប់អនុវត្តឆ្លើយតបទៅនឹងសេចក្ដីត្រូវការ |

*៣.៤.១.១ វឌ្ឍនភាព*

យុទ្ធសាស្ត្រទី១ ផ្ដោតលើការពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងការអនុវត្តច្បាប់ គោលនយោបាយ និងស្តង់ដារគតិយុត្ត។ សកម្មភាពក្នុងយុទ្ធសាស្ត្រនេះ ត្រូវបានអនុវត្តក្រោមការដឹកនាំនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ក្រុមការងារទំនាក់ទំនងអន្តរជាតិដែលដឹកនាំដោយក្រសួងកិច្ចការនារី និងមានការចូលរួមចំណែកពីក្រុមការងារដទៃទៀត។ យុទ្ធសាស្ត្រនេះមានចង្កោមសកម្មភាពចំនួន ៦ អមនឹងសូចនាករពាក់ព័ន្ធ (សូមមើលតារាងខាងលើ)។ ខាងក្រោមនេះ គឺការបង្ហាញដោយសង្ខេបពីវឌ្ឍនភាពនៃចង្កោមសកម្មភាពទាំងនេះ ដែលបានពីឯកសារផ្សេងៗ។ សកម្មភាពផ្សេងៗមួយចំនួនក្រៅពីនេះទៀត ដែលមិនត្រូវបានប្រមូលចងក្រងក្នុងរបាយការណ៍នានា និងដឹងតាមរយៈការសម្ភាស ក៏ទំនងជាបានកើតឡើងដែរ។

១.១ រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រចាំឆ្នាំ និងពង្រឹងយន្តការ៖

- ផែនការយុទ្ធសាស្ត្រជាតិត្រូវបានរៀបចំឡើង សម្រាប់ឆ្នាំ ២០១៩ - ២០២៣។ ផែនការយុទ្ធសាស្ត្រជាតិនេះ ផ្ដល់ការណែនាំតម្រង់ទិសអំពីអាទិភាពការងាររបស់ក្រុមការងារជំនាញ និង គ.រ/ខ.ប.ជ. នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- នៅកម្រិតក្រុមការងារជំនាញ ក្រុមការងាររាយការណ៍ថា ពួកគេបានរៀបចំផែនការការងាររៀងៗខ្លួន ឬបានបញ្ចូលអាទិភាពនៃផែនការការងាររបស់ពួកគេទៅក្នុងផែនការយុទ្ធសាស្ត្រជាតិ។ ក្រុមការងារទាំងអស់សុទ្ធតែលើកឡើងថា មានផែនការនៅកម្រិតមួយចំនួន ប៉ុន្តែគេមិនច្បាស់ទេថាតើ ផែនការទាំងនោះ គឺជាផែនការដាច់ដោយឡែកទាំងស្រុងពីផែនការជាតិ ឬជារបាយការណ៍ទូទៅអំពីការអនុវត្តអាទិភាពការងារដែលពាក់ព័ន្ធសម្រាប់ក្រុមការងារជំនាញរបស់ពួកគេ។

- នៅកម្រិត គ.ខ.ប.ជ. លេខាធិការដ្ឋាន គ.ខ.ប.ជ. ភាគច្រើនបានដឹងពីផែនការយុទ្ធសាស្ត្រជាតិ និងដឹងថាពួកគេត្រូវអនុវត្តតាមអាទិភាពរៀងខ្លួន។ ក្នុងខេត្តដែលសកម្ម ដូចជាខេត្តសៀមរាបជាដើម គ.ខ.ប.ជ. បានរៀបចំផែនការការងាររបស់ខ្លួន ដោយបានដាក់ចេញនូវអាទិភាពសម្រាប់ខេត្ត។ ចំណុចនេះត្រូវបានចាត់ទុកថាជាការអនុវត្តដ៏ល្អមួយ។

- បើទោះជាផែនការការងារទើបត្រូវបានចាប់ផ្ដើមរៀបចំក៏ដោយ ផែនការការងារទាំងនេះ ពុំទាន់ត្រូវបានរៀបចំឱ្យបានពេញលេញ ក្នុងគ្រប់ក្រុមការងារជំនាញ និងគ.ខ.ប.ជ. ទាំងអស់ឡើយ ហើយនេះគឺជាចំណុចដែលត្រូវធ្វើការកែលម្អបន្ថែមទៀត។

- យន្តការជាតិមានក្របខ័ណ្ឌរឹងមាំ និងមានរចនាសម្ព័ន្ធសមស្រប ក្នុងការឆ្លើយតបចំពោះអំពើជួញដូរមនុស្ស។

១.២ ពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាព អង្គភាព ស្ថាប័ន និងអង្គការដៃគូអនុវត្ត៖

- មុនពេលមានការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ គ.ខ.ប.ជ. និង ក្រុមការងារជំនាញភាគច្រើន រៀបចំកិច្ចប្រជុំយ៉ាងទៀងទាត់។ កិច្ចប្រជុំដែលរៀបចំញឹកញាប់ជាងគេ រួមមានកិច្ចប្រជុំរៀងរាល់ ៣ខែ ប្រចាំឆមាស និងប្រចាំឆ្នាំ។ គ.ខ.ប.ជ. មួយចំនួន និងគ.ជ.ប.ជ. បានផ្លាស់ប្តូរការរៀបចំកិច្ចប្រជុំ ដោយប្រើប្រាស់ប្រព័ន្ធអនឡាញ ដូចជា Zoom វិញព្រោះមានការដាក់កំហិតលើកាជួបប្រជុំគ្នាដោយផ្ទាល់។ កិច្ចប្រជុំទាំងនេះផ្តោតលើការចែករំលែកព័ត៌មាន និងការរាយការណ៍។

  ដូចបង្ហាញពីខាងដើម កិច្ចប្រជុំតាមថ្នាលបច្ចេកវិទ្យាអនឡាញ មិនត្រូវបានគេចាត់ទុកថាមានប្រសិទ្ធភាព ដូចកិច្ចប្រជុំដែលមានការចូលរួមផ្ទាល់នៅនឹងកន្លែងនោះឡើយ។

- គ.ជ.ប.ជ. បានដឹកនាំសិក្ខាសាលាពិគ្រោះយោបល់ ២ លើក ស្តីពី "វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំឆ្នាំរបស់សហរដ្ឋអាមេរិក និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាប្រឆាំងអំពើជួញដូរមនុស្ស" ដែលមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ព្រមទាំងសហការីរបស់លោក (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ.)។

១.៣ ការប្រមូលចងក្រង និងកសាងប្រព័ន្ធទិន្នន័យ ដើម្បីជាមូលដ្ឋាននៃការវិភាគលើកទិសដៅអនុវត្ត ផ្សព្វផ្សាយ និងផ្លាស់ប្តូរជាមួយប្រទេសពាក់ព័ន្ធ៖

- ក្រុមការងារជំនាញនីមួយៗ ត្រូវរាយការណ៍ពីសកម្មភាពរបស់ខ្លួន ព្រមទាំងវឌ្ឍនភាពដែលសម្រេចបាន ជូនលេខាធិការដ្ឋាននៃ គ.ជ.ប.ជ. នៅថ្នាក់ជាតិ និងគ.ខ.ប.ជ. នៅថ្នាក់ក្រោមជាតិ។ ក្រុមការងារវាយតម្លៃសង្កេតឃើញថាមានការរាយការណ៍ជាប្រចាំ។ ការពិនិត្យលើរបាយការណ៍ទាំងនេះ ផ្តល់នូវព័ត៌មានដែលមានប្រយោជន៍សម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិនេះ។ ការរៀបចំរបាយការណ៍មានភាពល្អប្រសើរជាងមុន គិតចាប់តាំងពីការវាយតម្លៃពាក់កណ្តាលអាណត្តិពីលើកមុន ប៉ុន្តែនេះក៏នៅតែជា ចំណុចដែលត្រូវតែធ្វើការកែលម្អបន្ថែមទៀតផងដែរ។

> *"យើងមានផែនការការងារដែលត្រូវបានរៀបចំឡើងដើម្បីអនុវត្តផែនការយុទ្ធជាតិ"*
> ក្រុមការងារជំនាញ

> *"សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ យើងធ្វើការងារជាមួយ គ.ជ.ប.ជ. និងក្របខណ្ឌ COMMIT ព្រមទាំងយន្តការអាស៊ាន និងទីភ្នាក់ងារអង្គការសហប្រជាជាតិ"*
> ក្រសួងកិច្ចការនារី, ក្រុមការងារទំនាក់ទំនងអន្តរជាតិ

- បន្ថែមលើរបាយការណ៍ ដែលរៀបចំជាប្រចាំ ក៏មានរបាយការណ៍ពិសេសតាមជំនាញមួយចំនួន ដូចជារបាយការណ៍អំពីស្ថានភាពរបស់ពលករទេសន្តរប្រវេសន៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ជាដើម។
    - ស្នងការនគរបាលរាជធានី-ខេត្ត បានកត់ត្រាចំនួនពលករទេសន្តរប្រវេសន៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេសជារៀងរាល់ខែ ដែលក្នុងនោះមានពលករស្របច្បាប់ផង និងមិនស្របច្បាប់ផង សរុបមានចំនួន ១៥០.៨៨៥ នាក់ (ស្រី ៥៤.៥៥៦នាក់) អនីតិជន ៥៦៤ នាក់ (ស្រី ១៥៧ នាក់) (របាយការណ៍ គ.ជ.ប.ជ. ខែមិថុនា ឆ្នាំ ២០២១)។
    - លេខាធិការដ្ឋាន គ.ខ.ប.ជ. ក៏កំពុងរៀបចំរបាយការណ៍ ស្រដៀងគ្នានេះ អំពីពលករដែលបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស និងកំពុងពិនិត្យតាមដានសុខភាព ជីវភាពរស់នៅរបស់ពួកគេ និងផ្តល់ការអប់រំអំពីការបង្ការទប់ស្កាត់ និងហានិភ័យនៃការធ្វើទេសន្តរប្រវេសន៍ជាថ្មីតាមរយៈមេខ្យល់។ លេខាធិការដ្ឋាន គ.ខ.ប.ជ. បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ដើម្បីកំណត់ពីបញ្ហាប្រឈម និងតម្រូវការនានា នៅពេលធ្វើសមាហរណកម្មពលករទាំងនោះ ព្រមទាំងផ្តល់សេវាសុខភាព និងការឧបត្ថម្ភសម្រាប់ការរស់នៅផងដែរ។

១.៤ កសាងបទដ្ឋានគតិយុត្ត និងអនុស្សរណៈ កិច្ចព្រមព្រៀង និងស្តង់ដារនីតិវិធីនានាជាមួយបណ្តាប្រទេសពាក់ព័ន្ធ៖

- ក្រសួងកិច្ចការនារី បានចូលរួមយ៉ាងទៀតទាត់ជាមួយនឹងក្របខណ្ឌ គំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្ស (ហៅកាត់ថា COMMIT)។ តាមរយៈក្របខណ្ឌនេះក្រសួងមានការព្រាងធ្វើវិសោធនកម្មអនុស្សរណៈ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ក្នុងមហាតំបន់ទន្លេមេគង្គ និងមានការចាត់តាំងគ្រូបង្គោលពីប្រទេសនីមួយៗ ដែលជាសមាជិករបស់ COMMIT (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ. និងការសម្ភាសជាមួយតំណាងក្រសួងកិច្ចការនារី)។
- នីតិវិធីប្រតិបត្តិការស្តង់ដារស្តីពីការគ្រប់គ្រងករណីមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃត្រូវបានផ្សព្វផ្សាយសម្រាប់ដាក់ឱ្យអនុវត្តជាផ្លូវការដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ.)។
- គ.ជ.ប.ជ. បានសហការក្នុងក្របខណ្ឌអាស៊ាន ដើម្បីបង្កើតដំណើរការអនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ (GCM) នៅកម្រិតប្រទេស។ កម្ពុជា គឺជាប្រទេសនាំមុខគេក្នុងបញ្ជីប្រទេសរបស់អង្គការសហប្រជាជាតិ ដែលបានចូលរួមក្នុងការអនុវត្តកតិកាសញ្ញា GCM នេះ។
- សេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសបារាំងស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងប្រព័ន្ធព្រហ្មទណ្ឌ (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ.)។
- សេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសប៉េរូស្តីពីការដោះដូរទណ្ឌិត (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ.)។

- សេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគីជាមួយប្រទេសប្រជាមានិតប្រជាធិបតេយ្យឡាវស្តីពីការដោះដូរទណ្ឌិត (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- សេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការធ្វើបត្យាប័នរវាងរាជរដ្ឋាភិបាលកម្ពុជា និងសាធារណៈរដ្ឋឥណ្ឌា (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- រៀបចំសេចក្តីព្រាងយន្តការផ្ទេរឆ្លងដែន ដើម្បីធានាឱ្យមានការប្រើប្រាស់ស្តង់ដារតែមួយ សម្រាប់គ្រូបង្គោលនីមួយៗដែលបានទទួលការចាត់តាំង ពីប្រទេសជាសមាជិករបស់ COMMIT (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- បានសហការជាមួយប្រទេសចិន សហរដ្ឋអាមេរិក និងប្រទេសគោលដៅដទៃទៀត ស្តីពីគោលនយោបាយ និងដំណើរការធ្វើមាតុភូមិនិវត្តន៍សម្រាប់ជនរងគ្រោះ (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)។

១.៥ ពង្រឹងកិច្ចសហប្រតិបត្តិការ និងសមត្ថភាពជំនាញ ជាមួយប្រទេសពាក់ព័ន្ធ និងជាអន្តរជាតិ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាបអំពើជួញដូរមនុស្សឆ្លងដែន ផ្តល់អន្តរាគមន៍ជួយជនរងគ្រោះ និងជំរុញការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី៖

- គ.ជ.ប.ជ. និងក្រុមការងារជំនាញពាក់ព័ន្ធ បានសហការជាមួយប្រទេសគោលដៅ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។
- គ.ជ.ប.ជ. បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅកម្រិតថ្នាក់ដឹកនាំ ដើម្បីកំណត់គោលដៅជាអាទិភាព និងពិភាក្សាពីអភិបាលកិច្ចទេសន្តរប្រវេសន៍ ដើម្បីអនុវត្តកតិកាសញ្ញាសកលស្តីពី "ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព សណ្តាប់ធ្នាប់ និងស្របច្បាប់" (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- គ.ជ.ប.ជ. បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ២ លើក ដែលមានការចូលរួមពីក្រសួងពាក់ព័ន្ធ ទីភ្នាក់ងារសហប្រជាជាតិ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ.។ ជាលទ្ធផលនៃសិក្ខាសាលានេះ មានការរៀបចំ និងអនុវត្តកម្មវិធីរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីជួយដល់ពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ។ កម្មវិធីនេះ បានអនុវត្តក្នុងខេត្តបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- គ.ជ.ប.ជ. បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីថ្នាក់រាជធានី-ខេត្ត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិជាដៃគូ ដើម្បីពិភាក្សាពីបញ្ហាប្រឈមនៃការឆ្លងដែនរបស់ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ក្នុងចំនួនដ៏ច្រើន តាមច្រករបៀងនានា ដោយពួកគេអាចចូលមកគ្រប់ពេល និងក្នុងចំនួនមិនអាចកំណត់ដឹង ហើយពួកគេជួបប្រទះនឹងបញ្ហាសុខភាព និងស្ថានភាព

ជីវភាពពិបាកធ្ងន់ធ្ងរ បន្ថែមលើគោលនយោបាយជាតិសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេស (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- រៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី ៦ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ដើម្បីរៀបចំព្រាងសេចក្ដីថ្លែងការណ៍រួមគ្នារបស់រដ្ឋមន្ត្រីក្រសួងការងារស្ដីពីសុវត្ថិភាពនៃប្រព័ន្ធសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍នៃប្រទេស CLMTV ដែលនឹងត្រូវរៀបចំឡើងនៅក្នុងឆ្នាំ ២០២១ (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- បន្តពិភាក្សាពីការអនុវត្តផែនការសកម្មភាពទី ៤ នៃអនុតំបន់ទន្លេមេគង្គស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២០ - ២០២២ (SPA-IV-2018) ត្រូវបានធ្វើឡើង ដោយផ្ដោតលើសុពលភាពនៃការអនុវត្តលើកទី ១ សម្រាប់ឆ្នាំ ២០១៨-២០២០ និងត្រៀមរៀបចំផែនការសកម្មភាពលើកទី ៥ (SPA-V) ដែលត្រូវបញ្ចូលនិន្នាការថ្មីៗ នៃអំពើជួញដូរមនុស្សដែលមានការចូលរួមពីអង្គការសង្គមស៊ីវិល និងបណ្ដាញយុវជន (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង គ.ជ.ប.ជ. បានចូលរួមវាយតម្លៃលើការអនុវត្តកតិកាសញ្ញាសកលស្ដីពីការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព សណ្ដាប់ធ្នាប់ និងស្របច្បាប់ (GCM) នៅថ្ងៃទី ១០-១២ ខែមីនា ឆ្នាំ ២០២១។

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈតំណាងស្ថានទូត បានជួយសង្គ្រោះ និងសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ ពលករដែលត្រូវបានកំណត់អត្តសញ្ញាណបឋម ថាជាជនដែលងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងបានធ្វើការវាយតម្លៃបឋម លើករណីទាំងនេះ ដើម្បីធ្វើការកំណត់ថាតើ អ្នកទាំងនេះគឺជាជនរងគ្រោះនៃអំពើជួញដូរមនុស្សដែរឬទេ។ សរុបមានចំនួន ១.០៦៦ នាក់ (ស្រី ៥០៣ នាក់)។ មានពលករមិនស្របច្បាប់ ៧៣៣ នាក់ (ស្រី ២៤០ នាក់) មកពីប្រទេសថៃ (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- ការពិភាក្សាបានបន្តធ្វើជាមួយក្រសួងការងារថៃ (តាមរយៈកិច្ចប្រជុំ Zoom) ដើម្បីរិះរកវិធីឆ្លើយតបចំពោះបញ្ហាប្រឈមនានា ដែលពលករទេសន្តរប្រវេសន៍កំពុងស្ថិតនៅក្នុងប្រទេសថៃកំពុងជួបប្រទះខណៈមានការអនុវត្តវិធានការរឹតត្បិតក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- បើតាមរបាយការណ៍របស់ គ.ជ.ប.ជ. សម្រាប់ត្រីមាសទី ២ ឆ្នាំ ២០២១ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងគ.ខ.ប.ជ. បានសហការជាមួយក្រសួងស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ផ្ដល់វគ្គបណ្ដុះបណ្ដាលចំនួន ៣ លើក ដែលមានការចូលរួមពីសិក្ខាកាមចំនួន ១៦៥ នាក់ ស្រី ៧៩ នាក់។ វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណងពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិកនៃលេខាធិការដ្ឋាន គ.ខ.ប.ជ.។ វគ្គបណ្ដុះបណ្ដាលទាំងនេះ រួមមានការបង្កើនការយល់ដឹងអំពីការបញ្ជ្រាបទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ដែលគ្របដណ្ដប់លើប្រធានបទមួយចំនួន ដូចជាជីវភាពរស់នៅ អាហារូបត្ថម្ភ គ្រឿងញៀន ការគ្រប់គ្រងសារជាតុគីមី ការដឹកនាំក្រុមឱ្យបានល្អ ដើម្បី

បង្កើនផលិតភាពការងារ ច្បាប់ស្តីពីការងារ សុវត្ថិភាពការងារ និងការសង្គ្រោះបឋម ក្រោមការសម្របសម្រួលរវាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង និងក្រុមហ៊ុនឯកជនចំនួន ៧។ លេខាធិការដ្ឋាន គ.ខ.ប.ជ. ខេត្តសៀមរាប បានសម្របសម្រួលជាមួយអង្គការបន្ទាយស្រី ផ្តល់វគ្គបណ្តុះបណ្តាល អំពីការបង្ការទប់ស្កាត់ ការធ្វើចំណាកស្រុកដោយខុសច្បាប់ ការពារកុមារនៅក្នុងសហគមន៍ និងការពង្រឹងការកសាងសមត្ថភាព ផ្តោតលើការប្រើប្រាស់ទិន្នន័យ ដែលបានពីប្រព័ន្ធអនឡាញ ជូនរដ្ឋបាលឃុំចំនួន ៦ និងរដ្ឋបាលស្រុកអង្គរជុំ ដើម្បីឆ្លើយតបចំពោះពលករដែលធ្វើទេសន្តរប្រវេសន៍ទៅក្រៅប្រទេស និងដែលបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេសវិញ។

១.៦ ធ្វើវិសោធនកម្ម ឬ/និងរៀបចំសេចក្តីព្រាងច្បាប់ និងគោលនយោបាយជាតិឆ្លើយតបទៅនឹងបញ្ហាថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស៖

- ក្រសួងយុត្តិធម៌បានពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងការរត់ពន្ធមនុស្ស និងសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- បើតាមរបាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលនយោបាយសម្រាប់ជនរងគ្រោះនៅក្នុងមណ្ឌលដំណើរការដោយរដ្ឋ និងជនរងគ្រោះរស់នៅក្នុងសហគមន៍ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.).
- គោលនយោបាយស្តីពីការការពារកុមារ ពីគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាទាំងក្នុង ទាំងក្រៅបរិបទសាលារៀន។

### *៣.៤.១.២ បញ្ហាប្រឈម និងអាទិភាពដែលនៅមាន*

- គួរបន្តធ្វើមូលដ្ឋានីយកម្មផែនការយុទ្ធសាស្ត្រជាតិ ក្នុងក្របខ័ណ្ឌក្រុមការងារជំនាញ និង គ.ជ.ប.ជ. ដើម្បីធានាឱ្យមានការរៀបចំ អនុវត្ត និងពិនិត្យតាមដានផែនការការងារឱ្យបានសមស្របនៅតាមកម្រិត នីមួយៗ។ ចំណុចនេះគួរភ្ជាប់ជាមួយសូចនាករថ្នាក់ជាតិ សម្រាប់បរិបទនីមួយៗ។
- កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការធ្វើផែនការ គឺជាកិច្ចការចាំបាច់ ដើម្បីធានាឱ្យមានការអនុវត្តសកម្មភាពរួមគ្នា ដើម្បីសំដៅលុបបំបាត់អំពើជួញដូរមនុស្ស។ ចាំបាច់ត្រូវមានការចាប់យកឱកាសធ្វើផែនការ ក៏ដូចជារៀបចំ និងអនុវត្តផែនការសកម្មភាពរួមគ្នា។
- នៅក្នុងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ មានការលើកឡើងជាទូទៅថា ការអនុវត្តអនុស្សរណៈជាមួយនឹងប្រទេសមួយចំនួន នៅមានបញ្ហាប្រឈម បើទោះជាពុំមានការលើកឡើងជាក់លាក់ថាប្រទេសណាក៏ដោយ។ មានការលើកឡើងថា ប្រទេសមួយចំនួនមានភាពស្ទាក់ស្ទើរក្នុងការចុះហត្ថលេខាលើអនុស្សរណៈព្រោះវាអាចប៉ះពាល់ដល់ប្រយោជន៍ប្រទេសទាំងនោះ។
- លើសពីនេះទៀត នៅពេលដែលមានការចុះហត្ថលេខា លើអនុស្សរណៈក្នុងករណីមួយចំនួន នីតិវិធីអនុវត្តពុំមានភាពគ្រប់ជ្រុងជ្រោយ ឬមិនត្រូវបានអនុវត្តតាមនោះឡើយ។

- គួរមានការបញ្ជាក់ឱ្យបានច្បាស់ពីតួនាទីផ្តួចផ្តើមចុះអនុស្សរណៈ (អន្តរជាតិ) ដើម្បីកុំឱ្យមានការធ្វើការងារត្រួតគ្នា ឬមានការភាន់ច្រឡំថាតើស្ថាប័នណាទទួលខុសត្រូវដឹកនាំការងារអនុស្សរណៈ។
- ពុំទាន់មានប្រព័ន្ធទិន្នន័យ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីយកមកប្រើប្រាស់សម្រាប់ធ្វើការវិភាគ កំណត់ទិសដៅ អនុវត្ត ផ្សព្វផ្សាយ និងផ្លោះប្តូរព័ត៌មានជាមួយប្រទេសពាក់ព័ន្ធនៅឡើយ។
- សេចក្តីព្រាងច្បាប់ ដែលនឹងជួយបន្ថែមទប់ស្កាត់អំពើជួញដូរមនុស្សក្នុងរូបភាពផ្សេងៗ ដូចជាការពពោះជំនួស និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យានៅមិនទាន់បានបញ្ចប់ និងប្រកាសឱ្យអនុវត្តនៅឡើយ។
- ខណៈដែលការរៀបចំរបាយការណ៍មានភាពល្អប្រសើរជាងមុន របាយការណ៍មួយចំនួនពុំមានសង្គតិភាព និងពុំបានភ្ជាប់ទំនាក់ទំនងឱ្យបានគ្រប់ជ្រុងជ្រោយជាមួយផែនការការងារ និងសូចនាករឡើយ។ ទម្រង់របាយការណ៍ដែលមានសង្គតិភាព ធៀបនឹងសូចនាករ និងផែនការការងារក៏មិនទាន់ត្រូវបានយកទៅអនុវត្តក្នុងគ្រប់វិស័យទាំងអស់ដែរ។ លើសពីនេះ ក៏ពុំមានធនធានមនុស្សឱ្យបានគ្រប់គ្រាន់ ហើយសមត្ថភាពបច្ចេកទេសក្នុងការរៀបចំរបាយការណ៍របស់មន្ត្រីពាក់ព័ន្ធក៏នៅមានកម្រិត។

### ៣.៤.២ យុទ្ធសាស្ត្រទី ២៖ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

| ចង្កោមសកម្មភាព | សូចនាករ |
| --- | --- |
| ២.១ ការសិក្សាស្រាវជ្រាវ ដើម្បីរកវិធានការឱ្យមានការផ្លាស់ប្តូរឥរិយាបថ ដែលអវិជ្ជមានប្រកបដោយគ្រោះថ្នាក់ | • ស្ថានភាពតុល្យភាពនៃផលចំណេញ និងខាតបង់នៃការធ្វើទេសន្តរប្រវេសន៍ចំពោះសង្គម ត្រូវបានរកឃើញ<br>• សេវាកម្មសម្រាប់ការគាំទ្រដល់សុវត្ថិភាពទេសន្តប្រវេសន៍ត្រូវបានរកឃើញ<br>• ទិន្នន័យអំពីសិប្បកម្ម ធុរករ កម្មករ ត្រូវបានផលិត<br>• វិធីសាស្ត្របង្ការ ទប់ស្កាត់យុវវ័យ និងកុមារប្រឈមភាពងាយរងគ្រោះត្រូវបានផលិត |
| ២.២ ការទប់ស្កាត់តាមវិធានការជំនាញ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ការពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងជំរុញអនុវត្តគោលនយោបាយទេសន្តប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០២១-២០២៣ | • បញ្ជីទីភ្នាក់ងារជ្រើសរើសពលករ ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយ<br>• ក្រុមសីលធម៌របស់ទីភ្នាក់ងារជ្រើសរើសពលករត្រូវបានពង្រឹង<br>• ក្រុមហ៊ុន ឬអ្នកជ្រើសរើសខុសច្បាប់ និងឆបោកត្រូវបានបង្ក្រាប |
| ២.៣ វិធានការបង្ការទប់ស្កាត់ តាមរយៈការពង្រឹងយន្តការទទួល និងការពារពលករ ដែលត្រូវបានបញ្ជូនត្រឡប់ | • មណ្ឌលទទួលពលករត្រូវបានពង្រឹង ដើម្បីផ្តល់ព័ត៌មាន និងសេវាដល់ពលករ |

| | |
|---|---|
| ដោយអាជ្ញាធរបរទេស ឬវិលត្រឡប់ដោយមូលហេតុផ្សេងៗ | • ប្រព័ន្ធគ្រប់គ្រងទិន្នន័យហំហូរចេញ/ចូលរបស់ពលករត្រូវបានដំណើរការ<br>• ឃុំ-សង្កាត់ មានផែនការសកម្មភាពបង្ការទប់ស្កាត់សម្រាប់អនុវត្ត |
| ២.៤ វិធានការជំនាញនគរបាលយុត្តិធម៌ ដើម្បីរារាំងតម្រូវការ សេវាកម្មដែលទំនោរទៅរកការជួញដូរមនុស្ស ជួញដូរស្ត្រី ជួញដូរកុមារ និងកាត់បន្ថយភាពរងគ្រោះដល់មុខសញ្ញាងាយរងគ្រោះ | • ក្រុមការងារតាមដានត្រួតពិនិត្យគោលដៅសង្ស័យត្រូវបានបង្កើន និងពង្រឹង<br>• គោលដៅសង្ស័យបទល្មើស ជួញដូរត្រូវបានឃ្លាំមើលស៊ើបអង្កេត និងបង្ក្រាប<br>• កុមារទទួលបានការការពារពីការជួញដូរ ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ អំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ<br>• ជនល្មើសក្លែងឯកសារសាធារណៈ ត្រូវបានស្រាវជ្រាវរកឃើញ បង្ក្រាប និងផ្តន្ទាទោស<br>• ទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសត្រូវបានផលិត |
| ២.៥ វិធានការបង្ការទប់ស្កាត់ តាមរយៈការធ្វើអធិការកិច្ច ទីតាំងគោលដៅសង្ស័យពាក់ព័ន្ធអំពើជួញដូរមនុស្ស និងបង្កើតកម្មវិធីនានា ដើម្បីឆ្លើយតបនឹងតម្រូវការ | • គ្រប់ជំនាញតាមក្រសួងស្ថាប័នពាក់ព័ន្ធ ពង្រឹងការចុះតាមដាន ត្រួតពិនិត្យមុខសញ្ញា គោលដៅ ដែលអាចកើតមានបទល្មើសជួញដូរ រំលោភបំពាន និងកេងប្រវ័ញ្ចផ្សេងៗ |
| ២.៦ វិធានការបង្ការទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស | • ព័ត៌មានពីភាពងាយរងគ្រោះតាមរយៈអាពាហ៍ពិពាហ៍ជាមួយជនបរទេស ត្រូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>• អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសមិនស្របច្បាប់ ត្រូវបានកាត់បន្ថយ |
| ២.៧ វិធានការបង្ការទប់ស្កាត់ តាមរយៈការបង្កើនការយល់ដឹង អំពីច្បាប់ គោលនយោបាយ លិខិតូបករណ៍ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធរាល់ទម្រង់នៃបទល្មើសជួញដូរមនុស្ស | • គ្រប់សមាសភាពពាក់ព័ន្ធ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ទទួលបានការយល់ដឹងពីខ្លឹមសារ គោលនយោបាយពាក់ព័ន្ធ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កលល្បិចជនល្មើស និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន និងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស |
| ២.៨ វិធានការបង្ការទប់ស្កាត់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងដល់អ្នកសារព័ត៌មាន | • សិល្បករ ពិធីករ អ្នកសារព័ត៌មាន បានយល់ច្បាស់អំពីអំពើជួញដូរមនុស្ស<br>• បង្កើតស្នាដៃអប់រំសង្គម ឱ្យរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស គ្រប់រូបភាពប្រកបដោយសីលធម៌វិជ្ជាជីវៈ<br>• ប្រជាពលរដ្ឋមានការយល់ដឹង អំពីការបង្ការ ទប់ស្កាត់ |

| | |
|---|---|
| **២.៩ យុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈ** | • កម្មវិធីអប់រំផ្សព្វផ្សាយទូលំទូលាយ ដល់ប្រជាពលរដ្ឋគ្រប់ច្រកល្ហក ត្រូវបានបង្កើតឡើង និងអនុវត្តជាប្រចាំ |
| **២.១០ វិធានការជំនាញ ក្រសួងអប់រំ យុវជន និងកីឡា៖ សកម្មភាពអប់រំតាមសាលារៀន និងវិស័យឯកជន អំពីកិច្ចការពារ កុមារពីអំពើជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាព** | • កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមសាលារៀន ត្រូវបានបង្កើតឡើង<br>• គ្រូទទួលបានការយល់ដឹងពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស |

យុទ្ធសាស្ត្រទី ២ ផ្តោតលើការបង្ការទប់ស្កាត់ ការជួញដូរមនុស្សគ្រប់រូបភាព។ ក្រុមការងារបង្ការទប់ស្កាត់ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា។ ជារួមសកម្មភាពបង្ការទប់ស្កាត់ ក៏ជាការងារសំខាន់នៃក្រុមការងារជំនាញផ្សេងទៀត គ.ខ.ប.ជ. និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិផងដែរ។ ក្រុមគោលដៅនៃសកម្មភាពបង្ការទប់ស្កាត់ រួមមានស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ និងពលករទេសន្តរប្រវេសន៍។ ខាងក្រោមនេះ គឺជាការបង្ហាញដោយសង្ខេបពីសកម្មភាពដែលបានពីរបាយការណ៍នានា និងពីការសម្ភាសជាមួយនឹងអ្នកផ្តល់ព័ត៌មាន។

### *៣.៤.២.១ វឌ្ឍនភាព*

**២.១ ការសិក្សាស្រាវជ្រាវ ដើម្បីរកវិធានការឱ្យមានការផ្លាស់ប្តូរឥរិយាបថ ដែលអវិជ្ជមាន ប្រកបដោយគ្រោះថ្នាក់**

- ការស្រាវជ្រាវចម្បងដែលធ្វើឡើងនៅក្នុងរយៈពេលនេះ មានភាពពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់នៃជំងឺកូវីដ១៩។ ការវាយតម្លៃបែបរហ័សជាច្រើនត្រូវបានធ្វើឡើងដោយផ្តោតជាពិសេសលើផលប៉ះពាល់មកលើពលករទេសន្តរប្រវេសន៍ដែលបានត្រឡប់មកកម្ពុជាវិញ និង/ឬកំណើនហានិភ័យនៃអំពើជួញដូរមនុស្ស។ ការស្រាវជ្រាវមួយចំនួនដែលត្រូវបានធ្វើឡើងរួមមាន៖
    - អង្គការ CARE៖ ការវិភាគបែបរហ័សលើយេនឌ័រក្នុងបរិបទជំងឺកូវីដ១៩
    - ទីភ្នាក់ងារសហប្រជាជាតិ៖ ការវាយតម្លៃបែបរហ័ស លើផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដែលបង្កឡើងដោយជំងឺកូវីដ១៩ មកលើពលករទេសន្តរប្រវេសន៍ ដែលបានត្រឡប់មកកម្ពុជាវិញ (UNFPA, UN Women, IOM, UNAIDS, UNICEF)
    - អង្គការ CARE៖ ការវាយតម្លៃលើតម្រូវការរបស់កម្មករ កម្មការនីកាត់ដេរ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩
    - អង្គការអន្តរជាតិខាងការងារ៖ ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើពលករទេសន្តរប្រវេសន៍កម្ពុជា
    - អង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)៖ ការអង្កេតលើពលករទេសន្តរប្រវេសន៍ជាស្ត្រីដែលបានធ្វើមាតុភូមិនិវត្តន៍ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ
- ការស្រាវជ្រាវផ្សេងទៀតដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលនេះផងដែរ រួមមាន៖

- អង្គការអន្តរជាតិខាងការងារ៖ ថ្លៃសេវាជ្រើសរើសពលករ និងចំណាយដែលពាក់ព័ន្ធ៖ តើពលករទេសន្តរប្រវេសន៍មកពីកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ត្រូវបង់ថ្លៃអ្វីខ្លះ ដើម្បីអាចធ្វើការងារនៅក្នុងប្រទេសថៃបាន
- អង្គការវីនរ៉ក់៖ ដំណើររបស់ពលករកម្ពុជា

**២.២ ការទប់ស្កាត់តាមវិធានការជំនាញក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ៖ ការពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងជំរុញអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ ២០២១-២០២៣**

- បញ្ជីរាយនាមទីភ្នាក់ងារជ្រើសរើសពលករត្រូវបានធ្វើបច្ចុប្បន្នភាពដោយទៀងទាត់ ហើយមានការផ្សព្វ ផ្សាយយ៉ាងទូលំទូលាយតាមរយៈគេហទំព័រ និងទំព័រហ្វេសប៊ុករបស់ក្រសួង។ ក្រុមការងារវាយតម្លៃ កត់សម្គាល់ឃើញថាមានទីភ្នាក់ងារជ្រើសរើសពលករឯកជនចំនួន ១២៦ ដែលកំពុងផ្តោតការយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាដែលពលករទេសន្តរប្រវេសន៍ជួបប្រទះនៅតាមប្រទេសគោលដៅ ជាជាងជ្រើសរើសពលករថ្មី និងបញ្ជូនពួកគេឱ្យទៅធ្វើការក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ដ៏សែនលំបាកនេះ (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ.)។
- ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់ គ.ជ.ប.ជ. សម្រាប់ឆមាសទី ១ ឆ្នាំ ២០២១ ពលករទេសន្តរប្រវេសន៍ ដែលត្រូវបានបញ្ជូនទៅធ្វើការនៅក្រៅប្រទេស តាមរយៈទីភ្នាក់ងារជ្រើសរើសពលករ និងប្រព័ន្ធផ្តល់លិខិតអនុញ្ញាតការងារ (EPS) មានចំនួនសរុប ២.១៨៩ នាក់ (ស្រី ៦៩៦ នាក់)។ ប្រទេសគោលដៅរួមមាន សាធារណៈរដ្ឋកូរ៉េ សរុបចំនួន ១.៧៥៩ នាក់ (ស្រី ៤៦៧ នាក់) ជប៉ុន ៣៨៧ នាក់ (ស្រី ១៨៦ នាក់) សិង្ហបុរី ពលការនីចំនួន ២ នាក់ និងតំបន់រដ្ឋបាលពិសេសហុងកុងមានពលករជាស្ត្រីចំនួន ៤១ នាក់។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់វគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរ ដូចជាការបណ្តុះបណ្តាលពីភាសា ជំនាញកម្រិតមូលដ្ឋាន ច្បាប់នៅក្នុងប្រទេសគោលដៅ លក្ខខណ្ឌការងារ របៀបរបបរស់នៅ និងវប្បធម៌នៃប្រទេសគោលដៅ ដែលមានការចូលរួមពីសិក្ខាកាមដែលមានបំណងធ្វើ ទេសន្តរប្រវេសន៍ចំនួន ៧៣៤ នាក់ (ស្រី ១៥៦ នាក់) (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រព័ន្ធទិន្នន័យបញ្ជីទីភ្នាក់ងារជ្រើសរើសពលករ ព្រមទាំងពលករដែលទីភ្នាក់ងារនោះបានជ្រើសរើស ព្រមទាំងលក្ខខណ្ឌការងារនៅក្នុងប្រទេសគោលដៅ ដោយទីភ្នាក់ងារជ្រើសរើសពលករត្រូវរាយការណ៍ជាប្រចាំជូននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។
- មានការផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធអន្តរជាតិ ដើម្បីលើកកម្ពស់សុចរិតភាពក្នុងការជ្រើសរើសពលករ (IRIS) របស់ IOM ដល់ទីភ្នាក់ងារជ្រើសរើសពលករឯកជនចំនួន ៧៥ ផ្តោតលើការមិនគិតថ្លៃសេវា

ក្នុងដំណើរការជ្រើសរើស ការស្វែងរកការងារឱ្យធ្វើ និងជានាយ៉ាងណាឱ្យថ្លៃសេវានានា ត្រូវបង់ដោយនិយោជកជំនួសវិញ (របាយការណ៍ធមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មាននីតិវិធីមួយដែលហៅថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សម្រាប់អនុវត្តដំណើរការដោះស្រាយវិវាទការងាររវាងពលករ និងនិយោជកក្នុងប្រទេសគោលដៅ។ បន្ទាប់ពីយន្តការនេះត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីឆ្នាំ២០២០ ដំណើរការជ្រើសរើសពលករ បណ្តុះបណ្តាលពលករ និងដោះស្រាយវិវាទការងារមានភាពល្អប្រសើរច្រើនជាងមុន នេះបើតាមការសម្ភាសជាមួយសមាជិកក្រុមការងារជំនាញ។
- មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនកិត្តិយសក្នុង "កម្មវិធីសំឡេងសមភាពយេនឌ័រ" ដោយបានពិភាក្សាពីរបៀបធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពទៅក្រៅប្រទេស។

*"យើងបានរៀបចំផែនការសកម្មភាព ដើម្បីឆ្លើយតបចំពោះស្ថានភាពបច្ចុប្បន្នរបស់ពលករទេសន្តរប្រវេសន៍"*
ក្រុមការងារទេសន្តរប្រវេសន៍

## ២.៣ វិធានការបង្ការទប់ស្កាត់ តាមរយៈការពង្រឹងយន្តការទទួល និងការពារពលករ ដែលត្រូវបានបញ្ជូនត្រឡប់ ដោយអាជ្ញាធរបរទេស ឬវិលត្រឡប់ ដោយមូលហេតុផ្សេងៗ

- បានសហការជាមួយក្រសួងកិច្ចការនារី ដើម្បីបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ស្តីពីការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសពលករទេសន្តរប្រវេសន៍ក្នុងតំបន់អាស៊ាន តាមរយៈប្រកាសអន្តរក្រសួងលេខ ០៨៦/២១ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១។
- បានផ្សព្វផ្សាយព័ត៌មានជូនពលករទេសន្តរប្រវេសន៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ ដូចជា តាមរយៈការចែកខិតប័ណ្ណព័ត៌មានអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ផ្តល់ជូនពួកគេនូវស្បៀងអាហារ កន្លែងស្នាក់នៅបណ្តោះអាសន្ន និងគ្រឿងផ្គត់ផ្គង់ដទៃទៀត ក៏ដូចជាសេវានានា រួមទាំងការធ្វើតេស្តរកជំងឺកូវីដ១៩ ព័ត៌មានអំពីឱកាសការងារនៅក្នុងប្រទេសថៃ ការពិគ្រោះយោបល់អំពីរបៀបធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ទៅកាន់ប្រទេសថៃ និងម៉ាឡេស៊ី ជាដើម។ ការងារទាំងនេះត្រូវបានអនុវត្តដោយមានការសហការជាមួយអង្គការនានា ដូចជា Samaritan Purse, អង្គការដំណក់ទឹក អង្គការគ្រួសារថ្មី អង្គការភឿន ភឿន IOM អង្គការក្តីស្រឡាញ់គ្មានព្រំដែន និង CWCC (របាយការណ៍ធមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- ចេញសេចក្តីណែនាំស្តីពីការសម្របសម្រួលការសិក្សា ដោយមានវិញ្ញាបនបត្របញ្ជាក់ និងការចុះឈ្មោះសិក្ខាកាមជាពលករទេសន្តរប្រវេសន៍ និងសិស្សដែលឪពុកម្តាយបានធ្វើមាតុភូមិនិវត្តន៍បន្ទាប់ពីបានធ្វើទេសន្តរប្រវេសន៍រួច (របាយការណ៍ធមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

- គ.ខ.ប.ជ. បានផ្តល់ការគាំទ្រដល់ពលករទេសន្តរប្រវេសន៍ នៅពេលដែលចាំបាច់ ដូចជា នៅពេលដែលពួកគេធ្វើមាតុភូមិនិវត្តន៍ និងបានសម្របសម្រួលជាមួយនឹងមន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ។

**២.៤ វិធានការជំនាញនគរបាលយុត្តិធម៌ ដើម្បីរារាំងតម្រូវការ សេវាកម្មដែលដែលទំនោរទៅរកការជួញដូរមនុស្ស ជួញដូរស្ត្រី ជួញដូរកុមារ និងកាត់បន្ថយភាពរងគ្រោះដល់មុខសញ្ញាងាយរងគ្រោះ**

- ពុំមានសកម្មភាពជាក់លាក់ត្រូវបានកំណត់រកឃើញ ក្រោមចង្កោមសកម្មភាពនេះឡើយ។ ទោះបីជាបែបនេះក្តី សកម្មភាពក្នុងចង្កោមសកម្មភាពដទៃទៀត ទំនងជាអាចដាក់បញ្ចូលក្នុងចង្កោមសកម្មភាពនេះបាន។

**២.៥ វិធានការបង្ការទប់ស្កាត់ តាមរយៈការធ្វើអធិការកិច្ច ទីតាំងគោលដៅសង្ស័យពាក់ព័ន្ធអំពើជួញដូរមនុស្ស និងបង្កើតកម្មវិធីនានា ដើម្បីឆ្លើយតបនឹងតម្រូវការ**

- មានការរកឃើញសកម្មភាពជាក់លាក់តិចតួចក្រោមចង្កោមសកម្មភាពនេះ។ ទោះបីជាបែបនេះក្តី សកម្មភាពក្នុងចង្កោមសកម្មភាពដទៃទៀត ទំនងជាអាចដាក់បញ្ចូលក្នុងចង្កោមសកម្មភាពនេះបានដែរ។ នេះទំនងជាបណ្តុំសកម្មភាពមួយដែលត្រូវបានពន្យារ ដោយសារវិធានការរឹតត្បិតការធ្វើដំណើរដែលត្រូវបានដាក់ឱ្យអនុវត្តដើម្បីបង្ការទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ១៩។

- កាលពីខែកុម្ភៈ ឆ្នាំ២០២១ បញ្ជាការដ្ឋានភូមិភាគបស្ចិម បូព៌ា និងឧត្តរ ត្រូវបានបង្កើតឡើងក្នុងខេត្តដែលនៅជាប់នឹងព្រំដែនប្រទេសវៀតណាម និងប្រទេសថៃ។ នៅតាមបណ្តោយព្រំដែន ពលករទេសន្តរប្រវេសន៍ ដែលពុំមានឯកសារបញ្ជាក់ត្រឹមត្រូវ ត្រូវបានឃាត់ខ្លួន និងអប់រំអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងប្រថុយប្រថាន ក្នុងអំឡុងពេលនៃវិបត្តិកូវីដ១៩ បន្ទាប់ពីមានការដាក់ចេញនូវវិធានការសុខភាពសាធារណៈ។[3]

*“ ការបង្ការទប់ស្កាត់ករណីជួញដូរមនុស្សតាមរយៈការផ្សព្វផ្សាយ គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ត្រូវបានធ្វើឡើងយ៉ាងទូលំទូលាយ”*

គ.ខ.ប.ជ.

**២.៦ វិធានការបង្ការទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- អគ្គនាយកដ្ឋានកិច្ចការកុងស៊ុលនៃក្រសួងការបរទេសបានពង្រឹងការត្រួតពិនិត្យឯកសារ ស្ត្រីក្មេងៗដែលធ្វើដំណើរទៅក្រៅប្រទេសដើម្បីរៀបអាពាហ៍ពិពាហ៍ ឬរៀបអាពាហ៍ពិពាហ៍ដោយមិនស្ម័គ្រ

[3] របាយការណ៍ដែលបានពីសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីផែនការយុទ្ធសាស្ត្រជាតិ ដែលរៀបចំដោយ គ.ជ.ប.ជ. កាលពីខែកក្កដា ឆ្នាំ ២០២១

ចិត្ត ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ។[4]

**២.៧ វិធានការបង្ការទប់ស្កាត់ តាមរយៈការបង្កើនការយល់ដឹង អំពីច្បាប់ គោលនយោបាយ លិខិតូបករណ៍ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធរាល់ទម្រង់នៃបទល្មើសជួញដូរមនុស្ស**

- សូមមើលចំណុច ២.៩ ខាងក្រោម
- ខ្លឹមសារបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស ត្រូវបានបញ្ចូលទៅក្នុងយន្តការនានា ដូចជា ផែនការសេវាសង្គមឃុំ/សង្កាត់ និងការប្រើប្រាស់ថវិកាឃុំសម្រាប់អនុវត្តសកម្មភាពនានា គណៈកម្មការគ្រប់គ្រងសាលារៀន និងក្លឹបយុវជននៅតាមសាលារៀន និងសហគមន៍ ដែលមានសមាសភាពជានាយកសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍/មាតាបិតា, កិច្ចប្រជុំរវាងថ្នាក់ខេត្តជាមួយនឹងឃុំ/សង្កាត់ ដើម្បីបញ្ជ្រាបសកម្មភាពនានា សំដៅលើកកម្ពស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការបញ្ចូលខ្លឹមសារទៅក្នុងកម្មវិធីព្រះពុទ្ធសាសនា ដែលរៀបចំដោយក្រសួងធម្មការ និងសាសនា។[5]
- បានសហការជាមួយនឹងមណ្ឌលចត្តាឡីស័កនៅជិតព្រំដែន (សម្រាប់ករណីកូវីដ ១៩) សម្រាប់ពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ដើម្បីផ្សព្វផ្សាយព័ត៌មានជូនពួកគាត់អំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

**២.៨ វិធានការបង្ការទប់ស្កាត់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងដល់អ្នកសារព័ត៌មាន**

- ពុំមានការរាយការណ៍ពីសកម្មភាពជាក់លាក់ ក្រោមចង្កោមសកម្មភាពនេះឡើយ បើទោះជាសកម្មភាពក្នុងចង្កោមសកម្មភាពដទៃទៀត ទំនងជាអាចយកមកបញ្ចូលក្នុងផ្នែកនេះផងដែរ ដូចចំណុច ២.៩ ខាងក្រោម។

**២.៩ យុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈ**

- បានផ្សព្វផ្សាយព័ត៌មាន ក្នុងទម្រង់ជាសារអប់រំស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុ បណ្តាញទំនាក់ទំនងសង្គម វេទិកាសាធារណៈ សិក្ខាសាលាពិគ្រោះយោបល់ វេទិកាសាសនា និងផ្សព្វផ្សាយជូនពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍។
- ក្រសួងកិច្ចការនារី សហការជាមួយ UN Women តាមរយៈកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ បានផ្សព្វផ្សាយសារអប់រំចំនួន ៨ តាមរយៈទំព័រហ្វេសប៊ុករបស់ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី ក្នុងគោលបំណងបង្ការទប់ស្កាត់អំពើហិង្សា និងការរើសអើងលើពលករទេសន្តរប្រវេសន៍ និងដើម្បីផ្តល់

[4] Ibid.

[5] Ibid.

"យើងបានបង្កើតក្រុមការងារជាមួយនឹងលេខាធិការដ្ឋាន គ.ជ.ប.ជ. ដើម្បីរៀបចំសៀវភៅសិក្សា និងសម្ភារឧបទេសន៍ផ្ដោតលើការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅតាមសាលារៀន"
ក្រុមការងារបង្ការទប់ស្កាត់

ព័ត៌មានទំនាក់ទំនង សេវា និងព័ត៌មានអំពីសេវាចាំបាច់សំខាន់ៗ សម្រាប់ស្ត្រី និងក្មេងស្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សា និងការកេងប្រវ័ញ្ច។

• ក្រសួងអប់រំយុវជន និងកីឡាបានផ្សព្វផ្សាយព័ត៌មានតាម វិទ្យុ និងទូរទស្សន៍ កាលពីថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៩ តាមរយៈការចុះអប់រំផ្សព្វផ្សាយដល់សហគមន៍អំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

• ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានចូលរួមផ្សព្វផ្សាយព័ត៌មាន និងចែករំលែកចំណេះដឹងជាមួយក្រុមការងារ សមាជិកសហគមន៍មូលដ្ឋាន និងស្ថាប័នដទៃទៀត។

• គ.ខ.ប.ជ. ទាំងអស់ដែលត្រូវបានសម្ភាស បានផ្ដល់អាទិភាពដល់ការផ្សព្វផ្សាយព័ត៌មាន និងបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយដោយប្រើប្រាស់រូបភាពចម្រុះ ដូចជាតាមសាលារៀន និងសហគមន៍ តាមរយៈវិទ្យុ បណ្ដាញទំនាក់ទំនងសង្គម វេទិកាសាធារណៈ សិក្ខាសាលាពិគ្រោះយោបល់ វេទិកាសាសនា និងតាមរយៈពលករដែលបានធ្វើមាតុភូមិនិវត្តន៍។ គ.ខ.ប.ជ. បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដើម្បីផ្សព្វ ផ្សាយព័ត៌មានទៅក្នុងសហគមន៍។

• ប្រធានបទដូចជា ការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ ត្រូវបានបញ្ចូលទៅក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

- ស្ថាប័នជាតិ ស្ថាប័នថ្នាក់ក្រោមជាតិ អាជ្ញាធរមកពីមន្ទីរជំនាញថ្នាក់ខេត្តបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូ និងធ្វើការផ្សព្វផ្សាយព័ត៌មានអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ទេសន្តប្រវេសន៍ប្រកប ដោយសុវត្ថិភាព តាមរយៈវេទិកាសាធារណៈ និងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងតាមរយៈព្រឹត្តិការណ៍ដទៃទៀត ដែលមានការចូលរួមពីមន្ត្រីរដ្ឋាភិបាល សិស្ស គ្រូបង្រៀន អ្នកគោរពប្រតិបត្តិសាសនា និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ការផ្សព្វផ្សាយព័ត៌មានបានធ្វើឡើងចំនួន ២៧.៧២៩ លើក ដែលមានអ្នកចូលរួមចំនួន ៩០៧.២៣៩ នាក់ បើធៀបនឹងត្រីមាសទី ១ ក្នុងឆ្នាំដដែលដែលមានអ្នកចូលរួមចំនួន ១.៣៧៤.០៨៩ នាក់ថយចុះ ៤៦៦.៨៤៥ នាក់ (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

## ២.១០ វិធានការជំនាញក្រសួងអប់រំ យុវជន និងកីឡា៖ សកម្មភាពអប់រំតាមសាលារៀន និងវិស័យឯកជនអំពីកិច្ចការពារកុមារពីអំពើជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាព

- ក្រុមការងារបង្ការទប់ស្កាត់ បានបង្កើតក្រុមការងារមួយ ដើម្បីរៀបចំសៀវភៅសិក្សា និងវិធីសាស្ត្របង្រៀនស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។

- ប្រធានបទបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា។
- សៀវភៅសិក្សាស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងសៀវភៅណែនាំសម្រាប់ការបង្រៀន ចំនួន ៦.000 ក្បាល ត្រូវបានរៀបចំឡើង សម្រាប់ការបង្រៀនសាកល្បង។ សៀវភៅសិក្សានេះត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីខែកុម្ភៈ ឆ្នាំ២០២១។ អ្វីដែលបានត្រៀមក្នុងផែនការ គឺការផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលដោយប្រើប្រាស់វិធីសាស្ត្របង្រៀនតគ្នា ដើម្បីគ្របដណ្តប់លើគ្រូបង្រៀនទូទាំងប្រទេស។ នេះគឺជាកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា (ដែលដឹកនាំក្រុមការងារបង្ការទប់ស្កាត់) អង្គការផ្លែនអន្តរជាតិ(Plan International) អង្គការA21 អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) អង្គការការីតាស (Caritas) និងមជ្ឈមណ្ឌលសាមគ្គីភាព (Solidarity Center)។
- ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយនឹងអង្គការផ្លែនអន្តរជាតិ ក្រុមការងារបង្ការទប់ស្កាត់ និងលេខាធិការដ្ឋាន គ.ជ.ប.ជ. ដើម្បីរៀបចំសិក្ខាសាលារំលឹកឡើងវិញស្តីពីការបង្ការទប់ស្កាត់ការជួញដូរមនុស្ស និងសៀវភៅណែនាំស្តីពីការបង្រៀន តាមរយៈកិច្ចប្រជុំ Zoom ជូនគ្រូបង្រៀនចំនួន ៥៣ នាក់នៅក្នុងខេត្តកំពង់ឆ្នាំង។
- ពាក់ព័ន្ធនឹងហានិភ័យរបស់យុវជន និងកុមារដែលសិក្សាតាមប្រព័ន្ធអនឡាញ មន្ទីរអប់រំ យុវជន និងកីឡាបានរៀបចំវិធីសាស្ត្រ បង្កើតក្រុមយុវជនស្ម័គ្រចិត្ត ដើម្បីបង្កើនការយល់ដឹង អំពីការបង្ការទប់ស្កាត់ ការជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ តាមរយៈការបង្កើតក្រុមការងារ ដោយមួយក្រុមៗមានគ្នា ៤ នាក់ មកពីតាមស្រុកផ្សេងៗគ្នា។ អ្នកទាំងនេះត្រូវប្រកួតប្រជែង ដើម្បីទទួលបានមុខដំណែងនេះ តាមរយៈការសរសេរសំណើគម្រោង ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅក្នុងបរិបទកូវីដ១៩។

### ៣.៤.២.២ បញ្ហាប្រឈម និងអាទិភាពដែលនៅសេសសល់

- សកម្មភាពសំខាន់ៗ ដែលត្រូវបានរាយការណ៍ រួមមានការផ្សព្វផ្សាយព័ត៌មាន យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ប៉ុន្តែពុំមានការបញ្ជាក់ឱ្យបានច្បាស់ ថាតើអង្គការ ស្ថាប័ន ទាំងអស់នោះបានធ្វើការផ្សព្វផ្សាយពីប្រធានបទ ឬសារដែលមានសង្គតិភាពជូនសាធារណៈជនឬទេ។ អង្គការស្ថាប័នមួយចំនួនផ្តោតលើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ច្បាប់ និងគោលនយោបាយ ប៉ុន្តែពុំមានការរកឃើញថាមានការផ្សព្វផ្សាយសារអប់រំដែលមានលក្ខណៈស្តង់ដារនោះឡើយ។
- មានចង្កោមសកម្មភាពមួយចំនួន ដែលពុំមានការរាយការណ៍ពីសកម្មភាព។ ប៉ុន្តែពុំមានការបញ្ជាក់ថាតើ មានសកម្មភាពពាក់ព័ន្ធដែលត្រូវបានអនុវត្តចប់រួចរាល់ ឬមិនមាននោះទេ។ សកម្មភាពមួយចំនួនត្រូវបានពិពណ៌នាជាលក្ខណៈទូទៅ និងពិបាកបែងចែកទៅតាមប្រភេទ។ ការកែលម្អការរៀបចំរបាយការណ៍ផ្នែកនេះ នឹងមានសារៈប្រយោជន៍ច្រើន។ ឧទាហរណ៍ របាយការណ៍រៀបរាប់ជាទូទៅថាសកម្មភាពដែលមានលក្ខណៈទូលំទូលាយមួយត្រូវបានបញ្ចប់ ប៉ុន្តែពុំមានបញ្ជាក់ថាស្ថាប័នណាអ្នកធ្វើសកម្មភាពនោះ នៅកន្លែងណា ហើយក៏ពុំមានព័ត៌មានលម្អិតផ្សេងៗទៀតនោះឡើយ។ ទម្រង់

របាយការណ៍ គួរគោរពតាមសូចនាករ និងលទ្ធផលរំពឹងទុក បែងចែកតាមស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។

- បម្រែបម្រួលនៃបរិបទនាំឱ្យមានហានិភ័យថ្មីៗ ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដូចជាហានិភ័យសម្រាប់ពលករទេសន្តរប្រវេសន៍ ដែលបានធ្វើមាតុភូមិនិវត្តន៍ និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញមកលើកុមារ ដែលទាមទារឱ្យមានការរៀបចំយុទ្ធសាស្ត្រថ្មីៗ សម្រាប់ធ្វើការងារបង្ការទប់ស្កាត់។
- សកម្មភាពបង្ការទប់ស្កាត់ ផ្តោតលើការរកចំណូល និងការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ច មិនត្រូវបានបញ្ជាក់លម្អិតឱ្យបានគ្រប់គ្រាន់នៅក្នុងរបាយការណ៍ឡើយ។ សកម្មភាពបង្ការទប់ស្កាត់ដ៏សំខាន់មួយ គឺការលើកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ច ដើម្បីកាត់បន្ថយហានិភ័យនៃអំពើជួញដូរមនុស្ស នៅពេលដែលក្រុមគ្រួសារ ឬបុគ្គល ធ្វើទេសន្តរប្រវេសន៍ក្នុងកាលៈទេសៈដែលមានហានិភ័យខ្ពស់ ដែលបណ្តាលមកពីសម្ពាធសេដ្ឋកិច្ច។ ខណៈពេលដែលមានអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិជាច្រើនធ្វើសកម្មភាពផ្នែកនេះ ការងាររបស់ពួកគេ គឺមិនត្រូវបានបញ្ចូលឱ្យបានគ្រប់ជ្រុងជ្រោយ នៅក្នុងរបាយការណ៍ឡើយ។

### ៣.៤.៣ យុទ្ធសាស្ត្រទី ៣៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

| ចង្កោមសកម្មភាព | សូចនាករ |
|---|---|
| ៣.១ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន ជំនាញអនុវត្តច្បាប់ តុលាការ និងមន្ត្រីសង្គមកិច្ច នៅក្នុងប្រទេស និងទំនាក់ទំនងផ្លូវការទូតរវាងកម្ពុជា និងប្រទេសគោលដៅ ដើម្បីយុត្តិធម៌ជនរងគ្រោះ។ | • របាយការប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំត្រូវបានផលិត<br>• ការសម្របសម្រួល និងកិច្ចសហការមន្ត្រីអនុវត្តច្បាប់ និងស្ថាប័នអយ្យការ តុលាការ និងសេវាសង្គមមានភាពរលូន |
| ៣.២ ការលើកកម្ពស់សមត្ថភាពមន្ត្រីស្ថាប័នពាក់ព័ន្ធ ដើម្បីការងារបង្ការទប់ស្កាត់ | • ក្រសួង ស្ថាប័ន ក្នុងក្រុមការងារបង្ការទប់ស្កាត់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានយល់ដឹង និងមានសមត្ថភាព ដាក់វិធានការបង្ការទប់ស្កាត់តាមវិស័យនីមួយៗ<br>• មន្ត្រីអនុវត្តច្បាប់ទទួលបានការបណ្តុះបណ្តាលសមត្ថភាព<br>• មន្ត្រីជំនាញទទួលបានការបណ្តុះបណ្តាលពីសុវត្ថិភាពស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ |
| ៣.៣ ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីក្នុងស្ថាប័នអយ្យការ ឱ្យកាន់តែប្រសើរឡើង ក្នុងការដោះស្រាយករណីជួញដូរមនុស្ស | • មន្ត្រីអនុវត្តច្បាប់ ទទួលបានការបណ្តុះបណ្តាលជំនាញនីតិវិធីស៊ើបអង្កេត<br>• មន្ត្រីទទួលបានការយល់ដឹងអំពីច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ |

> *"ក្រុមការងារពង្រឹងការអនុវត្តច្បាប់ទទួលបានជោគជ័យ ព្រោះយើងធ្វើការងារជាមួយនឹងក្រុមផ្សេងទៀត។ ឧទាហរណ៍ នៅពេលក្រសួងកិច្ចការនារីបញ្ជូនករណីអ្វីមួយមក យើងរួមគ្នាស៊ើបអង្កេត និងបញ្ជូនទៅក្រសួងយុត្តិធម៌ ដើម្បីបន្តធ្វើការផ្តន្ទាទោស"*
> ក្រុមការងារពង្រឹងការអនុវត្តច្បាប់

### *៣.៤.៣.១ វឌ្ឍនភាព*

យុទ្ធសាស្ត្រទី ៣ ផ្តោតលើការឆ្លើយតបផ្នែកប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះករណីជួញដូរមនុស្ស។ សកម្មភាពយុទ្ធសាស្ត្រនេះ ពាក់ព័ន្ធនឹងក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយស្នងការដ្ឋាននគរបាលជាតិ និងក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌។ យុទ្ធសាស្ត្រនេះមានចង្កោមសកម្មភាពចំនួន ៣។ ខាងក្រោមនេះ គឺជាការរៀបរាប់ដោយសង្ខេបពីវឌ្ឍនភាពដែលសម្រេចបាន៖

**៣.១ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន ជំនាញអនុវត្តច្បាប់ តុលាការ និងមន្ត្រីសង្គមកិច្ច នៅក្នុងប្រទេស និងទំនាក់ទំនងផ្លូវការទូតរវាងកម្ពុជា និងប្រទេសគោលដៅ ដើម្បីយុត្តិធម៌ជនរងគ្រោះ**

- គ.ខ.ប.ជ. រាយការណ៍ថា មន្ត្រីនគរបាល / មន្ត្រីអនុវត្តច្បាប់កាន់តែមានសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ និងស៊ើបអង្កេតលើជន ដែលប្រព្រឹត្តបទល្មើស។ មន្ត្រីពាក់ព័ន្ធបានសម្របសម្រួលជាមួយនឹងមន្ត្រីក្នុងខេត្តដទៃទៀត ទៅតាមតម្រូវការចាំបាច់។
- មានករណីប្រហែលជា ៣០០ ករណី ត្រូវបានចោទប្រកាន់បន្ទាប់ពីមានកិច្ចសហប្រតិបត្តិការរវាងតួអង្គពាក់ព័ន្ធសំខាន់ៗ និងការសម្របសម្រួលជាមួយនឹងខេត្តដទៃទៀត (របាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ.)។
- ដំណើរការដាក់ពាក្យបណ្តឹងមានភាពយឺតយ៉ាវ ក្នុងបរិបទនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩។ ជាការឆ្លើយតបចំពោះបញ្ហាប្រឈមនេះ ក្រសួងការបរទេស បានសហការយ៉ាងល្អជាមួយអគ្គស្នងការដ្ឋាននគរបានជាតិនៃក្រសួងមហាផ្ទៃ សម្របសម្រួលដំណើរការដាក់ពាក្យបណ្តឹងតាមប្រព័ន្ធអនឡាញ ពោលគឺជនរងគ្រោះមិនចាំបាច់មានវត្តមានផ្ទាល់នោះឡើយ។ នីតិវិធីបែបនេះមានភាពបត់បែន ងាយស្រួល និងផ្តល់នូវលទ្ធផលល្អប្រសើរ។[6]
- មានកិច្ចសហប្រតិបត្តិការយ៉ាងល្អ រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ស្ថានទូត ស្ថានកុងស៊ុលនៅក្រៅប្រទេស និងអង្គការជាដៃគូ ក្នុងការធ្វើមាតុភូមិនិវត្តន៍ពលករ ដូចជាការទិញសំបុត្រយន្តហោះ ការរៀបចំការធ្វើដំណើរ និងការស្វែងរកកន្លែងស្នាក់នៅបណ្តោះអាសន្នជាដើម។ ហើយក្រសួងស្ថាប័ន

---
6 របាយការណ៍ដែលបានពីសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីផែនការយុទ្ធសាស្ត្រជាតិ ដែលរៀបចំដោយ គ.ជ.ប.ជ. កាលពីខែកក្កដា ឆ្នាំ ២០២១

ពាក់ព័ន្ធ ជាពិសេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបំពេញតួនាទីយ៉ាងសកម្ម ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនបន្តទៅប្រព័ន្ធយុត្តិធម៌។[7]

- ក្រសួងយុត្តិធម៌បានរាយការណ៍ថា បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការជួយជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងបានរៀបចំកិច្ចប្រជុំជាមួយក្រសួងស្ថាប័នពាក់ព័ន្ធស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកំណត់ពីបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយជាដើម។

> *"វគ្គបណ្តុះបណ្តាលមួយចំនួនសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាត្រូវពន្យារពេលដោយសារតែជំងឺកូវីដ ១៩"*
> ក្រុមការងារកិច្ចការយុត្តិធម៌

**៣.២ ការលើកកម្ពស់សមត្ថភាពមន្រ្តី ស្ថាប័នពាក់ព័ន្ធ ក្នុងការងារបង្ការទប់ស្កាត់**

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. បានចាត់វិធានការគ្រប់គ្រងស្ថានភាពទទួល និងបញ្ជូនពលករទេសន្តរប្រវេសន៍ នៅតាមបណ្តោយព្រំដែន និងធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍ ដែលគោរពតាមវិធានការរក្សាគម្លាតសុវត្ថិភាព ចាប់តាំងពីពេលមានការបិទព្រំដែនថៃដំបូង។
- ក្រសួងយុត្តិធម៌បានរាយការណ៍ថា បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ដល់មន្រ្តីអនុវត្តច្បាប់ដើម្បីពង្រឹងការងារស៊ើបអង្កេត។

**៣.៣ ពង្រឹងសមត្ថភាពមន្រ្តីអនុវត្តច្បាប់ និងមន្រ្តីក្នុងស្ថាប័នអយ្យការ ឱ្យកាន់តែប្រសើរឡើង ក្នុងការដោះស្រាយករណីជួញដូរមនុស្ស**

- នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន ជាមួយស្នងការដ្ឋាននគរបាលរាជធានី-ខេត្តនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងនាយកដ្ឋានប្រឆាំងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា នៃកងរាជអាវុធហត្ថផ្ទៃប្រទេស បានតាមដាន ស៊ើបអង្កេត និងចាត់វិធានការលើជនសង្ស័យប្រព្រឹត្តអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ សរុប ១៩៨ ករណី ធៀបនឹង ៦៣ ករណីក្នុងឆមាសទី ១ ឆ្នាំ ២០២០។ លើសពីនេះ ជនល្មើស ២៩១ នាក់ (ស្រី ៣១ នាក់) ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅសាលាដំបូង។ ក្នុងចំណោមជនល្មើសទាំង ២៩១ នាក់ ជនសង្ស័យ ១៣ នាក់ជាអនីតិជន ជនជាតិវៀតណាម ៣ នាក់ និងជនជាតិប៊ែលស៊ីកម្នាក់។ មានការសង្គ្រោះជនរងគ្រោះចំនួន ៧២១ នាក់ ក្នុងនោះ ៨៨ នាក់អាយុក្រោម ១៥ឆ្នាំ ជនរងគ្រោះ ៦៣នាក់ អាយុចន្លោះពី ១៥ ដល់ ១៧ឆ្នាំ ៥៧០នាក់ អាយុលើស ១៨ឆ្នាំ។ ជនរងគ្រោះ ២៥ នាក់ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយជនរងគ្រោះ ៦៩៦ នាក់ត្រូវបានបញ្ជូនទៅក្រុមគ្រួសាររបស់ពួកគេវិញ។
- សកម្មភាពដែលអនុវត្តដោយព្រះរាជអាជ្ញា នៃតុលាការរាជធានីខេត្ត៖ បើតាមរបាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ. មាន ៤០៥ ករណី។ ជនរងគ្រោះមានចំនួន ៣៤៤ នាក់ (ស្រី

[7] Ibid.

១៦២ នាក់) និងក្នុងចំណោមជនរងគ្រោះទាំងនេះ ១៤២ នាក់ (ស្រី ៧៥ នាក់) ជាអនីតិជន។ ចុងចោទមានចំនួន ៤៣៨ នាក់ (ស្រី ១៦០ នាក់) ក្នុងនោះចុងចោទ ១៥ នាក់ (ស្រី ២ នាក់) គឺជាអនីតិជន។ ករណីចំនួន ៣៨៤ករណីត្រូវបានបញ្ជូនទៅស៊ើបសួរ ១០ករណីនៅបន្តមិនទាន់បានដោះស្រាយ ៧ករណីត្រូវបានបញ្ជូនទៅចោទប្រកាន់ ២ករណីកំពុងឆ្លងកាត់នីតិវិធីនាពេលបច្ចុប្បន្ន និង ៤២ករណីកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការ។

- សកម្មភាពដែលអនុវត្តដោយចៅក្រមស៊ើបសួរ នៃតុលាការរាជធានីខេត្តៈ បើតាមរបាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ. មាន ៣៣២ករណី និងជនរងគ្រោះចំនួន ៣៩៦នាក់ (ស្រី ១៨១ នាក់) និងមានជនរងគ្រោះចំនួន ១៣៨នាក់ជាអនីតិជន (ស្រី ១២៣នាក់)។ ចុងចោទមានចំនួន ៤៥៤នាក់ (ស្រី ៩២នាក់) ហើយចុងចោទ ៧៥នាក់ (ស្រី ១០នាក់) គឺជាអនីតិជន។ ករណីចំនួន ១១៧ករណីត្រូវបានបញ្ជូនទៅចោទប្រកាន់ ៥ករណីត្រូវបានទំលាក់ចោល និង ២១០ករណីត្រូវបានបញ្ជូនទៅរកនីតិវិធីតុលាការជាបន្តទៀត។ ជំណាក់កាលចៅក្រមជំនុំជម្រះក្នុងតុលាការរាជធានីខេត្តៈ បើតាមរបាយការណ៍ឆមាសទី១ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ. មាន ២០៤ ករណីដែលមានជនរងគ្រោះចំនួន ១៨៧នាក់ (ស្រី ៨១ នាក់) និងជនរងគ្រោះ ៨៣នាក់ (ស្រី ៧៥ នាក់) ជាអនីតិជន។ ចុងចោទមានចំនួន ១៩៩នាក់ (ស្រី ៨៦នាក់)។ ករណីទាំងនេះត្រូវបានបែងចែកជាប្រភេទដូចតទៅៈ ចុងចោទ ២នាក់ត្រូវបានព្យួរទោស ១ករណីត្រូវបានពិន័យ ៤ករណីត្រូវបានទំលាក់ចោល និង ៦៥ករណីត្រូវបានបញ្ចប់រួចរាល់ ៣៧ករណីដាក់ពន្ធនាគារ និង ១៣៩ករណីកំពុងស្ថិតក្នុងនីតិវិធីតុលាការ។
- ក្រសួងយុត្តិធម៌រាយការណ៍ថា ខ្លួនបានសហការជាមួយនឹងកម្មវិធីអូស្ត្រាលី-អាស៊ីប្រឆាំងអំពើជួញដូរមនុស្ស (AAPTIP) ដើម្បីបណ្តុះបណ្តាលគ្រូបង្គោលប្រឆាំងអំពើជួញដូរមនុស្ស។
- ក្រសួងយុត្តិធម៌រាយការណ៍ថា បានបណ្តុះបណ្តាលចៅក្រមនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការផងដែរ។

### ៣.៤.៣.២ បញ្ហាប្រឈម និងអាទិភាពដែលនៅមាន

- ការស៊ើបអង្កេតលើករណីជួញដូរមនុស្សនៅតែជាបញ្ហាប្រឈម។ បញ្ហាថវិកានៅមានកម្រិត សាក្សី និងគ្រួសារមិនសហការ និងមិនមានឆន្ទៈចូលរួម និងកង្វះមន្ត្រីស៊ើបអង្កេតជំនាញ សុទ្ធតែរួមចំណែកនាំឱ្យការស៊ើបអង្កេត និងការចោទប្រកាន់ជួបប្រទះនឹងបញ្ហាប្រឈមផ្សេងៗ។
- អ្នកផ្តល់សេវាមួយចំនួនបានរាយការណ៍ថា ការចំណាយលើនីតិវិធីតុលាការ និងចំណាយផ្សេងទៀត (មិនអាចទៅធ្វើការបាន ចំណាយលើការធ្វើដំណើរ) ជាកត្តារារាំងជនរងគ្រោះមិនឱ្យស្វែងរកជំនួយក្នុងប្រព័ន្ធយុត្តិធម៌។
- ទីតាំងភូមិសាស្ត្រសម្រាប់អនុវត្តសកម្មភាពអន្តរាគមន៍ ជួយដល់ជនរងគ្រោះហាក់បីដូចជា មានការលំបាក ព្រោះករណីមួយចំនួនកើតនៅតាមច្រករបៀង ដែលធ្វើឱ្យអាជ្ញាធរមានការលំបាកក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

- ពាក់ព័ន្ធនឹងអាទិភាពនៅក្នុងយុទ្ធសាស្ត្រផ្សេងទៀត មានការលើកឡើងជាអនុសាសន៍ ឱ្យមានការបង្កើតប្រព័ន្ធទិន្នន័យជាក់លាក់គ្រប់ជ្រុងជ្រោយ ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ប្រមូលព័ត៌មាន និងធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រសួងស្ថាប័នពាក់ព័ន្ធទៅតាមការចាំបាច់។

## ៣.៤.៤ យុទ្ធសាស្ត្រទី ៤៖ បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ

| ចង្កោមសកម្មភាព | សូចនាករ |
|---|---|
| **៤.១ ពង្រឹងការអនុវត្តបែបបទនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងផ្តល់សេវាចាំបាច់បឋមសមស្រប ព្រមទាំងការថែទាំប្រកបដោយគុណភាព ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសស្ត្រី និងកុមារ** | • ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់<br>• មន្ត្រីទទួលបានការបណ្តុះបណ្តាលនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវា និងបទដ្ឋានអប្បរមាសម្រាប់ថែទាំជូនជនរងគ្រោះ |
| **៤.២ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវា រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យកាន់តែល្អប្រសើរ ដើម្បីឱ្យជនរងគ្រោះជាពិសេសស្ត្រី និងកុមារ ទទួលបានសេវាគាំទ្រ និងថែទាំបានរហ័សដល់ដៃ ឆ្លើយតបនឹងតម្រូវការចាំបាច់** | • ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវា<br>• ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍<br>• លិខិតបទដ្ឋានពាក់ព័ន្ធ និងការផ្តល់នីតិសម្បទាដល់ជងរងគ្រោះ ត្រូវបានបង្កើត<br>• សក្តានុពលពង្រីកចំណូលដល់ពលករ ត្រូវបានរកឃើញ<br>• មូលហេតុធ្វើឱ្យមានចំណាកស្រុកច្រើន ត្រូវបានរកឃើញ |

យុទ្ធសាស្ត្រទី ៤ ផ្តោតលើការការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ និងមានការសម្របសម្រួលដោយក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការចូលរួមពីក្រសួងស្ថាប័នផ្សេងទៀត។ យុទ្ធសាស្ត្រនេះមានចង្កោមសកម្មភាពចំនួន ២។ ខាងក្រោមនេះ គឺជាការរៀបរាប់ដោយសង្ខេបពីវឌ្ឍនភាពដែលសម្រេចបាន។

### *៣.៤.៤.១ វឌ្ឍនភាព*

**៤.១ ពង្រឹងការអនុវត្តបែបបទនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងផ្តល់សេវាចាំបាច់បឋមសមស្រប ព្រមទាំងការថែទាំប្រកបដោយគុណភាព ជូនជនរងគ្រោះនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសស្ត្រី និងកុមារ**

- ការបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលមានការចូលរួមពីតំណាងរដ្ឋាភិបាល ចំនួន ៥៣នាក់ (ស្រី ៣០នាក់) ដើម្បីបង្កើនសមត្ថភាពកំណត់អត្តសញ្ញាណជនរងគ្រោះ និងបច្ចេកទេសសម្ភាសជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានធ្វើឡើងដោយមានការគាំទ្រពីកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ របស់ UN Women ក្នុងឆ្នាំ ២០១៩។
- សិក្ខាសាលាស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៅក្នុងខេត្តសៀមរាប នៅថ្ងៃទី ២៨-២៩ ខែកញ្ញា ដឹកនាំដោយ គ.ខ.ប.ជ. (របាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។
- គ.ជ.ប.ជ. បានជួបពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា អំពីកម្មវិធីបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន ផ្តោតលើការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ដើម្បីបញ្ជូនទៅរកសេវាសមស្រប (របាយការណ៍ឆមាសទី១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.)។

**៤.២ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវា រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យកាន់តែល្អប្រសើរ ដើម្បីឱ្យជនរងគ្រោះជាពិសេសស្ត្រី និងកុមារ ទទួលបានសេវាគាំទ្រ និងថែទាំបានរហ័សដល់ដៃ ឆ្លើយតបនឹងតម្រូវការចាំបាច់**

- មន្ត្រីមកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ដើម្បីវាយតម្លៃលើប្រជាពលរដ្ឋចំនួន ៣០គ្រួសារ ដែលត្រូវបានជួញដូរក្នុងខេត្ត-រាជធានីចំនួន ២៥ នេះបើតាមរបាយការណ៍ឆមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។
- ក្រុមការងារការពារជនរងគ្រោះ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ទទួលយកមនុស្សចំនួន ២២នាក់ (ស្រី ១៣នាក់ ក្មេងប្រុសម្នាក់ និងក្មេងស្រី ៥នាក់) ដែលងាយរងគ្រោះ ឬរងគ្រោះដោយសារអំពើជួញដូរមនុស្សនេះបើតាមរបាយការណ៍ត្រីមាសទី ២ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។
- មណ្ឌលទទួលពលករទេសន្តរប្រវេសន៍ត្រូវបានបង្កើតឡើង ដោយមានការគាំទ្រពីវិស័យឯកជន នៅតាមព្រំដែនកម្ពុជា-ថៃក្នុងខេត្តបាត់ដំបង។ មណ្ឌលនេះជួយសម្រួលដល់ពលករទេសន្តរប្រវេសន៍ ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។
- នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសជនរងគ្រោះ ដែលធ្វើមាតុភូមិនិវត្តន៍ ពីក្រៅប្រទេសតាមរយៈប្រព័ន្ធ Zoom។ ជនរងគ្រោះ ២៨នាក់មកពីប្រទេសចិន និងមានម្នាក់មកពីប្រទេសសិង្ហបុរី។ លទ្ធផលនៃការសម្ភាសបង្ហាញថា ជនរងគ្រោះ ២៨នាក់ ដែលមកពីប្រទេសចិន ត្រូវបានទិញដោយមេខ្យល់ដែលមិនស្គាល់អត្តសញ្ញាណ ហើយម្នាក់មកពីសិង្ហបុរី បានឆ្លងកាត់តាមក្រុមហ៊ុនមួយ នេះបើតាមរបាយការណ៍ត្រីមាសទី២ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។

> *"យើងត្រូវការគាំទ្រ ដើម្បីឱ្យក្រសួងហិរញ្ញវត្ថុផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការសកម្មភាព និងឆ្លើយតបចំពោះតម្រូវការជនរងគ្រោះ"*
> ក្រុមការងារការពារជនរងគ្រោះ

- ក្រុមការងារការពារជនរងគ្រោះ និងមន្ទីរសង្គមកិច្ចអតីយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ផ្តល់ការស្នាក់នៅដល់ជនរងគ្រោះចំនួន ៥៧នាក់ និងជួយដល់ការស្តារនីតិសម្បទាពួកគេឡើងវិញ បើតាមរបាយការណ៍ត្រីមាសទី ២ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាដៃគូ ធ្វើសមាហរណកម្មជនរងគ្រោះ និងអ្នកដែលងាយរងគ្រោះដោយសារអំពើជួញដូរមនុស្សចំនួន ៥២នាក់ ទៅក្នុងសហគមន៍របស់ពួកគេ នេះបើតាមរបាយការណ៍ត្រីមាសទី ២ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។
- គ.ជ.ប.ជ. បានសហការក្នុងរៀបចំគោលនយោបាយស្តីពីសុខភាពជនទេសន្តប្រវេសន៍ បច្ចុប្បន្ននេះកំពុងមានការវាយតម្លៃ ដើម្បីស្វែងយល់ពីវិធីសាស្ត្រ ដើម្បីសម្រេចគោលដៅក្នុងគោលនយោបាយនេះ។
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈតំណាងស្ថានទូត បានជួយសង្គ្រោះ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលករដែលត្រូវបានកំណត់អត្តសញ្ញាណបឋមថាជាជនរងគ្រោះនៃការងារខុសច្បាប់ និងជនរងគ្រោះដែលត្រូវបានគេសង្ស័យថា រងគ្រោះដោយអំពើជួញដូរមនុស្ស សរុបចំនួន ១.០៦៦ នាក់ (ស្រី ៥០៣ នាក់)។ ពលករខុសច្បាប់មានចំនួន ៧៣៣ នាក់ (ស្រី ២៤០ នាក់) មកពីប្រទេសថៃ នេះបើតាមរបាយការណ៍ត្រីមាសទី ២ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។
- គ.ខ.ប.ជ. ទាំងអស់បានលើកឡើងនៅក្នុងការសម្ភាសថា ពួកគេបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដើម្បីផ្តល់សេវាដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស។ កិច្ចសហប្រតិបត្តិការនេះ ត្រូវបានលើកឡើងថាជាជោគជ័យដ៏សំខាន់មួយ។
- គ.ខ.ប.ជ. ក្នុងខេត្តកំពង់ធំលើកឡើងថាពួកគេបានជួយជនរងគ្រោះ ដែលរងការកេងប្រវ័ញ្ចនៅក្នុងប្រទេសម៉ាឡេស៊ី ដោយបានសហការជាមួយ ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល។ ជនរងគ្រោះមួយចំនួនបានទទួលការគាំទ្រឱ្យចាប់ផ្តើមអាជីវកម្មខ្នាតតូច ដើម្បីរកប្រាក់ចំណូលដោយខ្លួនឯង។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលរួមធ្វើជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល អំពីការធ្វើផែនការសមាហរណកម្មពលករទេសន្តប្រវេសន៍ ដែលរៀបចំដោយអង្គការ CWCC នៅទីក្រុងភ្នំពេញ នេះបើតាមរបាយការណ៍ត្រីមាសទី ១ ឆ្នាំ ២០២១ របស់ គ.ជ.ប.ជ.។

- ក្រុមការងារទំនាក់ទំនងអន្តរជាតិ បានរាយការណ៍ថាមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន សហរដ្ឋអាមេរិក និងប្រទេសគោលដៅដទៃទៀត ដើម្បីឆ្លើយតបចំពោះករណីជួញដូរមនុស្ស គ្រប់រូបភាព និងក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ។

### *៣.៤.៤.២ បញ្ហាប្រឈម និងអាទិភាពដែលនៅសេសសល់*

- កាលពីឆ្នាំ ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ប៉ុន្តែស្ថាប័នទទួលខុសត្រូវមិនទាន់បានយកគោលការណ៍ណែនាំនេះ ទៅប្រើប្រាស់ឱ្យបានត្រឹមត្រូវ ឬមានសង្គតិភាពនៅឡើយ។ កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ទម្រង់ស្តង់ដារក្នុងចំណោមតួអង្គពាក់ព័ន្ធនានា ដូចជា (ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល) ជាដើម នៅតែជាបញ្ហាប្រឈមនាំឱ្យដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះជួបនឹងភាពស្មុគស្មាញ។
- ក្នុងពេលជាមួយគ្នា ជនរងគ្រោះមានការស្ទាក់ស្ទើរក្នុងការបង្ហាញពីបទពិសោធន៍របស់ពួកគេ ដោយសារតែឧបសគ្គនានា ដូចជាការម៉ាក់ងាយ ការរើសអើង គួបផ្សំនឹងអ្នកសម្ភាសដែលពុំមានជំនាញកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានច្បាស់លាស់។ ដូច្នេះចាំបាច់ត្រូវមានការពិនិត្យលើគោលការណ៍ណែនាំទាំងនេះឡើងវិញ និងផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រី ស្ថាប័ន ព្រមទាំងអង្គការពាក់ព័ន្ធអំពីការអនុវត្តគោលការណ៍ណែនាំនេះ។
- ការពុំមានថវិកាគ្រប់គ្រាន់ គឺជាកត្តាបន្ទុចបង្អាក់ដល់ការផ្តល់សេវាឱ្យបានគ្រប់គ្រាន់ ដល់ជនរងគ្រោះ និងការតាមដានបន្ត។ តម្រូវការផ្នែកធនធានផ្សេងៗមានជាច្រើនដូចជា ជម្រកបណ្តោះអាសន្ន ចំនួនភ្នាក់ងារគ្រប់គ្រងករណី សេវាថែទាំសុខភាព សេវាគាំទ្រចិត្តសង្គម និងការគាំទ្រផ្សេងទៀត ដើម្បីជួយជនរងគ្រោះក្នុងការធ្វើមាតុភូមិនិវត្តន៍ដោយពេញលេញ រួមទាំងសំបុត្រយន្តហោះ ការរក្សាសុវត្ថិភាពពេលធ្វើដំណើរ ឬក្នុងពេលធ្វើចត្តាឡីស័ក និងសេវាគាំទ្រដទៃទៀត។ ការវិនិយោគឃុំ/សង្កាត់ ក៏ពុំបានបញ្ចូលថវិកាសម្រាប់ធ្វើសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្សនោះទេ។

# ៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ស្ថានភាពជារួម

ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៩-២០២៣ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានរៀបចំឡើង ដោយប្រើប្រាស់ដំណើរការដែលមានការចូលរួមពីថ្នាក់ដឹកនាំនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ.។ បើទោះបីជាផែនការនេះត្រូវបានអនុវត្តក្នុងអំឡុងពេលមានការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ដែលនាំឱ្យបរិបទមានការប្រែប្រួលភ្លាមៗ ព្រោះតែមានការរឹតត្បិតលើការធ្វើដំណើរ ពលករទេសន្តរប្រវេសន៍រាប់ពាន់នាក់ដែលបានធ្វើមាតុភូមិនិវត្តន៍មកវិញ ហានិភ័យថ្មីៗនៃការជួញដូរមនុស្ស ព្រមទាំងបញ្ហាប្រឈមដទៃទៀតក៏ដោយ ក៏ក្រុមការងារវាយតម្លៃសង្កេតឃើញថាកម្ពុជាសម្រេចបានវឌ្ឍនភាពមួយចំនួនពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ទោះជាបែបនេះក្តី ក៏នៅមាន

ការងារសេសសល់ជាច្រើន ដើម្បីធានាថាវិធានការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សត្រូវបានអនុវត្ត ហើយយន្តការនេះដំណើរការទៅបានគ្រប់គ្រាន់ ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។

ផែនការយុទ្ធសាស្ត្រជាតិ គឺជាឯកសារតម្រង់ទិសដល់ការធ្វើផែនការសកម្មភាពរបស់ គ.ជ.ប.ជ. ក្រុមការងារជំនាញ និង គ.ខ.ប.ជ.។ ដូច្នេះភាគីពាក់ព័ន្ធចាំបាច់ ត្រូវស្វែងយល់ឱ្យបានស៊ីជម្រៅពីផែនការយុទ្ធសាស្ត្រជាតិនេះ ក៏ដូចជាសកម្មភាព និងសូចនាករដែលត្រូវបានដាក់ចេញ។ ផែនការសកម្មភាពជាតិ ត្រូវបានលើកឡើងថា មានសកម្មភាពដ៏ច្រើន (២៣៥ សកម្មភាព) ព្រមទាំងសូចនាករ ដែលអ្នកឆ្លើយតបមួយចំនួនបានលើកឡើងថា មានការយល់ដឹងនៅមានកំណត់ ហើយមួយចំនួនទៀតលើកឡើងថា សូចនាករមានចំនួនច្រើនពេក។ ជាអនុសាសន៍ ស្ថាប័នពាក់ព័ន្ធគួរៈ

- បង្កើនការយល់ដឹងអំពីផែនការយុទ្ធសាស្ត្រជាតិនេះ ដើម្បីជួយឱ្យ គ.ខ.ប.ជ. ក្រុមការងារជំនាញ អាចធ្វើផែនការសកម្មភាព និងអនុវត្តសកម្មភាពរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ គួរមានការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ដើម្បីឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់យល់កាន់តែស៊ីជម្រៅបន្ថែម ពីសកម្មភាព និងអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។
- ធ្វើការវាយតម្លៃឡើងវិញលើសូចនាករនៃផែនការយុទ្ធសាស្ត្រជាតិ ***ដើម្បីបន្ថយចំនួន ប្រសិនបើអាចធ្វើទៅបាន និងកំណត់អាទិភាព*** ពីលទ្ធផលរំពឹងទុក និងសកម្មភាពដែលត្រូវបញ្ចប់ក្នុងក្របខណ្ឌពេលវេលានៃផែនការនេះ។ ត្រូវប្រាកដថាតួអង្គពាក់ព័ន្ធសំខាន់ៗ យល់ច្បាស់ពីសូចនាករទាំងនេះ ហើយគេអាចវាស់វែងសូចនាករទាំងនេះបាន ជាមួយនឹងប្រភពទិន្នន័យដែលមាន (ភ្ជាប់ទំនាក់ទំនងជាមួយនឹងរបាយការណ៍ប្រចាំឆ្នាំ)។

ការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ បានបង្កផលប៉ះពាល់ដល់ការអនុវត្តផែនការសកម្មភាពជាតិ ដោយសារការរឹតត្បិតលើការធ្វើដំណើរ លទ្ធភាពរៀបចំកិច្ចប្រជុំ បញ្ហាប្រឈមថ្មីៗជាមួយនឹងប្រជាជនទូទៅ ដូចជាពលករទេសន្តរប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញជាដើម។ ការឆ្លើយតបចំពោះជំងឺកូវីដ១៩ ត្រូវការពេលវេលា និងថវិកា។ ប៉ុន្តែនៅពេលអាចធ្វើបាន ភាគីពាក់ព័ន្ធគួរសម្របខ្លួន ដើម្បីបន្តជួបប្រជុំ និងអនុវត្តសកម្មភាពនានា ដូចជាការបង្ការទប់ស្កាត់ និងការឆ្លើយតបចំពោះតម្រូវការជនរងគ្រោះជាដើម។ បើទោះជាយ៉ាងណាក៏ដោយ ដោយសារតែមានបញ្ហាប្រឈមទាំងនេះ ជាអនុសាសន៍ៈ

- គួរឱ្យក្រុមការងារជំនាញនីមួយៗ ផ្តោតអាទិភាពលើសកម្មភាពរបស់ខ្លួនតាមរយៈផែនការការងារដោយពិចារណាលើការពន្យារពេលផ្សេងៗ ដើម្បីឱ្យផែនការនេះមានលក្ខណៈប្រាកដនិយម ជុំវិញអ្វីដែលអាចសម្រេចទៅបានក្នុងរយៈពេលដែលនៅសេសសល់។
- ក្រុមការងារជំនាញ គួរផ្តល់អាទិភាពដល់សកម្មភាពទាំងឡាយ ដែលធ្វើឱ្យដំណើរប្រព្រឹត្តទៅនៃយន្តការ នេះកាន់តែមានភាពល្អប្រសើរ ដូចជាលទ្ធភាពបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះករណី

ជួញដូរមនុស្ស។ គួរមានការសម្របខ្លួន អាស្រ័យដោយសារវត្តមានបញ្ហាថ្មីៗដែលកើតឡើង បណ្តាលមកពីជំងឺកូវីដ១៩ និងអ្វីដែលអាចសម្រេចទៅបានតាមស្ថានភាពជាក់ស្តែង។ ឧទាហរណ៍ ការបណ្តុះបណ្តាល ការធ្វើផែនការ និងផ្សព្វផ្សាយព័ត៌មានអំពីផែនការយុទ្ធសាស្ត្រជាតិ អាចប្តូរទៅធ្វើតាមប្រព័ន្ធអនឡាញវិញ នៅពេលដែលអាចធ្វើទៅបាន ដោយគេអាចពង្រឹងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ប្រសិនបើវាជាឧបសគ្គ ហើយគេអាចឯកភាពគ្នាជាមុន លើសារអប់រំផ្សព្វផ្សាយ អំពីការបង្ការទប់ស្កាត់ មុននឹងយកទៅផ្សព្វផ្សាយតាមក្រុមតូច ឬតាមរយៈបណ្តាញទំនាក់ទំនងសង្គម វិទ្យុ ឬទូរទស្សន៍ – ដោយត្រូវសម្របទៅតាមកាលៈទេសៈជាក់ស្តែងសម្រាប់យុទ្ធសាស្ត្រនីមួយៗ។ នៅពេលដែលចាំបាច់ត្រូវមានការជួបប្រជុំផ្ទាល់នៅនឹងកន្លែង ចាំបាច់ត្រូវតែមានការផ្តល់ឧបករណ៍ការពារខ្លួន (PPE) ឱ្យបានសមស្រប ដល់បុគ្គលិក និងជនរងគ្រោះ ព្រមទាំងគ្រួសាររបស់ពួកគេ។

## ដំណើរប្រព្រឹត្តទៅរបស់យន្តការ

យន្តការ សម្រាប់បង្ការទប់ស្កាត់ និងឆ្លើយតបចំពោះករណីជួញដូរមនុស្ស មានរចនាសម្ព័ន្ធច្បាស់លាស់។ មានការកំណត់ពីតួនាទី និងការទទួលខុសត្រូវបានច្បាស់លាស់។ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. បានផ្តល់កិច្ចសម្របសម្រួលសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិ តាមរយៈក្រុមការងារជំនាញចំនួន ៦ និង គ.រ/ខ.ប.ជ. ដែលមានការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ។ ដើម្បីធ្វើឱ្យយន្តការនេះកាន់តែមានភាពប្រសើរជាងនេះ ក្រុមការងារវាយតម្លៃផ្តល់អនុសាសន៍ដូចខាងក្រោម៖

### ការកសាងសមត្ថភាព

- បន្តកសាងសមត្ថភាពអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. លេខាធិការដ្ឋាន គ.រ/ខ.ប.ជ. ក្រុមការងារជំនាញ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រាជធានី-ខេត្ត ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ អំពីច្បាប់ និងគោលនយោបាយ យុទ្ធសាស្ត្រ និងគម្រូអនុវត្តល្អ ដើម្បីជួយឱ្យពួកគេអាចបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនបានល្អប្រសើរ។
- បន្តកសាងសមត្ថភាពគ្រូបង្គោលនៃលេខាធិការដ្ឋាន គ.ខ.ប.ជ. ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ការគាំទ្រដល់ជនរងគ្រោះ ចំណេះដឹងអំពីការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ ការធ្វើផែនការ ការរៀបចំរបាយការណ៍ និងការគ្រប់គ្រងទិន្នន័យ។
- រៀបចំ "យន្តការផ្តល់ការបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងការងារ" ដើម្បីឱ្យមានការចែករំលែកចំណេះដឹង បទពិសោធន៍ជាក់ស្តែង ការណែនាំរវាងមន្ត្រីថ្មី និងមន្ត្រីដែលមានបទពិសោធន៍ ដែលនឹងចូលនិវត្តន៍ ឬប្តូរទៅកន្លែងធ្វើការផ្សេងទៀត ក្នុងក្របខណ្ឌ គ.ជ.ប.ជ. ក្រុមការងារជំនាញ និង គ.ខ.ប.ជ.។

### ធនធាន

- ធានាថាយន្តការនេះ មានធនធានគ្រប់គ្រាន់ នៅគ្រប់កម្រិតទាំងអស់ (គ.ជ.ប.ជ. ក្រុមការងារជំនាញ គ.ខ.ប.ជ.) សម្រាប់បុគ្គលិក និងសម្រាប់ការអនុវត្តចង្កោមសកម្មភាពនៅក្នុងយុទ្ធសាស្ត្រនីមួយៗ ។

## ការអនុវត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

- ផែនការយុទ្ធសាស្ត្រជាតិនេះ អាចបន្តធ្វើមូលដ្ឋាននីយកម្ម ក្នុងក្របខណ្ឌក្រុមការងារជំនាញ និង គ.ខ.ប.ជ. ដើម្បីធានាឱ្យមានការរៀបចំ អនុវត្ត និងពិនិត្យតាមដាន ផែនការការងារឱ្យបានសមស្រប នៅតាមកម្រិតនីមួយៗ។ ចំណុចនេះគួរភ្ជាប់ទំនាក់ទំនងជាមួយនឹងសូចនាករថ្នាក់ជាតិ ស្របតាមបរិបទនីមួយៗ។
    - ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍ស្តីពីអំពើជួញដូរមនុស្ស គឺជាអាទិភាពមួយ។ បច្ចុប្បន្នពុំមានប្រព័ន្ធសម្រាប់តាមដានការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងករណីជួញដូរមនុស្សនៅឡើយ។ មិនទាន់មានប្រព័ន្ធទិន្នន័យថ្នាក់ជាតិ សម្រាប់ពិនិត្យតាមដាន ប្រមូល និង រាយការណ៍ទិន្នន័យ អំពីការចោទប្រកាន់បទល្មើសជួញដូរមនុស្ស និងកិច្ចខិតខំប្រឹងប្រែងការពារជនរងគ្រោះនៅឡើយ។ ដូច្នេះ ជាអនុសាសន៍ គ.ជ.ប.ជ. ក្រុមការងារជំនាញ និង គ.ខ.ប.ជ. ត្រូវមានយន្តការពិនិត្យតាមដាន សម្រាប់តាមដានការអនុវត្តយុទ្ធសាស្ត្រនីមួយៗ ដើម្បីទទួលបានជោគជ័យក្នុងការអនុវត្តចង្កោមសកម្មភាពនីមួយៗ និងត្រូវមានយន្តការឱ្យបានច្បាស់លាស់លើការរៀបចំរបាយការណ៍។ ត្រូវធានាថាទម្រង់របាយការណ៍ត្រូវបានភ្ជាប់ទំនាក់ទំនងឱ្យបានគ្រប់ជ្រុងជ្រោយជាមួយនឹងផែនការការងារ និងសូចនាករនានា។ គេអាចតាមដានរបាយការណ៍ និងតាមដានសកម្មភាពតាមរយៈប្រព័ន្ធទិន្នន័យបាន។
- គ.ជ.ប.ជ. គួរបង្កើតមជ្ឈមណ្ឌលទិន្នន័យមួយ ដែលប្រមូលផ្តុំគ្រប់ព័ត៌មានទាំងអស់អំពីករណីជួញដូរមនុស្សនៅថ្នាក់ជាតិ និងធ្វើការសម្របសម្រួលជាមួយដៃគូអន្តរជាតិនានា ហើយក្នុងពេលជាមួយគ្នាត្រូវធានាឱ្យមានការរក្សាឯកជនភាព និងការរក្សាការសម្ងាត់ជូនបុគ្គលពាក់ព័ន្ធ (ទំនាក់ទំនងជាមួយនឹងយុទ្ធសាស្ត្រទី ១)។ ដើម្បីសម្រេចគោលដៅនេះ គួរមានការវាយតម្លៃលើយន្តការដែលមានស្រាប់នៅតាមក្រសួងស្ថាប័ននានា ដើម្បីកំណត់ពីវឌ្ឍនភាព បញ្ហាដែលនៅរាំងស្ទះ និងជំហានបន្ទាប់ ដើម្បីឈានទៅបង្កើតមជ្ឈមណ្ឌលទិន្នន័យមួយ ហើយក្នុងពេលជាមួយគ្នាដែរ ធានាថាជនរងគ្រោះទទួលបានសិទ្ធិរក្សាឯកជនភាពរបស់ពួកគេ។
- គួរបញ្ជាក់ពីតួនាទី និងអាទិភាពរបស់ គ.ជ.ប.ជ. ក្រុមការងារជំនាញ និងក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការ ការធ្វើការងារបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និងទំនាក់ទំនងរវាងក្រុមការងារជំនាញ ព្រមទាំងធានាឱ្យមានការរៀបចំរបាយការណ៍គ្រប់ជ្រុងជ្រោយអំពីការអនុវត្តយុទ្ធសាស្ត្រនានានៅក្នុងផែនការយុទ្ធសាស្ត្រជាតិ។
- បង្កើនកិច្ចសហការក្នុងក្របខណ្ឌក្រុមការងារជំនាញ និងរវាងក្រុមការងារជំនាញ ជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដោយប្រើប្រាស់អភិក្រមគ្រប់ជ្រុងជ្រោយជាយុទ្ធសាស្ត្រ ដើម្បីធានាឱ្យមានការសម្របសម្រួល និងការអនុវត្តសកម្មភាពបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ គេអាចចាប់ផ្តើមចំណុចនេះបានដោយប្រើប្រាស់ការវាយតម្លៃមួយ ដើម្បីស្វែងយល់ពីការងារដែលត្រួតគ្នា និងដឹងពី

ចំណុចសមស្របដែលអាចបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និងមធ្យោបាយល្អសម្រាប់ទំនាក់ទំនងជាមួយគ្នា ដើម្បីជានាឱ្យមានកិច្ចសហប្រតិបត្តិការដែលកាន់តែមានប្រសិទ្ធភាព។

- រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងជាទៀងទាត់ដើម្បី ចែករំលែកគម្រូអនុវត្តល្អ មេរៀន និងបទពិសោធន៍ ជុំវិញការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ ដើម្បីពិនិត្យសកម្មភាពដែលបានគ្រោងទុក និងដើម្បីកំណត់ពីបញ្ហាប្រឈម និងរបៀបឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនោះ។
- ចងក្រងទុកជាឯកសារពីគម្រូអនុវត្តល្អនានា ដូចជាការសម្របសម្រួល ការសហការ និងការធ្វើប្រតិភូកម្មការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការផ្តល់ជំនួយដល់ជនរងគ្រោះ ក៏ដូចជាគាំទ្រដល់អ្នកដែលរួចរស់ពីអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេអាចធ្វើសកម្មភាពរកចំណូលដោយខ្លួនឯងបាន។

## យុទ្ធសាស្រ្តទី ១៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការធ្វើផែនការ គឺជាការងារចាំបាច់ ដើម្បីធានាឱ្យមានការរៀបចំសកម្មភាពរួមគ្នា សំដៅលុបបំបាត់អំពើជួញដូរមនុស្ស។ ចាំបាច់ត្រូវចាប់យកឱកាសធ្វើផែនការ និងអនុវត្តសកម្មភាពរួមគ្នា ស្របតាមផែនការយុទ្ធសាស្រ្តជាតិរបស់ គ.ជ.ប.ជ. និងអាទិភាពពាក់ព័ន្ធ ដែលមានចែងនៅក្នុងផែនការសកម្មភាពអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស។ ឱកាសមួយចំនួនមានដូចជា៖

- បន្តភ្ជាប់ទំនាក់ទំនង និងចូលរួមជាមួយយន្តការថ្នាក់តំបន់ និងសហការជាមួយ ស្ថាប័ន រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ ដើម្បីធានាឱ្យមានការសម្របសម្រួលសកម្មភាពបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស និងគាំទ្រដល់ជនរងគ្រោះតាមរយៈការផ្តល់សេវា និងការប្រើប្រាស់យន្តការយុត្តិធម៌ឆ្លងដែន។
- ចូលរួមក្នុងការអនុវត្តកតិកាសញ្ញាសកលស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព សណ្តាប់ធ្នាប់ និងស្របច្បាប់ នៅកម្ពុជា។
- បន្តបញ្ជាក់ឱ្យបានច្បាស់លាស់ និងរៀបចំផែនការសកម្មភាព និងពិនិត្យតាមដានការអនុវត្តអនុស្សរណៈជាមួយប្រទេសពាក់ព័ន្ធ។
- បន្តរៀបចំប្រព័ន្ធទិន្នន័យ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីប្រមូលចងក្រង គ្រប់គ្រង និងចែករំលែកទិន្នន័យ ខណៈការពារឯកជនភាព និងសិទ្ធិនានារបស់ជនរងគ្រោះ (សូមមើលអនុសាសន៍ខាងដើម ក្នុងផ្នែកការអនុវត្ត ពិនិត្យតាមដាន និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ)។
- សេចក្តីព្រាងច្បាប់ ដែលនឹងបន្តបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស ដូចជាការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញនៅមិនទាន់មានប្រកាសដាក់ឱ្យអនុវត្តឡើយ ។

**យុទ្ធសាស្ត្រទី ២៖ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ**

កន្លងមកមានការអនុវត្តសកម្មភាពសំខាន់ៗជាច្រើន ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស គ្រប់រូបភាពនៅកម្រិតផ្សេងៗគ្នា។ ការបង្កើនការយល់ដឹងរបស់សហគមន៍ ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងកម្មវិធីតាមសាលារៀន សុទ្ធតែបានរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រនេះ។ យុទ្ធសាស្ត្រនេះមានសកម្មភាពសំខាន់ៗជាច្រើន ប៉ុន្តែនៅតែមានចំណុចដែលត្រូវធ្វើការកែលម្អបន្ថែម។ សំណូមពរមួយចំនួនមានដូចជា៖

- បង្កើតអាទិភាពក្នុងកិច្ចការស្រាវជ្រាវ ដើម្បីផ្តល់ព័ត៌មានជុំវិញអាទិភាពការងារបង្ការទប់ស្កាត់នៅក្នុងរយៈពេលខ្លី ដូចជា តម្លៃជាក់ស្តែងដែលពលរដ្ឋបានចំណាយក្នុងការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ប្រៀបធៀបជាមួយតម្លៃចំណាយនៃការធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ដែលបានកំណត់ដោយរដ្ឋ ថាតើគម្លាតរវាងចំណាយទាំងពីរនេះ មានឥទ្ធិពលយ៉ាងដូចម្តេចខ្លះលើការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន។
- ធានាថា សារអប់រំ ប្រធានបទអប់រំ ត្រូវបានធ្វើបច្ចុប្បន្នភាព និងមានសង្គតិភាព ហើយត្រូវបានចែករំលែកជាមួយនឹងគ្រប់អ្នកធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធទាំងអស់ និងបង្កើនការយល់ដឹងជាសាធារណៈអំពីច្បាប់ គោលនយោបាយ និងហានិភ័យនៃអំពើជួញដូរមនុស្ស និងការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព។ ចំណុចនេះត្រូវមានការកែសម្រួលមួយចំនួន នៅពេលដែលមានការកំណត់ដឹងពីហានិភ័យថ្មីៗនៃអំពើជួញដូរមនុស្ស។
- ពុំមានការប្រមូលចងក្រងជាឯកសារនូវព័ត៌មានអំពីសកម្មភាពបង្ការទប់ស្កាត់ ឱ្យបានល្អនោះឡើយក្នុងគ្រប់ចង្កោមសកម្មភាពទាំងអស់។ ឧទាហរណ៍ សកម្មភាពមួយចំនួនពាក់ព័ន្ធប្រព័ន្ធផ្សព្វផ្សាយ និង វប្បធម៌ ពុំមាននៅក្នុងបញ្ជីសកម្មភាពឡើយ បើទោះជាសកម្មភាពទាំងនោះទំនងជាបានកើតឡើងក៏ ដោយ។ គេត្រូវធានាថាសកម្មភាពទាំងនោះត្រូវបានចាត់ទុកជាអាទិភាព និងមានការចងក្រងព័ត៌មានអំពីការងារនេះនៅក្នុងរបាយការណ៍។
- ការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ បានរំលេចឱ្យឃើញពីការខ្វះឱកាសផ្នែកសេដ្ឋកិច្ចរបស់ប្រជាជនដែលងាយរងគ្រោះជាច្រើននាក់នៅកម្ពុជា។ កម្មវិធីលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ច ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស មានសារៈសំខាន់ខ្លាំងណាស់ ជាពិសេសនៅពេលដែលមានកំណើនសម្ពាធសេដ្ឋកិច្ច ដែលជាកត្តារួមចំណែកនាំឱ្យមានការធ្វើទេសន្តរប្រវេសន៍ទាំងប្រថុយប្រថាន។ ចាំបាច់ ត្រូវមានការអនុវត្តកម្មវិធីបែបនេះបន្ថែមទៀត និងពង្រីកកម្មវិធីដែលកំពុងមានស្រាប់។

**យុទ្ធសាស្ត្រទី ៣៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**

ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សមានសិទ្ធិចូលរួមក្នុងដំណើរការយុត្តិធម៌ ហើយការផ្តន្ទាទោសត្រូវតែធ្វើឡើង ដើម្បីរាំងបន្ទុចបង្អាក់ (បង្ការទប់ស្កាត់) ករណីជួញដូរមនុស្ស។

- បន្តកសាងសមត្ថភាពមន្ត្រីនគរបាល និងមន្ត្រីយុត្តិធម៌ដទៃទៀត ក្នុងការស៊ើបអង្កេត និងផ្តន្ទាទោស ក្នុងករណីជួញដូរមនុស្ស។ ចាំបាច់ត្រូវមានការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីឱ្យមានការស៊ើបអង្កេតឱ្យបានពេញលេញ ទាំងករណីក្នុងប្រទេស ទាំងករណីឆ្លងដែន ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចឆ្លងដែន។
- ត្រូវបន្តកសាងសមត្ថភាពឱ្យបានទៀងទាត់ ដល់មន្ត្រីអនុវត្តច្បាប់ ដើម្បីឱ្យពួកគេចេះទំនាក់ទំនងបានល្អជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ព្រមទាំងក្រុមគ្រួសារតាមបែបផែនដែលផ្តល់នូវការគាំទ្រដោយមិនមានការស្តីបន្ទោស និងដើម្បីអាចប្រមូលព័ត៌មានពាក់ព័ន្ធនឹងករណីនានា នៅពេលធ្វើការស៊ើបអង្កេត។
- បន្តធ្វើការរួមគ្នាជាមួយមន្ត្រីតុលាការ ក៏ដូចជាសហការជាមួយមន្ត្រីនគរបាល និងមន្ទីរនៅថ្នាក់រាជធានី-ខេត្តពាក់ព័ន្ធនឹងករណីដែលមានបញ្ហាបន្ទុកហិរញ្ញវត្ថុ ដើម្បីពន្លឿនការអនុវត្តនីតិវិធី។
- ភ្ជាប់ទំនាក់ទំនងជាមួយយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈក្នុងយុទ្ធសាស្ត្រទី២ ដើម្បីឆ្លើយតបចំពោះបទដ្ឋានសង្គមនានាដែលដាក់ការបន្ទោសលើជនរងគ្រោះ ដើម្បីឱ្យពួកគេមានឆន្ទៈសហការដោយស្ម័គ្រចិត្តក្នុងនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលប្រព្រឹត្តអំពើជួញដូរមនុស្សមកលើពួកគេ។ ការមាក់ងាយ និងការរើសអើង ដែលជនរងគ្រោះជាច្រើនជួបប្រទះ គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ គឺជាឧបសគ្គធំៗ ដល់ដំណើរការផ្តន្ទាទោស និងការទទួលបានយុត្តិធម៌។
- ធានាថាថ្លៃសេវាសម្រាប់នីតិវិធីតុលាការមិនមែនជាឧបសគ្គរារាំងជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌នោះឡើយ។
- ធានាថាមានប្រព័ន្ធសម្រាប់ផ្តល់ការគាំទ្រ (ភ្នាក់ងារសង្គមកិច្ច មន្ត្រីនគរបាលដែលបានទទួលការបណ្តុះបណ្តាល) ដល់ជនរងគ្រោះ ក្នុងដំណើរការនីតិវិធីទាំងមូល ដើម្បីឱ្យពួកគេមានឆន្ទៈចូលរួមនៅក្នុងដំណើរការនេះ។
- ធានាឱ្យមានមូលនិធិ ជួយរ៉ាប់រងចំណាយនានារបស់ជនរងគ្រោះ ក្នុងអំឡុងពេលអនុវត្តដំណើរការនីតិវិធីតុលាការ និងផ្តល់សំណងឱ្យជនរងគ្រោះក្រោយមានសេចក្តីសម្រេចរបស់តុលាការ។
- បង្កើនការយល់ដឹងអំពីហានិភ័យថ្មីៗ ដូចជាការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងធានាថាច្បាប់មានគ្រប់គ្រាន់ដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចប្រភេទនេះ និងឆ្លើយតបចំពោះករណីទាំងនេះជាបន្តទៀត។
- ធានាថារបាយការណ៍នានាបានដាក់បញ្ចូលទិន្នន័យអំពីករណីដែលត្រូវបាន បង្ក្រាប ផ្តន្ទាទោស ឬកំពុងស្ថិតនៅក្នុងដំណើរការនីតិវិធី។

**យុទ្ធសាស្ត្រទី ៤៖ បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ**

គ.ជ.ប.ជ. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ បានធ្វើការរួមគ្នា ដើម្បីជំរុញការការពារដល់ជនរងគ្រោះ។ ស្ត្រី និងកុមារត្រូវបានផ្តល់អាទិភាព។ នីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះត្រូវបានដាក់ឱ្យអនុវត្ត និងមានការផ្តល់វគ្គបណ្តុះបណ្តាលមួយចំនួនផងដែរ។ ការងារមួយចំនួនដែលត្រូវបន្តធ្វើការកែលម្អរួមមាន៖

- រៀបចំកញ្ចប់ឧបករណ៍បណ្តុះបណ្តាល អំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការប្រាស្រ័យទាក់ទងបែបផ្តល់ការគាំទ្រ ដើម្បីបណ្តុះបណ្តាលណែនាំដល់មន្ត្រីតាមស្ថាប័ន និងអង្គការពាក់ព័ន្ធ ឱ្យពួកគេអាចបង្កើតនូវបរិយាកាសដែលផ្តល់ការគាំទ្រដល់ការបង្ហាញព័ត៌មានអំពីករណីជួញដូរមនុស្សពីសំណាក់អ្នកដែលរងផលប៉ះពាល់។
- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ជនរងគ្រោះ ដែលជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ហើយចាំបាច់ត្រូវតែមានការឆ្លើយតបចំពោះការផ្តល់សំណងដល់ជនរងគ្រោះ។ លើសពីនេះ គួរមានការពិចារណាធ្វើយ៉ាងណាឱ្យមានធនធានជាក់លាក់ ដើម្បីជួយជនរងគ្រោះឱ្យធូរស្បើយពីការប៉ះទង្គិចកន្លងមក ដូចជាជនរងគ្រោះដែលត្រូវបានគេកេងប្រវ័ញ្ចជាដើម ដោយមានការគាំទ្រពីភ្នាក់ងារសង្គមកិច្ច ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។ ការផ្តល់ការគាំទ្រផ្នែកសេដ្ឋកិច្ច គឺជារឿងចាំបាច់សម្រាប់គ្រួសារ ដើម្បីឱ្យពួកគេអាចធ្វើសកម្មភាពរកប្រាក់ចំណូលបានបន្ទាប់ពីធ្វើសមាហរណកម្មរួច។
- គ.ជ.ប.ជ. គួរសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីបង្កើតមូលនិធិការពារជនរងគ្រោះ ក្នុងគោលបំណងជួយផ្តល់ការគាំទ្រដល់ជនរងគ្រោះ និងអ្នកដែលរួចរស់ពីអំពើជួញដូរមនុស្ស ដែលគេអាចហៅថា "មូលនិធិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រដ្ឋាភិបាល" ដើម្បីអាចឱ្យជនរងគ្រោះទទួលបានជំនួយគាំទ្រពីរដ្ឋាភិបាល។
- បន្តធ្វើការកែលម្អការគ្រប់គ្រងករណី និងបង្កើតប្រព័ន្ធទិន្នន័យ ដូចដែលបានលើកជាអនុសាសន៍ក្នុងផ្នែក ការអនុវត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍ពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិពីខាងដើម។

## ការវាយតម្លៃពាក់កណ្ដាលអាណត្តិលើ-ផែនការយុទ្ធសាស្ត្រជាតិ ៥ ឆ្នាំ ២០១៩-២០២៣ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## ការណែនាំសម្រាប់ការសម្ភាស – គ.ជ.ប.ជ.

### I. ការណែនាំ

- ពន្យល់ពីគោលបំណងនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិ ទៅកាន់អ្នកដែលកំពុងត្រូវបានសម្ភាស និងពីអ្វីដែលនឹងកើតមានឡើងជាមួយទិន្នន័យដែលប្រមូលបាន។
- កត់ត្រាពីបុគ្គលដែលអ្នកកំពុងនិយាយជាមួយ។
    - តើអ្នកមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះពាក់ព័ន្ធនឹង គ.ជ.ប.ជ.?

### II. ការពិភាក្សាអំពីរចនាសម្ព័ន្ធ មុខងារ និងតួនាទីសម្របសម្រួលរបស់ គ.ជ.ប.ជ.

*ក. លេខាធិការដ្ឋាន៖*

- តើរចនាសម្ព័ន្ធ គ.ជ.ប.ជ. ជួយសម្រេចអាណត្តិការងាររបស់ខ្លួនបែបណាខ្លះ? តើមានចំណុចខ្លាំងធំៗជាងគេអ្វីខ្លះ?
- តើ គ.ជ.ប.ជ. ទទួលបានជោគជ័យ និងជួបប្រទះបញ្ហាប្រឈមធំៗអ្វីខ្លះ នៅក្នុងរចនាសម្ព័ន្ធ ការបំពេញមុខងារ និងតួនាទីសម្របសម្រួលរបស់ខ្លួន?
- តើ គ.ជ.ប.ជ. សម្របសម្រួលយ៉ាងដូចម្ដេចខ្លះជាមួយក្រុមការងារ? គ.ខ.ប.ជ.? ក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត? អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ? តួអង្គអន្តរជាតិ តួអង្គផ្សេងទៀត?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យ គ.ជ.ប.ជ. ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព?
    ១. ធនធានហិរញ្ញវត្ថុ? (ថវិកា)
    ២. ធនធានមនុស្ស? តើ គ.ជ.ប.ជ. មានបុគ្គលិកគ្រប់គ្រាន់ (សមត្ថភាព ត្រូវជំនាញ ចំនួនបុគ្គលិកដែរឬទេ)
    ៣. កិច្ចសហប្រតិបត្តិការអន្តរ-រដ្ឋាភិបាល?
    ៤. បច្ចេកវិទ្យា?
    ៥. នយោបាយ?
    ៦. ឧបសគ្គផ្សេងទៀត?

- តើ គ.ជ.ប.ជ. និរន្តរភាពក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ខ្លួនដែរឬទេ? ហេតុអ្វី?
- តើជំងឺកូវីដ ១៩ បង្កផលប៉ះពាល់អ្វីខ្លះដល់ការបំពេញមុខងាររបស់ គ.ជ.ប.ជ.?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឱ្យ គ.ជ.ប.ជ. បំពេញមុខងារកាន់តែប្រសើរ?

*ខ. ក្រុមការងារ៖*

បង្ការទប់ស្កាត់ ការពារជនរងគ្រោះ អនុវត្តច្បាប់ កិច្ចការយុត្តិធម៌ ទំនាក់ទំនងអន្តរជាតិ និងទេសន្តរប្រវេសន៍

*សម្រាប់ក្រុមការងារនីមួយៗ សូមពិភាក្សាពីសំណួរដូចខាងក្រោម*

- តើក្រុមការងារ xx មានអាណត្តិការងារអ្វីខ្លះ?
- តើការដឹកនាំក្រុមនេះមានប្រសិទ្ធភាពដែរឬទេ (រៀបរាប់ពីមូលហេតុដែលមានប្រសិទ្ធភាព និងមូលហេតុដែលពុំមានប្រសិទ្ធភាព)?
- តើក្រុមនេះមានសមាជិកសមស្របដែរឬទេ? តើសមាជិកក្រុមមានជំនាញត្រូវនឹងការងារ – សម្រេចតួនាទីភារកិច្ចរបស់ក្រុមការងារដែរឬទេ?
- តើក្រុមការងារ X មានជោគជ័យ និងបញ្ហាប្រឈមធំៗអ្វីខ្លះ? តើចំណុចនេះមានការកែលម្អអ្វីដែរឬទេ ចាប់តាំងពីការវាយតម្លៃពាក់កណ្តាលអាណត្តិលើចុងក្រោយរួចមក?
- តើមានប្រព័ន្ធពិនិត្យតាមដានសម្រាប់ ពិនិត្យតាមដាន និងរាយការណ៍ពីជោគជ័យ និងបញ្ហាប្រឈមនានាដែរឬទេ?
- តើក្រុមការងារ XX ធ្វើការងារជាមួយនឹង គ.ជ.ប.ជ. យ៉ាងដូចម្តេចខ្លះ? ពាក់ព័ន្ធនឹងគណៈកម្មាធិការដទៃទៀត? ជាមួយ គ.ខ.ប.ជ.?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យក្រុមការងារ XX ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព?
    - ធនធានហិរញ្ញវត្ថុ? (ថវិកា)
    - ធនធានមនុស្ស? តើ គ.ជ.ប.ជ. មានបុគ្គលិកគ្រប់គ្រាន់ (សមត្ថភាព ត្រូវជំនាញ ចំនួនបុគ្គលិកដែរឬទេ)
    - កិច្ចសហប្រតិបត្តិការអន្តរ-រដ្ឋាភិបាល?
    - បច្ចេកវិទ្យា?
    - នយោបាយ?
    - ឧបសគ្គផ្សេងទៀត?
- តើជំងឺកូវីដ ១៩ បង្កផលប៉ះពាល់អ្វីខ្លះដល់ការបំពេញមុខងាររបស់ក្រុមការងារ?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឱ្យក្រុមការងារ XX អាចបំពេញមុខងាររបស់ខ្លួនកាន់តែល្អប្រសើរ? តើប្រព័ន្ធការងាររបស់ក្រុមការងារនេះមាននិរន្តរភាពដែរឬទេ? ហេតុអ្វី?

*គ. គ.ខ.ប.ជ.៖*

- តើ គ.ខ.ប.ជ. មានអាណត្តិការងារអ្វីខ្លះ?
- តើ គ.ខ.ប.ជ. មានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយនឹង គ.ជ.ប.ជ.? ជាមួយនឹងរចនាសម្ព័ន្ធផ្សេងទៀត ក្នុងជួររដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ?
- តើ គ.ខ.ប.ជ. បំពេញមុខងារយ៉ាងដូចម្តេចនៅក្នុងខេត្តនីមួយៗ? តើ គ.ខ.ប.ជ. ណាដែលបំពេញការងារបានល្អប្រសើរ និងនៅកន្លែងណាដែលមិនបានបំពេញការងារល្អប្រសើរ?
- តើកត្តាអ្វីខ្លះ ដែលធ្វើ គ.ខ.ប.ជ. អាចបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព?
- តើ គ.ខ.ប.ជ. សម្រេចបានជោគជ័យធំៗជាងគេអ្វីខ្លះ?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យ គ.ខ.ប.ជ. ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព?
    - ធនធានហិរញ្ញវត្ថុ? (ថវិកា)
    - ធនធានមនុស្ស? តើ គ.ជ.ប.ជ. មានបុគ្គលិកគ្រប់គ្រាន់ (សមត្ថភាពត្រូវជំនាញ ចំនួនបុគ្គលិកដែរឬទេ)
    - កិច្ចសហប្រតិបត្តិការអន្តរ-រដ្ឋាភិបាល?
    - បច្ចេកវិទ្យា?
    - នយោបាយ?
    - ឧបសគ្គផ្សេងទៀត?
- តើជំងឺកូវីដ ១៩ បង្កផលប៉ះពាល់អ្វីខ្លះដល់ការបំពេញមុខងាររបស់ គ.ខ.ប.ជ.?
- តើកន្លងមកផែនការយុទ្ធសាស្ត្រជាតិ/គ.ជ.ប.ជ./គ.ខ.ប.ជ. មានឥទ្ធិពលអ្វីខ្លះលើការទប់ស្កាត់ និងឆ្លើយតបចំពោះករណីជួញដូរមនុស្ស?
- តើ គ.ជ.ប.ជ. មាននិរន្តរភាពនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួនដែរឬទេ? ហេតុអ្វី?
- តើមានប្រព័ន្ធសម្រាប់តាមដាន និងរាយការណ៍ពីជោគជ័យ និងបញ្ហាប្រឈមដែរឬទេ?
- តើ គ.ខ.ប.ជ. ឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះស្ថានភាពជួញដូរមនុស្សនៅកម្ពុជាដែរឬទេ? ប្រសិនបើមិនបានឆ្លើយតបឱ្យមានប្រសិទ្ធភាព ហេតុអ្វី?

## IV. តើកន្លងមកមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

**យុទ្ធសាស្ត្រទី ១៖** ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

**យុទ្ធសាស្ត្រទី ២៖** លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

**យុទ្ធសាស្ត្រទី ៣៖** ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

**យុទ្ធសាស្ត្រទី ៤៖** បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ

*សម្រាប់យុទ្ធសាស្ត្រនីមួយៗ សូមពិភាក្សាសំណួរខាងក្រោម៖*

- សម្រាប់យុទ្ធសាស្ត្រ X តើមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ រហូតមកដល់ពេលបច្ចុប្បន្ននេះ ?
- តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការសម្រេចបានលទ្ធផលនៃយុទ្ធសាស្ត្រ X?
- តើមានការអនុវត្តសកម្មភាពអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ ?
- តើសូចនាករនៅក្នុងយុទ្ធសាស្ត្រ X មានភាពពាក់ព័ន្ធជាមួយស្ថានភាពបច្ចុប្បន្នដែរឬទេ ? តើមានផលប៉ះពាល់ផ្សេងគ្នាអ្វីខ្លះ សម្រាប់បុរស និងស្ត្រី ?
- តើរចនាសម្ព័ន្ធនឹងការបំពេញមុខងាររបស់ គ.ជ.ប.ជ. មានឥទ្ធិពលលើជោគជ័យនៃសូចនាករដែរឬទេ ?
- តើមានប្រព័ន្ធពិនិត្យតាមដាន សម្រាប់តាមដាន និងរាយការណ៍ពីជោគជ័យ និងបញ្ហាប្រឈមដែរឬទេ ?
- តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ធ្វើការកែលម្អ ?
- តើផែនការយុទ្ធសាស្ត្រជាតិ/គ.ជ.ប.ជ. មានឥទ្ធិពលអ្វីខ្លះ មកលើការបង្ការទប់ស្កាត់ និងឆ្លើយតបករណីជួញដូរមនុស្សគិតរហូតដល់ពេលបច្ចុប្បន្ននេះ ? តើជំងឺកូវីដ ១៩ បានបង្កផលប៉ះពាល់អ្វីខ្លះ ?
- តើ គ.ជ.ប.ជ. បានឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សនៅកម្ពុជាដែរឬទេ ? ហេតុអ្វី ?
- តើអ្នកមានអនុសាសន៍អ្វីខ្លះ ដើម្បីធ្វើការកែលម្អ ?
- តើមានអ្វីផ្សេងទៀត ដែលអ្នកគិតថាសំខាន់ ដែលអ្នកត្រូវដឹង ?

## I. សេចក្ដីផ្ដើម

- ពន្យល់ពីគោលបំណងនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិ ទៅកាន់អ្នកដែលកំពុងត្រូវបានសម្ភាស និងពីអ្វីដែលនឹងកើតមានឡើងជាមួយទិន្នន័យដែលប្រមូលបាន។
- កត់ត្រាពីបុគ្គលដែលអ្នកកំពុងនិយាយជាមួយ។
    - តើអ្នកមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះពាក់ព័ន្ធនឹង គ.ជ.ប.ជ.?

## II. ការពិភាក្សាអំពីរចនាសម្ព័ន្ធ មុខងារ និងតួនាទីសម្របសម្រួលរបស់ គ.ជ.ប.ជ.

### *ក. ក្រុមការងារ៖*

- តើក្រុមការងារនៃ គ.ជ.ប.ជ. មានអាណត្តិការងារអ្វីខ្លះ?
- តើក្រុមការងារ X ទទួលបានជោគជ័យ និងមានបញ្ហាប្រឈមធំៗអ្វីខ្លះ?
- តើក្រុមការងារ XX ធ្វើការងារយ៉ាងដូចម្ដេចខ្លះជាមួយនឹង គ.ជ.ប.ជ.? ពាក់ព័ន្ធនឹងគណៈកម្មាធិការដទៃទៀត? ជាមួយ គ.ខ.ប.ជ.?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យក្រុមការងារ XX ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព?
    - ធនធានហិរញ្ញវត្ថុ? (ថវិកា)
    - ធនធានមនុស្ស? តើ គ.ជ.ប.ជ. មានបុគ្គលិកគ្រប់គ្រាន់ (សមត្ថភាព ត្រូវជំនាញ ចំនួនបុគ្គលិកដែរឬទេ)
    - កិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល?
    - ឧបសគ្គផ្សេងទៀត?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឱ្យមុខងាររបស់ក្រុមការងារ XX កាន់តែមានភាពល្អប្រសើរ?

### *ខ. លេខាធិការដ្ឋាន៖*

- តើលេខាធិការដ្ឋាន គ.ជ.ប.ជ. មានអាណត្តិការងារអ្វីខ្លះ?
- តើ គ.ជ.ប.ជ. បានសម្រេចជោគជ័យ និងមានបញ្ហាប្រឈមធំៗអ្វីខ្លះ ក្នុងការបំពេញតាមអាណត្តិការងាររបស់ខ្លួន?
- តើ គ.ជ.ប.ជ. បានសម្របសម្រួលជាមួយក្រុមការងារប្រកបដោយប្រសិទ្ធភាពកម្រិតណា? គ.ខ.ប.ជ.? ក្រសួងស្ថាប័នដទៃទៀត? សហគមន៍អន្តរជាតិ? ដទៃទៀត?

- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យ គ.ជ.ប.ជ. ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព?
    ១. ធនធានហិរញ្ញវត្ថុ? (ថវិកា)
    ២. ធនធានមនុស្ស? តើ គ.ជ.ប.ជ. មានបុគ្គលិកគ្រប់គ្រាន់ (សមត្ថភាព ត្រូវជំនាញ ចំនួនបុគ្គលិកដែរឬទេ)
    ៣. កិច្ចសហប្រតិបត្តិការអន្តរ-រដ្ឋាភិបាល?
    ៤. ឧបសគ្គផ្សេងទៀត?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឱ្យ គ.ជ.ប.ជ. បំពេញមុខងារកាន់តែប្រសើរ?

*គ. គ.ខ.ប.ជ.៖*
- តើ គ.ខ.ប.ជ. សម្រេចបានជោគជ័យធំៗអ្វីខ្លះ?
- តើកត្តាអ្វីខ្លះដែលជាឧបសគ្គធ្វើឱ្យ គ.ខ.ប.ជ. មិនអាចដំណើរការទៅដោយមានប្រសិទ្ធភាព?

## IV. តើកន្លងមកមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

**យុទ្ធសាស្ត្រទី ១៖** ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

**យុទ្ធសាស្ត្រទី ២៖** លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

**យុទ្ធសាស្ត្រទី ៣៖** ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

**យុទ្ធសាស្ត្រទី ៤៖** បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ

*សម្រាប់យុទ្ធសាស្ត្រនីមួយៗ សូមពិភាក្សាសំណួរខាងក្រោម៖*
- សម្រាប់យុទ្ធសាស្ត្រ X តើមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ រហូតមកដល់ពេលបច្ចុប្បន្ននេះ?
- តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការសម្រេចបានលទ្ធផលនៃយុទ្ធសាស្ត្រ X?
- តើមានការអនុវត្តសកម្មភាពអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ?
- តើសូចនាករនៅក្នុងយុទ្ធសាស្ត្រ X មានភាពពាក់ព័ន្ធជាមួយស្ថានភាពបច្ចុប្បន្នដែរឬទេ? តើមានផលប៉ះពាល់ផ្សេងគ្នាអ្វីខ្លះ?
- តើរចនាសម្ព័ន្ធ និងការបំពេញមុខងាររបស់ គ.ជ.ប.ជ. មានឥទ្ធិពលលើជោគជ័យនៃសូចនាករដែរឬទេ?
- តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ធ្វើការកែលម្អ?
- តើ គ.ជ.ប.ជ. បានឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សនៅកម្ពុជាដែរឬទេ? ហេតុអ្វី?
- តើអ្នកមានអនុសាសន៍អ្វីខ្លះ ដើម្បីធ្វើការកែលម្អ?
- តើមានអ្វីផ្សេងទៀត ដែលអ្នកគិតថាសំខាន់ ដែលអ្នកត្រូវដឹង?

## ការវាយតម្លៃពាក់កណ្តាលអាណត្តិលើ-ផែនការយុទ្ធសាស្ត្រជាតិ ៥ ឆ្នាំ ២០១៩-២០២៣ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## ការណែនាំសម្រាប់ការសម្ភាស – គ.ខ.ប.ជ.

### I. សេចក្តីផ្តើម

- ពន្យល់ពីគោលបំណងនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ ទៅកាន់អ្នកដែលកំពុងត្រូវបានសម្ភាស និងពីអ្វីដែលនឹងកើតមានឡើងជាមួយទិន្នន័យដែលប្រមូលបាន។
- កត់ត្រាពីបុគ្គលដែលអ្នកកំពុងនិយាយជាមួយ។
    - តើអ្នកមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះពាក់ព័ន្ធនឹង គ.ជ.ប.ជ.?

### II. ការពិភាក្សាអំពីរចនាសម្ព័ន្ធ មុខងារ និងតួនាទីសម្របសម្រួលរបស់ គ.ជ.ប.ជ.

- តើ គ.ខ.ប.ជ. មានអាណត្តិការងារអ្វីខ្លះ? តើ គ.ខ.ប.ជ. មានរចនាសម្ព័ន្ធ យ៉ាងដូចម្តេចនៅក្នុងខេត្តរបស់អ្នក?
- តើ គ.ខ.ប.ជ. មានជោគជ័យ និងបញ្ហាប្រឈមធំៗអ្វីខ្លះ?
- តើ គ.ខ.ប.ជ. សម្របសម្រួលយ៉ាងដូចម្តេចខ្លះជាមួយ គ.ជ.ប.ជ.?? ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត? សហគមន៍អន្តរជាតិ? ដទៃទៀត?
- តើ គ.ខ.ប.ជ. ធ្វើការជាមួយនឹងក្រុមការងារនៃ គ.ជ.ប.ជ. ដែរឬទេ? ដោយរបៀបណា?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យ គ.ខ.ប.ជ. បំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព?
    ១. ធនធានហិរញ្ញវត្ថុ? (ថវិកា), ធនធានមនុស្ស? កិច្ចសហប្រតិបត្តិការអន្តរ-រដ្ឋាភិបាល?
    ២. ឧបសគ្គផ្សេងទៀត?
- តើ គ.ខ.ប.ជ. ឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជាដែរឬទេ? តើមានការសម្រេចបានលទ្ធផលផ្សេងគ្នាសម្រាប់បុរស និងស្ត្រីដែរឬទេ?
- តើជំងឺកូវីដ ១៩ បង្កផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ មកលើការបំពេញមុខងាររបស់ គ.ខ.ប.ជ.?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឱ្យការបំពេញមុខងាររបស់ គ.ខ.ប.ជ. កាន់តែមានភាពល្អប្រសើរ?
- តើមានចំណុចអ្វីផ្សេងទៀតដែលសំខាន់ត្រូវដឹង?

## III. តើកន្លងមកមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ[8]

**យុទ្ធសាស្ត្រទី ១៖** ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

**យុទ្ធសាស្ត្រទី ២៖** លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

**យុទ្ធសាស្ត្រទី ៣៖** ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

**យុទ្ធសាស្ត្រទី ៤៖** បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ

- តើមានអាទិភាពជាយុទ្ធសាស្ត្រអ្វីខ្លះនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ដែល គ.ខ.ប.ជ. បានអនុវត្តកន្លងមក?
- តើអាទិភាពជាយុទ្ធសាស្ត្រទាំងនេះ ឆ្លើយតបចំពោះស្ថានភាពនៃការជួញដូរមនុស្សនាពេលបច្ចុប្បន្ននៅក្នុងខេត្តរបស់អ្នកដែរឬទេ? តើជំងឺកូវីដ ១៩ បង្កផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ មកលើហានិភ័យ ឬលទ្ធភាពឆ្លើយតបចំពោះជំងឺកូវីដ ១៩?
- តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលរារាំងដល់ការសម្រេចលទ្ធផលក្នុងយុទ្ធសាស្ត្រ X? តើបញ្ហាប្រឈមទាំងនេះមានលក្ខណៈផ្សេងគ្នា នៅពេលឆ្លើយតបចំពោះតម្រូវការរបស់បុរស និងស្ត្រីដែរឬទេ?
- តើបច្ចុប្បន្ននេះមានការធ្វើអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ?
- តើសូចនាករនៅក្នុងយុទ្ធសាស្ត្រ X មានភាពពាក់ព័ន្ធជាមួយស្ថានភាពបច្ចុប្បន្នដែរឬទេ? តើមានផលប៉ះពាល់ផ្សេងគ្នាអ្វីខ្លះ សម្រាប់បុរស និងស្ត្រី?
- តើវេទនាសម្ព័ន្ធនឹងការបំពេញមុខងាររបស់ គ.ជ.ប.ជ. មានឥទ្ធិពលលើជោគជ័យនៃសូចនាករដែរឬទេ?
- តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ធ្វើការកែលម្អ?
- តើយុទ្ធសាស្ត្រដែលត្រូវបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ បានឆ្លើយតបចំពោះតម្រូវការពីអ្នកដែលរួចរស់ពីករណីជួញដូរមនុស្សនៅកម្ពុជាដែរឬទេ? ហេតុអ្វី? តើអ្នកសង្កេតឃើញចំណុចផ្សេងគ្នាសម្រាប់បុរស និងស្ត្រីដែរឬទេ (ចំណុចខ្លាំង ឬបញ្ហាប្រឈម)?
- តើអ្នកមានអនុសាសន៍អ្វីខ្លះ ដើម្បីបង្កើនប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រជាតិ និងមុខងាររបស់ គ.ខ.ប.ជ.?
- តើមានអ្វីផ្សេងទៀត ដែលអ្នកគិតថាសំខាន់ ដែលអ្នកត្រូវដឹង?

[8] សមិទ្ធផលសម្រេចបានលម្អិតនឹងត្រូវពិនិត្យ និងចេញពីរបាយការណ៍តាមរយៈការសម្ភាស និងអង្គការក្រៅរដ្ឋាភិបាល។ អាចនឹងមានការសម្ភាសបន្ថែមដើម្បីប្រមូលព័ត៌មាន

## I. សេចក្ដីផ្ដើម

- ពន្យល់ពីគោលបំណងនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិ ទៅកាន់អ្នកដែលកំពុងត្រូវបានសម្ភាស និងពីអ្វីដែលនឹងកើតមានឡើងជាមួយទិន្នន័យដែលប្រមូលបាន។
- កត់ត្រាពីបុគ្គលដែលអ្នកកំពុងនិយាយជាមួយ។
    - តើអ្នកមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះពាក់ព័ន្ធនឹង គ.ជ.ប.ជ.?

## II. ការពិភាក្សាអំពីរចនាសម្ព័ន្ធ មុខងារ និងតួនាទីសម្របសម្រួលរបស់ គ.ជ.ប.ជ.

### *ក. លេខាធិការដ្ឋាន៖*

- តើលេខាធិការដ្ឋាន គ.ជ.ប.ជ. មានអាណត្តិការងារអ្វីខ្លះ?
- តើ គ.ជ.ប.ជ. បានសម្រេចជោគជ័យ និងមានបញ្ហាប្រឈមធំៗអ្វីខ្លះ ក្នុងការបំពេញតាមអាណត្តិការងាររបស់ខ្លួន?
- តើ គ.ជ.ប.ជ. បានសម្របសម្រួលជាមួយក្រុមការងារប្រកបដោយប្រសិទ្ធភាពកម្រិតណា? គ.ខ.ប.ជ.? ក្រសួងស្ថាប័នដទៃទៀត? សហគមន៍អន្តរជាតិ? ដទៃទៀត?
- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងមិនឱ្យ គ.ជ.ប.ជ. ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីឱ្យ គ.ជ.ប.ជ. បំពេញមុខងារកាន់តែប្រសើរ?

### *ខ. ក្រុមការងារ៖*

បង្ការទប់ស្កាត់ ការពារជនរងគ្រោះ អនុវត្តច្បាប់ កិច្ចការយុត្តិធម៌ ទំនាក់ទំនងអន្តរជាតិ និងទេសន្តរប្រវេសន៍

តើក្រុមការងារអ្វីដែលអង្គការរបស់អ្នកពាក់ព័ន្ធជាងគេ?

តើក្រុមការងារទាំងនេះដំណើរការយ៉ាងដូចម្ដេចខ្លះ?

- តើការដឹកនាំក្រុមនេះមានប្រសិទ្ធភាពដែរឬទេ (សូមរៀបរាប់ពីមូលហេតុដែលមានប្រសិទ្ធភាព ឬមូលហេតុដែលពុំមានប្រសិទ្ធភាព)?
- តើក្រុមនេះមានសមាជិកសមស្របដែរឬទេ? តើសមាជិកក្រុមមានជំនាញត្រូវនឹងការងារ – ដើម្បីបំពេញតាមអាណត្តិការងារដែរឬទេ?
- តើគណៈកម្មការ X សម្រេចបានជោគជ័យ និងបញ្ហាប្រឈមធំៗអ្វីខ្លះ?
- តើក្រុមការងារ XX ធ្វើការងារជាមួយនឹង គ.ជ.ប.ជ. យ៉ាងដូចម្ដេចខ្លះ? ជាមួយគណៈកម្មាធិការដទៃទៀត? ជាមួយ គ.ខ.ប.ជ.?

- តើមានឧបសគ្គអ្វីខ្លះ ដែលរារាំងក្រុមការងារ XX មិនឱ្យបំពេញការងារកាន់តែមានប្រសិទ្ធភាព?
- តើមានអនុសាសន៍អ្វីខ្លះ ដើម្បីធ្វើការបំពេញមុខងាររបស់ក្រុមការងារកាន់តែមានភាពល្អប្រសើរ?

*គ. គ.ខ.ប.ជ.៖*

តើអង្គការរបស់អ្នកទំនាក់ទំនងជាមួយនឹង គ.ខ.ប.ជ. ដែរឬទេ? ប្រសិនបើមាន៖

- តើ គ.ខ.ប.ជ. សម្រេចបានជោគជ័យធំៗអ្វីខ្លះ?
- តើមានឧបសគ្គអ្វីខ្លះដែលធ្វើឱ្យ គ.ខ.ប.ជ. មិនអាចបំពេញមុខងារប្រកបដោយប្រសិទ្ធភាព
- តើ គ.ខ.ប.ជ. ឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជាដែរឬទេ? តាមបែបណាខ្លះ ឬប្រសិនបើពុំមានប្រសិទ្ធភាព ហេតុអ្វី?

## IV. តើកន្លងមកមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

**យុទ្ធសាស្ត្រទី ១៖** ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា

**យុទ្ធសាស្ត្រទី ២៖** លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ

**យុទ្ធសាស្ត្រទី ៣៖** ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

**យុទ្ធសាស្ត្រទី ៤៖** បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ

*តើអង្គការរបស់អ្នកធ្វើការងារពាក់ព័ន្ធនឹងយុទ្ធសាស្ត្រណាមួយ? (ពិនិត្យមើលយុទ្ធសាស្ត្រនោះ ព្រមទាំងយុទ្ធសាស្ត្រដទៃទៀត ដែលពួកគេលើលឡើង ដើម្បីកត់ត្រាវឌ្ឍនភាព)*

- សម្រាប់យុទ្ធសាស្ត្រ X តើមានការសម្រេចបានសមិទ្ធផលអ្វីខ្លះ រហូតមកដល់ពេលបច្ចុប្បន្ននេះ?
- តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការសម្រេចបានលទ្ធផលនៃយុទ្ធសាស្ត្រ X? តើជំងឺកូវីដ ១៩ បង្កផលប៉ះពាល់អ្វីខ្លះមកលើហានិភ័យនៃការជួញដូរមនុស្ស និងសមត្ថភាពឆ្លើយតប?
- តើមានការអនុវត្តសកម្មភាពអ្វីខ្លះ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ?
- តើសូចនាករនៅក្នុងយុទ្ធសាស្ត្រ X មានភាពពាក់ព័ន្ធជាមួយស្ថានភាពបច្ចុប្បន្នដែរឬទេ? តើមានផលប៉ះពាល់ផ្សេងគ្នាអ្វីខ្លះ?
- តើរចនាសម្ព័ន្ធ និងការបំពេញមុខងាររបស់ គ.ជ.ប.ជ. មានឥទ្ធិពលលើជោគជ័យនៃសូចនាករដែរឬទេ?
- តើមានអនុសាសន៍អ្វីខ្លះ សម្រាប់ធ្វើការកែលម្អ?
- តើ គ.ជ.ប.ជ., គ.ខ.ប.ជ. ក្រុមការងារជំនាញ និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ បានឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សនៅកម្ពុជាដែរឬទេ? ហេតុអ្វី?
- តើអ្នកមានអនុសាសន៍អ្វីខ្លះ ដើម្បីធ្វើការកែលម្អ?
- តើមានអ្វីផ្សេងទៀត ដែលអ្នកគិតថាសំខាន់ ដែលអ្នកត្រូវដឹង?

**សេចក្តីបញ្ជាក់ ÷**

**របាយការណ៍នេះអាចផលិតឡើងបានដោយមានជំនួយដ៏សប្បុរស របស់ពលរដ្ឋអាមេរិកតាមរយៈ  ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ។ ខ្លឹមសារនៅក្នុងរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលអាមេរិកឡើយ។**